ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jun-2012, 14:34
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០០ នាទី**

**សវនាការលើកទី៦៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្ដារា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក អេនឌ្រូ ចេមស៍ ម៉ាគិនថាយអ៊័រ
*(Mr. Andrew James MCINTYRE)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ថារីក អាប់ឌុលហ្ទាក់
*(Mr. Tarik ABDULHAK)*

លោក កែត រេយ៍ន័រ *(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

(*Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោកស្រី ឡៅ ជុនធី

លោកស្រី ទី ស្រ៊ីនណា

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ស៊ីន សុវ៉ន | ខ្មែរ |
| លោក បាណាបេ ណេគ្វី | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក មឿន សុវណ្ណ (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោក សគីម ល្មុត (TCW-583) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សគីម លូត** (TCW-583)

សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖..........................................................ទំព័រ ៣
សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្តើមពី៖......................................................................ទំព័រ៥១
សួរដោយលោក បាណាបេ ណេគ្វី ផ្តើមពី៖ ..................................................................ទំព័រ ៧៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាដំបូងនេះក្រឡាបញ្ជី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវបានអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែក ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ។ ដោយគាត់បានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការដោយផ្ទាល់ពីបន្ទប់សវនាការនេះ សម្រាប់រយៈពេលពេញមួយថ្ងៃ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:០២:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

ថ្ងៃនេះយើងកត់សម្គាល់ឃើញមានការផ្លាស់ប្ដូរនូវមេធាវីប្រឹក្សាសាក្សី គឺ មឿន សុវណ្ណ អ៊ីចឹងទេ?

**លោក មឿន សុវណ្ណ៖**

បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានអត្តលេខប៉ុន្មានដែរ នៅគណៈមេធាវី?

**លោក មឿន សុវណ្ណ៖**

បាទ ខ្ញុំបាទមានអត្តលេខ៥៦១។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះសាលាដំបូងបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយគាត់សុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈដំណើរការសវនាការពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដាននៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។

[០៩:០៣:៣៥]

អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្ដីរបស់គាត់បាន។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលនៃការធ្វើសវនាការពេញមួយថ្ងៃនេះ។

[០៩:០៤:៣៣]

ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកស្រីចៅក្រម មេធាវី ហើយនិងភាគីទាំងអស់រួមទាំងសាក្សី សគឹម ល្មុត ផងដែរ។

[០៩:០៥:០០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** ខ្ញុំសូមត្រឡប់ដោយសង្ខេបទៅរកប្រធានបទមួយ ដែលយើងបានពិភាក្សាកាលពីសប្ដាហ៍មុន គឺនៅថ្ងៃទី៣១ ខែឧសភា នោះ។ ហើយនៅក្នុងនោះ គឺទំនាក់ទំនងរវាង ខៀវ សំផន ហើយនិង វន វ៉េត។ នេះគឺជាគណៈកម្មាធិការពាណិជ្ជកម្ម ហើយនិង វ៉ាន់ រិទ្ធ ផងដែរ។ ឥឡូវនេះ ដើម្បីរំឭកឡើងវិញនូវគំនិតសំខាន់ៗដែលលោកបានធ្វើសក្ខីកម្មកាលពីសប្ដាហ៍មុននោះ គឺលោកបានសង្កេតឃើញថា វន វ៉េត ជាអ្នកទទួលបន្ទុកខាងពាណិជ្ជកម្ម ហើយទាំង-- នៅក្នុងនោះ គឺទទួលបន្ទុកខាងឧស្សាហកម្មផងដែរ។ ហើយមានឯកសារមួយចំនួនដែលលោកបានពិនិត្យមើល ដែលគណៈកម្មាធិការពាណិជ្ជកម្មបានដាក់ឯកសារទៅឲ្យ ខៀវ សំផន ពិនិត្យនោះ។

[០៩:០៦:២៧]

ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតឲ្យលោកពិនិត្យមើលបន្តទៅទៀត គឺទំនាក់ទំនងនោះ ឲ្យបានលម្អិតជាងមុនបន្តិច។ ហើយលោកក៏បានបញ្ជាក់ផងដែរថា នៅពេលដែលលោកបានមកភ្នំពេញ លោកបានជួបបុគ្គលម្នាក់ឈ្មោះ អន ជាប្រធាននៃគណៈឧស្សាហកម្ម។ ថាតើគាត់មានទំនាក់ទំនងអ្វីខ្លះនៅរវាងគាត់ រវាង អន ហើយនិងគណៈកម្មាធិការឧស្សាហកម្មអានេះមួយ ហើយនិងទំនាក់ទំនងនេះទៅនឹង ខៀវ សំផន ហើយនិង វន វ៉េត បាទ?

**លោក សគីម ល្មុត៖**

**ឆ៖** បាទ សូមជម្រាបលោកប្រធាន គឺថា ខ្ញុំបាទមិនដឹងទំនាក់ទំនងច្បាស់លាស់រវាងលោក អន ហើយនិងលោក ខៀវ សំផន និងលោក វន វ៉េត ទេពេលនោះ។ ខ្ញុំគ្រាន់តែមកភ្នំពេញ គ្រាន់តែឲ្យស្នាក់នៅៗកន្លែងមួយនៅជិតមន្ទីររបស់លោក អន ហ្នឹង ហើយត្រង់ថាគាត់មានទំនាក់ទំនងយ៉ាងម៉េចៗទៅលោក វន វ៉េត ឬក៏លោក ខៀវ សំផន ខ្ញុំបាទមិនដឹងទេបាទ។

[០៩:០៧:៥៧]

**ស៖** លោកបាននិយាយថា លោកមិនដឹងច្បាស់ ប៉ុន្តែតើលោកបានដឹងអ្វីខ្លះទេបើលោកមិនប្រាកដនោះ? ផ្អែកលើការស្នាក់នៅបីឆ្នាំរបស់លោកនៅភ្នំពេញ ថាតើលោកបានដឹងពីទំនាក់ទំនងបែបនោះដែរឬទេ គឺទំនាក់ទំនងរវាងបុគ្គល ហើយនិងទំនាក់ទំនងរវាងគណៈកម្មាធិការ និងគណៈកម្មាធិការ

នោះដែរ?

**ឆ៖** ខ្ញុំបាទ សូមបញ្ជាក់អ៊ីចេះ គឺថាខ្ញុំដែលមកនៅក្បែរ និយាយពាក្យក្រសួងចុះវាស្រួលនិយាយបន្តិច ក្រសួងឧស្សាហកម្មហ្នឹង គឺថានៅមួយរយៈខ្លីទេ ដល់ក្រោយមកក៏លែងនៅជិតៗមន្ទីរបស់ក្រសួងឧស្សាហកម្មហ្នឹងហើយ ទៅនៅកន្លែងផ្សេងហើយ ដូច្នេះទំនាក់ទំនាងយ៉ាងម៉េចៗរវាងលោក អន ហើយនិងទៅថ្នាក់លើ ឬក៏លោក វន វ៉េត លោក ខៀវ សំផន យ៉ាងណាៗ គឺខ្ញុំមិនបានដឹងទេ។ ជាប្រយោលក្តី ជានេះក្តីអត់បានដឹងទេបាទ។

[០៩:០៩:១២]

**ស៖** លោកនិយាយថា លោកមិនដឹងពីទំនាក់ទំនងនោះទេ។ តើលោកបានដឹង ឬក៏មិនដឹង ថាតើអ្នកណាជាអ្នកណាជាមេដឹកនាំជាន់ខ្ពស់នៅក្នុងនោះ ថាតើ ខៀវ សំផន ឬ វន វ៉េត នៅក្នុងគណៈឧស្សាហកម្មនោះ ឬក៏ក្រសួងឧស្សាហកម្មនោះ? ប្រធានធំជាអ្នកណា?

**ឆ៖** ពេលដែលខ្ញុំមកនោះ មកដល់គឺថា គេមិនបានបញ្ជាក់ឲ្យខ្ញុំដឹងអំពីរចនាសម្ព័ន្ធយ៉ាងម៉េចៗទេ គ្រាន់តែដឹងថា ភ្លាមហ្នឹង គ្រាន់តែដឹងថា លោក ចេង-- នៅកន្លែងលោក អន ហ្នឹង ខ្ញុំនៅស្នាក់ក្បែរហ្នឹងទៅ ផ្ទះម្ខាងផ្លូវម្នាក់។ ហើយរង់ចាំ ប៉ុណ្ណឹង។ ហើយមិនបានបញ្ជាក់ថា រចនាសម្ព័ន្ធខាងគណៈកម្មាធិការសេដ្ឋកិច្ចអីៗយ៉ាងម៉េចៗក៏អត់បានបញ្ជាក់លម្អិតឲ្យខ្ញុំដឹងទេ។ ប៉ុន្តែដែលដឹងនេះ គឺថា ដោយក្រោយមកតាមឯកសារដែលអ្នកអង្កេតឲ្យខ្ញុំមើលហូរហែមក អាហ្នឹងក៏ដឹងក្រោយមកគឺថា នៅពីលើហ្នឹងវាមានហៅថា គណៈកម្មាធិការសេដ្ឋកិច្ច វាមានលោក វន វ៉េត វាមានលោក ខៀវ សំផន ហើយខាងគណៈកម្មាធិការពាណិជ្ជកម្មហ្នឹង វាមានលោក ឌឿន ហើយក្រោយមកមានលោក វ៉ាន់ រិទ្ធ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ អ៊ីចឹងដើម្បីឲ្យប្រាកដថា យើងដឹងយល់អំពីថាតើលោកដឹងនៅពេលណានោះ គឺថាខ្ញុំចង់ដកស្រង់សេចក្តីដែលលោកបានផ្តល់ទៅឲ្យសហចៅក្រមស៊ើបអង្កេតនោះ លោកបានឆ្លើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឯកសារ D279/6 បាទគឺឯកសារ D279/6 គឺកំណត់ហេតុស្តាប់ចម្លើយសាក្សី រូបនេះឯង គឺថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩។ ខ្ញុំសូមអនុញ្ញាតតុលាការ ដើម្បីបង្ហាញឯកសារផ្នែកនេះជូនសាក្សីពិនិត្យបាទ។

[០៩:១១:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

ហើយសូមមន្ត្រីតុលាការមេត្តាជួយចង្អុលបង្ហាញ គឺសំណួរនិងចម្លើយ ៣៨ គឺ A38បាទ។ បាទ A38 សំណួរចម្លើយត្រង់ចំណុចហ្នឹងបាទ។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផងដែរ ដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ ដើម្បីភាគីផ្សេងទៀតបានមើលឃើញបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីជំនួយការ បង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយនិងផ្នែកខាងសោតទស្សន៍បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍ផងដែរ!

[០៩:១៣:២១]

**លោក អាប់ឌុលឡាក់ ថារីក៖**

នៅពេលដែលយើងរង់ចាំនេះ ខ្ញុំសូមអានខ្លឹមសារនេះ ដើម្បីសន្សំពេល។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សគីម ល្មុត លោកបានឃើញផ្នែកដែលពាក់ព័ន្ធ ប៉ុន្តែនៅលើអេក្រង់ ហើយខ្ញុំអាចអាន ហើយអ្នកបកប្រែអាចតាមខ្ញុំបាន ដោយលើឯកសារនេះមាន។ សំណួរ៖ "តើលោកដឹងថា តើ ហែម មានតំណែងអ្វីទេនៅក្នុងក្រសួងឧស្សាហកម្ម?" ចម្លើយ៣៨៖ "នៅពេលដែលខ្ញុំចូលធ្វើការនៅទីនោះ គឺ អន គឺជាប្រធានក្រសួង។ បើតាមខ្ញុំស្មានប្រហែលជាឈ្មោះ ហែម ជាអ្នកមើលពីលើទៀត។ ប៉ុន្តែគាត់មិនបង្ហាញមុខទេ។ ប្រហែលជាលោក ហែម នៅក្នុងគណៈកម្មាធិការសេដ្ឋកិច្ចខាងលើ ហើយគាត់ជាអ្នកគ្រប់គ្រងទៅលើនោះឯង"។ ហើយដើម្បីឲ្យៗសមស្របទៅតាមចម្លើយរបស់លោកនោះ គឺថា ខ្ញុំអានសំណួរចម្លើយតទៅទៀត។ សំណួរ៖ "យោងទៅតាមសំណួរដែលសួរអម្បាញ់មិញ មានន័យថា ហែម ស្ថិតនៅក្នុងគណៈកម្មាធិការសេដ្ឋកិច្ច ឬក្រសួងសេដ្ឋកិច្ចនៅពេលនោះ ដែលនៅក្រោមការចាត់ចែងរបស់ វន វ៉េត មែនឬទេ?" លោកបានឆ្លើយថា ចម្លើយ៣៩៖ "បាទ ប្រហែលជា ហែម នៅ

ក្នុងគណៈកម្មាធិការសេដ្ឋកិច្ចជាមួយ វន វេត ឬមួយក៏ខាងលើជាអ្នកចាត់តាំងឲ្យគាត់មកគ្រប់គ្រងខាងផ្នែកពាណិជ្ជកម្មនេះ”។ តើលោកនៅចាំថា លោកបានឆ្លើយចម្លើយបែបនេះទៅអ្នកស៊ើបអង្កេតមកពីការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ លោកសាក្សី?

[០៩:១៥:២៤]

**ឆ៖** ខ្ញុំបានឆ្លើយយ៉ាងនេះមែនបាទ ប៉ុន្តែក៏បន្ទាប់ពីបានឃើញឯកសារអីផ្សេងៗទៀតដែរ មិនមែនថា មិនបានបង្ហាញទេ គឺអាចសន្និដ្ឋានថាដូច្នេះថា--

**ស៖** ឥឡូវនេះខ្ញុំចាប់អារម្មណ៍ទៅនឹងសេចក្តីពន្យល់របស់លោកសាក្សី ចំណុចសំខាន់នោះ គឺថាអនុលោមទៅតាមចម្លើយ ដែលកំណត់ត្រាចម្លើយសាក្សីនេះ គឺថាមុនពេលដែលលោកបានផ្តល់ចម្លើយនោះ គេបានបង្ហាញឯកសារជូនទៅលោកដើម្បីឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាង ខៀវ សំផន ហើយនិងៗក្រសួង និងមនុស្សផ្សេងទៀត ហើយអ៊ីចឹងគឺទាក់ទងទៅនឹងបាទ គឺមុនពីដែលលោកបានឃើញឯកសារនោះ តើលោកបានដឹងឬមិនដឹងពីទំនាក់ទំនងរវាង ខៀវ សំផន និង អន។ បើសិនជាលោកមិនចាំទេ សូមលោកប្រាប់ខ្ញុំផងបាទ។

[០៩:១៦:៤១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ ចាំស្តាប់ការសេចក្តីជំទាស់ពីមេធាវីការពារក្តី! សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់នៅក្នុងសាលសវនាការ។ ទាក់ទងទៅនឹងសាក្សីរូបនេះប្រហែលជាសូមឲ្យគាត់ពិនិត្យមើលសំណួរ និងចម្លើយ៣៦ និងហើយ ៣៧ ដែលអាចឲ្យគាត់មានឱកាសមើលឯកសារនេះ ពីព្រោះថាដើម្បីឲ្យគាត់ឆ្លើយ៣៧ និង ៣៨ និង ៣៩ គឺយើងត្រូវមើល៣៦ និង ៣៧ មុន។ គឺឯកសារពីរដែលគេបង្ហាញទៅឲ្យគាត់មើល ប្រហែលថាអាចអនុញ្ញាតឲ្យគាត់ឲ្យផ្តល់នូវចម្លើយពេញលេញ និងត្រឹមត្រូវជាងនេះ។ ហើយខ្ញុំសូមតុលាការអនុញ្ញាតឲ្យគាត់ពិនិត្យមើលសំណួរចម្លើយ៣៦, ៣៧ នៅលើឯកសារនេះ ដើម្បីឲ្យគាត់មានឱកាសដើម្បីឆ្លើយឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ជាងនេះបាទ។

[០៩:១៧:៥៤]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមលោកប្រធាន--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក អាកឡូវ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ដើម្បីយើងបន្តដូចសហមេធាវីការពារក្តីរបស់លោក អៀង សារី ដើម្បីឲ្យមានភាពយុត្តិធម៌ចំពោះសាក្សី យើងត្រូវតែជម្រាបជូនថា ឯកសារដែលសហព្រះរាជអាជ្ញាទើបនឹងអាននេះ គឺជាសេចក្តីសង្ខេបនៃចម្លើយរបស់គាត់ ហើយដែលអង្គជំនុំជម្រះមានៗអត្ថបទជាក់លាក់ ពាក្យពេចន៍ដែលគាត់ប្រើជាក់លាក់នៅថ្ងៃនោះ ដែលមាននៅលេខឯកសារ D279/6.14 ERN 00770738 ជាសំណៅជាភាសាបារាំង ហើយខ្ញុំយល់ឃើញថា ចម្លើយរបស់គាត់ជាមួយពាក្យ--

[០៩:១៩:២៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកអាចមិនគប្បីប្រើវេទិកានេះរំខានដល់ពេលវេលាដែលភាគីម្ខាងទៀតសួរទេ លោកអាចជំទាស់ដោយមូលហេតុអី? មូលហេតុនៃសេចក្តីជំទាស់របស់លោកចំពោះការតាំងសំណួរហ្នឹងត្រង់ចំណុចណា? ទីនេះមិនមែនជាវេទិកាបង្រៀន លោកបង្រៀនទៅភាគីម្ខាងទៀតឲ្យរៀនសួរតាំងសំណួរចំពោះសាក្សីទេ។ លោកជំទាស់មូលហេតុអី? យើងមិនបណ្តែតបណ្តោយឲ្យលោកយកវេទិកានៃការតាំងសំណួរដេញដោលទៅធ្វើអត្ថាធិប្បាយឯណាដែលវែងអន្លាយ ធ្វើឲ្យខាតពេលវេលាទេ។ ចាំពេលវេលាដែលចែកឲ្យលោកទៅ សឹមលោកអាចធ្វើបានក្នុងក្របខ័ណ្ឌ នៃការតាំងសំណួរដេញដោលចំពោះសាក្សី ហើយសេចក្តីជំទាស់ត្រូវតែនិយាយអំពីការជំទាស់ ហើយមូលហេតុនៃការជំទាស់ ជាការគ្រប់គ្រាន់ហើយ។

**លោក អាកឡូវ វែកគែន៖**

ខ្ញុំគិតថា ខ្ញុំបានគិតថាខ្ញុំធ្វើជំទាស់ហើយ ខ្ញុំ-- យ៉ាងច្បាស់លាស់ យើងមានឯកសារពីរ គឺថាកំណត់ហេតុស្តាប់ចម្លើយ--

**ប្រធានអង្គជំនុំ៖**

ឥឡូវ លោកជំទាស់រឿងស្អី ឥឡូវ ជំទាស់ទៅបានហើយ។ ពេលវេលា គឺឯកសារ គឺលោកទុក

ឯកសារសម្រាប់សួរដេញដោលខ្លួនឯង។ លោកទុកឯកសារសម្រាប់ដេញដោលខ្លួនឯងចំពោះបញ្ហានេះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា បន្តតាំងសំណួរ!

[០៩:២១:១៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំគិតថា លោកមេធាវីអាចនឹងមើលឯកសារហ្នឹង ដើម្បីជំទាស់ ហើយឯកសារដែលគាត់យោងនោះ គឺថា E3/182, D2/182។ មូលហេតុដែលខ្ញុំមិនអាច-- មិនអានចម្លើយ-- សំណួរនោះ ទៅសាក្សីនោះ គឺថាគាត់មិនបានឆ្លើយទាក់ទងទៅជាមួយ អន នោះទេ ក្នុងចំណែកនោះ។ ដើម្បីកុំឲ្យខាតពេលនៅចំណុចនេះ ខ្ញុំសូមអនុញ្ញាតបន្តទៅមុខទៀត។

**សួរលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សគីម ល្មុត បាទ យើងពិនិត្យមើលខ្លឹមសារមួយនេះ គឺថាទំនាក់ទំនង ឬក៏អំណាចនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្មនេះ។ តាមអ្វីដែលលោកបានដឹង ក្រៅពីការធ្វើរបាយការណ៍ ឬរាយការណ៍ជូនទៅ ខៀវ សំផន ឬក៏ វន វ៉េត នោះ។ តើ វ៉ាន់ រិទ្ធ មានអំណាចឯករាជ្យដើម្បីធ្វើសេចក្ដីសម្រេចអ្វីដែរឬទេ? បើសិនជាគាត់ចង់សម្រេចទាក់ទងទៅនឹងដំណើរការក្រសួងពាណិជ្ជកម្មដោយឯករាជ្យនោះ គឺថាដោយខ្លួន តើគាត់ធ្វើអ៊ីចឹងបានទេ ចំពោះ វ៉ាន់ រិទ្ធ នោះ?

**លោក សគីម ល្មុម៖**

**ឆ៖** សូមជម្រាប ថាខ្ញុំមិនអាចសន្និដ្ឋានបានទេ បាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ដើម្បីរំឭកការចងចាំរបស់លោក គឺខ្ញុំសូមអនុញ្ញាតត្រឡប់ទៅរកកំណត់ហេតុស្ដាប់ចម្លើយសាក្សី។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតតុលាការ ដើម្បីបង្ហាញដើម្បីឲ្យឯកសារ-- ឲ្យសាក្សីមើលឯកសារ D279/6 បាទ នេះជាកំណត់ហេតុស្ដាប់ចម្លើយសាក្សី ហើយក៏សូមអនុញ្ញាតដើម្បីបង្ហាញឯកសារនៅលើអេក្រង់ផងដែរបាទ។

[០៩:២៣:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណ។ លោក ល្អុត សូមលោកមើលឯកសារនេះ ហើយសូមអានទៅខាងមុខ គឺទៅរកសំណួរ និងចម្លើយ៥៦។ បាទ សូមមន្ត្រីតុលាការមេត្តាជួយលោក សាក្សីផងបាទ។

[០៩:២៥:៤៥]

**ស៖** នៅក្នុងផ្នែកនេះ នៅក្នុងចម្លើយរបស់លោក គឺលោកបានពិភាក្សាលើកឯកសារជាក់លាក់មួយចំនួន ហើយប្រសិនបើចាំបាច់ យើងខ្ញុំនឹងបង្ហាញឯកសារនេះ ជូនលោកនៅលើអេក្រង់។ ឥឡូវនេះ យើងពិនិត្យមើលយោបល់របស់លោកនៅលើចម្លើយនេះ។ បាទ គឺជាផ្នែកមួយទៀតដែលយើងបានឃើញជា *ឡេតផ័រ* ជាសៀវភៅបញ្ជីកាលសម័យនោះ។ គេបានបង្ហាញឯកសារជូនលោក គឺលេខ ERN 00278398 ហើយសូមកត់ត្រានៅក្នុងនេះ ថាតើឯកសារនោះគឺ D161/130 គឺឯកសារ D279/6.5 ចម្លើយរបស់លោកនៅលើឯកសារនោះគឺថា នៅចម្លើយ៥៦ "កាលនោះមានទំនាក់ទំនងរវាងជាមួយយូហ្គោស្លាវី ហើយគេបានស្នើលក់ឲ្យភាគីកម្ពុជា។ ពេលនោះ វ៉ាន់ រិទ្ធ គ្មានសិទ្ធិសម្រេចទិញ ឬមិនទិញនោះទេ។ ដូច្នេះ ត្រូវសួរទៅថ្នាក់លើដែលមាន វន វេត និង ហែម ជាអ្នកស៊ីញ៉េ នេះជាហត្ថលេខារបស់ វ៉ាន់ រិទ្ធ។ ហែម បានចារបញ្ជាក់មកវិញបងវន មិនយកទេសូមរកមធ្យោបាយប្រាប់ត្រឡប់មកវិញ។ ខ្ញុំមិនអាចអានភាសាអង់គ្លេស ខ្ញុំមិនអាចឃើញ-- មិនអាចមើលឃើញបានទេ។ បញ្ជីនេះ-- បញ្ជីនេះមិនដែលបានឃើញទេ ព្រោះមិនពាក់ព័ន្ធនឹងខាងធនាគារ ដោយសារសេចក្ដីសម្រេចត្រូវធ្វើឡើងដោយថ្នាក់លើនៅ-- ចម្លើយត្រូវធ្វើឡើងដោយថ្នាក់លើ"។

លោក ល្អុត តើនេះជាសេចក្ដីសង្ខេបត្រឹមត្រូវដែរឬទេ នៅពេលដែលលោកធ្វើសេចក្ដីសង្កេតទៅលើឯកសារនោះ? ហើយ វ៉ាន់ រិទ្ធ មិនមានការ-- មិនមានអំណាចក្នុងការធ្វើសេចក្ដីសម្រេចដោយខ្លួនគាត់នោះទេ។

[០៩:២៧:០៧]

**លោក សគីម ល្អុត ៖**

**ឆ៖** បាទ អម្បាញ់មិញនេះ គឺខ្ញុំបានឆ្លើយថា ខ្ញុំមិនដឹងថា លោក វ៉ាន់ រិទ្ធ នោះគាត់មានសិទ្ធិសម្រេច ឬមិនសម្រេចអ្វីទេ គឺតែដល់ក្នុងនេះគឺថា ដល់តែឃើញឯកសារនុ៎ងយកបង្ហាញអ៊ីចឹងឃើញថា គាត់ចារនោះគឺថា ទៅខាងលើ។ ដូច្នេះ បានន័យថា ទិញលក់អី ទាល់តែគាត់ស្នើទៅខាងលើ តែពីមុនមកខ្ញុំមិនដឹងថា គាត់មានសិទ្ធិត្រឹមណាៗក៏មិនដឹងដែរ។ ពីព្រោះក្នុងគណៈកម្មាធិការពាណិជ្ជកម្ម

ហ្នឹងគឺវាដោយឡែកពីខាងការងារធនាគាររបស់ខ្ញុំ ពិតមែនតែអង្គុយជិតគ្នាមែនកន្លែង ប៉ុន្តែមិនមែនខ្ញុំចេះតែទៅជ្រៀតជ្រែកចង់ដឹងការងារស្អី គេមិនឲ្យខ្ញុំដឹងទេ អាហ្នឹងគឺជាក់ស្តែង។ ហើយដូចខ្ញុំបញ្ជាក់ក្នុង៥៦នេះគឺ តាមចំណារនោះវាអ៊ីចឹងហើយ ខ្ញុំឃើញថា គាត់ លោក វ៉ាន់ រិទ្ធ គាត់ស៊ីញ៉េទៅ ហើយឈ្មោះ ហែម បានចារបញ្ជាក់មកវិញថា បងវន ៗមិនយកទេ គឺថាអត់ទិញទេ។ សូមរកមធ្យោបាយប្រាប់ត្រឡប់ទៅវិញ ឲ្យប្រាប់ថាទៅភាគីយូហ្គោស្លាវីថា អីវ៉ាន់ហ្នឹងអត់ទិញទេ ឲ្យ វ៉ាន់ រិទ្ធ ហ្នឹងនិយាយសម្រួលឆ្លើយគេទៅ។ ហើយដល់មានចំណារជាអក្សរអង់គ្លេសនេះ ខ្ញុំមើលមិនដាច់ មិនដឹងជាៗថាអីទេ ខ្ញុំចាំកាលនោះគឺ ល្អិតៗខ្ញុំ-- បើឲ្យឃើញឥឡូវនេះមើលម្តងទៀតបែបខ្ញុំអាច ពេលនោះខ្ញុំថា ខ្ញុំមើលមិនដាច់។ មិនមែនថា ខ្ញុំមិនចេះភាសាអង់គ្លេស តែចំណារខ្ញុំមើលមិនដាច់។ ហ្នឹងតាមខ្ញុំចាំបាទ។ ហើយបញ្ជីទាំងនេះ ខ្ញុំមិនដែលបានឃើញទេ ព្រោះមិនពាក់ព័ន្ធនឹងខាងធនាគារទេ ព្រោះការទិញដូរអីហ្នឹងគឺថាពាណិជ្ជកម្មហ្នឹងគេៗ ទាក់ទងជាមួយយូហ្គោអីហ្នឹង គេផ្ញើទៅ អត់មានឆ្លងកាត់ខាងធនាគារត្រូវដឹងមិនត្រូវដឹង ព្រោះអត់មែន អត់មានទិញដូរអីផងជាក់ស្តែង មិនទាន់ចូលទៅខាង បើសម្រេចទិញអីទៅអាចគេពឹងធនាគារអីទៅ នេះវាអត់ផង។ ហើយខ្ញុំបញ្ជាក់ថា ការដែលខ្ញុំឆ្លើយហ្នឹងវា ខ្ញុំរក្សាតាមហ្នឹង។

[០៩:២៩:៣២]

**ស៖** នេះជាការយល់របស់ខ្ញុំផងដែរ។ សូមអរគុណច្រើន។ ឯកសារដដែលនេះ គឺឯកសារនេះបានយកមកគឺបញ្ជីឯកសារនេះ បានយកសួរលោកនៅក្នុងកិច្ចសម្ភាសលើកទីពីរ ខ្ញុំចង់សួរទៅលោកថាតើលោកអាចបញ្ជាក់បានទេ ថាវាត្រឹមត្រូវ ឬក៏អត់? ហើយនៅក្នុងបញ្ជីនៃឯកសារនេះ គឺយើងនឹងបញ្ចប់--

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតសូមបង្ហាញឯកសារ D279/7 ៗ ដែល-- ឬក៏លេខ E3/105។ ជាកិច្ចសម្ភាសចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ គឺប្រធានបទដែលយើងកំពុងតែពិភាក្សាគ្នាមុននេះដដែលហ្នឹង។ ខ្ញុំចង់បង្ហាញថា តើសាក្សីគាត់នឹងអាចមានការអធិប្បាយអីបន្ថែមទៀតដែរឬក៏យ៉ាងណា? ដូច្នេះ បើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកជូនទៅសាក្សីពិនិត្យ

ហើយនិងដាក់បញ្ចាំងនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ផង!

សូមអញ្ជើញលោកមេធាវី!

[០៩:៣១:១៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ អម្បាញ់មិញនេះខ្ញុំបានស្ដាប់លោកសាក្សីគាត់មានប្រសាសន៍ថា សុំឲ្យតំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារដែលជាប់ពាក់ព័ន្ធកាលពីសហចៅក្រមស៊ើបអង្កេតបង្ហាញគាត់។ តើសហព្រះរាជអាជ្ញា គាត់បដិសេធ ឬមួយក៏គាត់យល់ព្រម ឬយ៉ាងម៉េច? បាទ សូមអរគុណ។ សូមជួយពន្យល់!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំបានអានសំណួរពាក់ព័ន្ធនៅក្នុងឯកសារ D នេះដើម្បីបង្កលក្ខណៈឲ្យសាក្សីគាត់អាចចាំអំពីចំណារ ហើយនិងចម្លើយរបស់គាត់ទេ ពីព្រោះខ្ញុំចង់សន្សំសំចៃពេលវេលា។

លោកប្រធាន បើសិនណាជាលោកប្រធានអនុញ្ញាតឲ្យខ្ញុំបង្ហាញឯកសារដែលមេធាវីលើកអម្បាញ់មិញនេះ ខ្ញុំនឹងបង្ហាញឯកសារនេះតែម្ដងក៏បានដែរលោកប្រធាន។

ដូច្នេះធ្វើយ៉ាងនេះទៅមេធាវីការពារក្ដីក៏អាចនឹងឃើញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រនេះផងដែរ។

[០៩:៣២:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា តាមបច្ចេកទេស និងវិទ្យាសាស្ត្រដែលលោកមានលទ្ធភាពអាចធ្វើការតាំងសំណួរដេញដោលសាក្សី នៅចំពោះមុខក្នុងនាមលោកជាភាគីខាងចោទប្រកាន់ទៅតាមមុខងាររបស់ខ្លួន។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រឡប់ទៅលើកំណត់ហេតុស្ដាប់ចម្លើយសាក្សី គឺឯកសារ D279/7 ឬក៏ឯកសារ E3/105។ ដូច្នេះ ខ្ញុំសូមបង្ហាញឯកសារនេះនៅលើអេក្រង់ ដើម្បីឲ្យភាគីទាំង

អស់បានឃើញឯកសារនេះ។

សូមឲ្យមន្ត្រីបច្ចេកទេសមេត្តាជួយបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ។ ពេលវេលា ខ្ញុំសូមអានតែម្តង។

[០៩:៣៣:៥៥]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត គឺខ្ញុំសួរលោកទៅសំណួរទីប្រាំពីរ សំណួរចម្លើយទីប្រាំពីរ។ ជាកំណត់ហេតុស្តាប់ចម្លើយសាក្សី។ សំណួរនិងចម្លើយទីប្រាំពីរ។ សំណួរដែលសួរទៅលោកនោះគឺសួរទាក់ទងទៅនឹងបញ្ជីទំនិញដដែលដែលលោកបានលើកឡើង។ ខ្ញុំសូមដកស្រង់តែម្តង។ “កាលពីម្សិលមិញយើងបានបង្ហាញឯកសារជូនលោកនូវឯកសារដែលមានលេខ ERN00278398 ឥឡូវយើងនឹងបង្ហាញលោកនូវឯកសារនេះសាជាថ្មីម្តងទៀត។ យោងទៅតាមអ្វីដែលលោកបានអានក្នុងឯកសារនេះ តើលោកយល់ព្រម ឬមិនយល់ស្រប ដែលថាចំពោះមុខងារដែលគេចាត់តាំង ហែម និង វន វ៉េត នោះ គឺពួកគេមានអំណាចគ្រប់គ្រាន់សម្រាប់ណែនាំទៅដល់អ្នកដែលនៅខាងក្រោម”។ រួចហើយលោកឆ្លើយថា៖ “បាទ ខ្ញុំយល់ស្រប”។ តើនេះគឺជាសេចក្តីសង្ខេបនៃចម្លើយរបស់លោកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះមែនឬទេ?

[០៩:៣៥:០៩]

**ឆ៖** បាទ នេះគឺខ្ញុំឃើញតែទំនាក់ទំនងហ្នឹង ខ្ញុំយល់ស្របអ៊ីចឹង ឃើញថាដោយសារឈរលើឯកសារទំនាក់ទំនងគ្នាទេ ប៉ុន្តែត្រង់ថាឲ្យខ្ញុំដឹងថាជារចនាសម្ព័ន្ធយ៉ាងម៉េចៗមុនមិនដឹងទេ។ គឺដល់មើលឯកសារហ្នឹង ឃើញថា មានការទំនាក់ទំនងអ៊ីចឹង គឺថាខាងក្រោមស្នើទៅ ហើយខាងលើហ្នឹងជាអ្នកសម្រេច។ អាហ្នឹង គឺឈរទៅលើឯកសារដែលខ្ញុំឃើញហ្នឹង មិនមែនជាគំនិតខ្ញុំគិតពីមុនមកយ៉ាងម៉េចដឹងតែឈរលើឯកសារហ្នឹង វាអ៊ីចឹងហើយ បើឯកសារហ្នឹង វាប្រភពហ្នឹងវាពិត គឺវាអ៊ីចឹងហើយ។

**ស៖** សូមអរគុណ។ ហើយយើងទុកឯកសារនេះមួយអន្លើ។ លោក ល្អុត ប្រហែលជាលោកអាចនៅចាំថា នៅថ្ងៃទី៣១ ខែឧសភា លោកបានលើកឡើងនូវរបាយការណ៍មួយចំនួនទាក់ទងទៅនឹងដំណើរការទស្សនកិច្ចរបស់គណៈប្រតិភូប្រទេស ហើយលោកក៏បានផ្តល់ជាចំណារនៅលើរបាយការណ៍នេះផងដែរ។ បើតាមដែលខ្ញុំស្វែងយល់អំពីទំនាក់ទំនងនេះទៅ ប្រសិនណាជាយើងពិនិត្យមើលទៅឯកសាររបស់ក្រសួងពាណិជ្ជកម្មមួយចំនួនទៀតនោះ ដែលពេលនោះលោកក៏បានឃើញឯកសារទាំង

នោះក្នុងពេលស្ដាប់ចម្លើយរបស់លោកនោះ។ ហើយលោកក៏បានផ្ដល់មតិយោបល់ទៅលើឯកសារទាំងនេះផងដែរ ពីព្រោះវាមានលក្ខណៈខុសគ្នាខ្លះ។

[០៩:៣៧:០៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន អ្វីដែលខ្ញុំមានក្នុងដៃនេះ គឺខ្ញុំមានបញ្ជីទំនិញចំនួនប្រាំមួយ ជាឯកសារហិរញ្ញវត្ថុដែលចុះកាលបរិច្ឆេទពីខែមករា ៧៨ រហូតទៅដល់ពាក់កណ្ដាលខែតុលា ឆ្នាំ៧៨។ ខ្ញុំមានឯកសារចំនួនប្រាំមួយ សម្រាប់គោលបំណងក្នុងពេលនេះតែម្ដង គឺថាឯកសារទាំងអស់នេះ គឺមានលក្ខណៈស្រដៀងគ្នាស្ទើរតែដូចគ្នាបេះបិទតែម្ដង។

ដូច្នេះ អ្វីដែលខ្ញុំស្នើសុំនេះ គឺខ្ញុំសូមបង្ហាញទៅលើលោកសាក្សីនូវឯកសារទីមួយ និងឯកសារចុងក្រោយបំផុត គឺទីប្រាំមួយ។ ខ្ញុំនឹងបង្ហាញជូននូវកំណត់ត្រាទាំងអស់នេះទៅជូនសាក្សី។

បើសិនជាមានការអនុញ្ញាតពីអង្គជំនុំជម្រះ ខ្ញុំសូមបង្ហាញឯកសារដំបូងបំផុត និងឯកសារចុងក្រោយក្នុងចំណោមឯកសារទាំងប្រាំមួយនេះ។

[០៩:៣៨:១៨]

ឯកសារទីមួយ ដូចខ្ញុំបានជម្រាបជូន គឺជាឯកសារចុះកាលបរិច្ឆេទខែមករា ៧៨ មានឯកសារ D161/1.14 និងឯកសារ D279/6.6។ បើអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំសូមបង្ហាញឯកសារពីរនេះជូនទៅសាក្សី។ ឯកសារនេះ គឺជាឯកសារ ជាឧបសម្ព័ន្ធភ្ជាប់ទៅនឹងកិច្ចសម្ភាសស្ដាប់ចម្លើយសាក្សីលើកទីមួយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតជាបឋម! ឱ្យផ្ដល់ឯកសារជូនទៅសាក្សី ដើម្បីពិនិត្យតាមរយៈមន្ត្រីរដ្ឋបាលតុលាការជាមុនសិន។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញា ជូនសាក្សីពិនិត្យ!

[០៩:៣៩:២២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត បើសិនណាជាលោកមើលឯកសារដែលមានហត្ថលេខារបស់លោកនៅខាងក្រោមនោះ។

លោកសាក្សី ក្រោយពីមើលឯកសារនេះហើយ ថាតើលោកធ្លាប់បានឃើញឯកសារនេះដែរឬទេ?

[០៩:៣៩:៥៦]

**លោក សគីម ល្អុត៖**

**ឆ៖** មុននឹងឆ្លើយបញ្ហានេះ ខ្ញុំសូមបញ្ជាក់ឡើងវិញថា កន្លែងខ្ញុំធ្វើការហ្នឹងគឺថាវានៅជាប់ជាមួយការងារពាណិជ្ជកម្ម ហើយខ្ញុំឃើញតែឯកសារដែលឲ្យខ្ញុំអាន ឲ្យខ្ញុំមើលបង្ហាញហ្នឹង គឺថាពាក់ព័ន្ធនឹងៗនែ៎ ការងារពាណិជ្ជកម្មច្រើនណាស់ ហើយខ្ញុំជម្រាបពីខាងដើមគឺថា វាសាមសិបឆ្នាំជាងហើយ ហើយខ្ញុំមិនអាចចងចាំបានទេ។ ហើយការងារពាណិជ្ជកម្មហ្នឹង ខ្ញុំមិនទៅជ្រៀតជ្រែកការងារគេទេ។ ដូច្នេះដែលខ្ញុំឆ្លើយនេះ គឺថាបន្ទាប់ពីខាងលោកស៊ើបអង្កេតបង្ហាញ យកបង្ហាញ មកបង្ហាញខ្ញុំនេះ គឺលេខហ្នឹងថា ដែលខ្ញុំស៊ីញេហ្នឹង គឺថាខ្ញុំស៊ីញេបានអានទេ មិនមែនថា ខ្ញុំពីមុនមកបានឃើញទេ។ សូមបញ្ជាក់អ៊ីចឹង។ ខ្ញុំសូមបញ្ជាក់ម្តងឡើងវិញ គឺថា សាមសិបឆ្នាំហើយ ការងារគេគឺរបស់គេហើយ ហើយដោយសារតែខ្ញុំនៅជាប់ហ្នឹង វាហាក់ដូចជាខ្ញុំហ្នឹងស្អីក៏ដឹងៗនៅហ្នឹង។ ប៉ុន្តែឲ្យឯកសារមកខ្ញុំក៏សហការអាណាខ្ញុំថាអាចវាអ៊ីចឹងមែន។ អាណាថា ខ្ញុំមិនដឹង។ អាហ្នឹងខ្ញុំសូមជម្រាបប៉ុណ្ណេះ។ សូមអស់។

[០៩:៤១:០៨]

**ប្រធានអង្គជំនុំ៖**

គោលបំណងនៃការតាំងសំណួរអម្បាញ់មិញនេះ គឺសួរថា តើឯកសារដែលជូនទៅលោកសាក្សីចំនួនពីរនេះ តើលោកសាក្សីធ្លាប់ជួបឯកសារ? ធ្លាប់បានឃើញឯកសារហ្នឹងពីមុនមកទេ មុនពេលមកថ្ងៃនេះ មុនពេលលោកមកផ្តល់សក្ខីកម្មនៅពេលនេះ? ពីមុនមកដែលថា ពេលណាក៏បានដែរ ឲ្យតែពីមុនមកធ្លាប់ឃើញ ធ្លាប់ជួប ជាពិសេស គឺត្រូវបានបង្ហាញឯកសារនេះដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលដែលស៊ើបអង្កេតកន្លងមកនៅក្នុងឆ្នាំ២០០៩ ជាដើម។ អ៊ីចឹងគ្រាន់តែប៉ុណ្ណឹងទេ ហើយចំពោះខ្លឹមសារអានោះ គឺទៅតាមជាក់ស្តែង។ សំណួរទីមួយគ្រាន់តែបានឃើញទេ ដើម្បីឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យដេញដោលឯកសារនេះ ឬក៏មិនអនុញ្ញាត។

[០៩:៤១:៥៥]

**លោក សគីម ល្អុត៖**

**ឆ៖** សូមជម្រាបលោកប្រធានបាទ ពេលដែលស៊ើបអង្កេតនេះបានយកឲ្យខ្ញុំអានមែន ហើយខ្ញុំក៏បានចុះហត្ថលេខាថាៗ បានអាន។ ប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា យើងអនុញ្ញាតឲ្យបង្ហាញឯកសារនេះ នៅលើអេក្រង់ទូរទស្សន៍ និងឲ្យផ្នែកខាងសោតទស្សន៍បង្ហាញឯកសារនៅលើងអេក្រង់កុំព្យូទ័រ ហើយនិងទូរទស្សន៍ផងដែរ។

[០៩:៤២:៣០]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត នៅពេលដែលយើងរង់ចាំការបង្ហាញឯកសារនៅលើអេក្រង់ លោកអាចពិនិត្យមើលឯកសារក្រដាសនៅចំពោះមុខលោកតែម្តង។ ហើយសូមចូលមកមើលអក្សរសរសេរដោយដៃនេះ តើលោកអាចអានសំណេរ ដោយដៃនេះបានឬទេ? ឬក៏បើលោកអានមិនបានទេ ខ្ញុំនឹងអាចអានជូនលោកបាន។

**លោក សគីម ល្អុត៖**

**ឆ៖** លោកប្រធានបាទ ខ្ញុំៗអានបាន ខ្ញុំសូមអាន គឺថា “បានផ្ញើជូន បងហែម និង វន” ដោយហត្ថលេខាហ្នឹងដូច ហត្ថលេខារបស់លោក វ៉ាន់ រិទ្ធ តាមខ្ញុំចាំបាន។ ប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណច្រើន។ ការបកប្រែជាភាសាអង់គ្លេស គឺមានការបាត់បន្តិច តើលោកបានជម្រាបអម្បាញ់មិញថា ហត្ថលេខានេះ ជាហត្ថលេខារបស់ វ៉ាន់ រិទ្ធ មែនទេ?

[០៩:៤៣:៥៥]

**ឆ៖** បាទ បើតាមខ្ញុំចាំបាន ដូចជារបស់គាត់ហើយបាទ។

**ស៖** សូមអរគុណច្រើន។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ដូចខ្ញុំបានជម្រាបជូនរួចមកហើយ គឺថាខ្ញុំចង់បង្ហាញឯកសារចុងក្រោយបំផុត គឺឯកសារទី៦ នៃបញ្ជីទំនិញនេះ ដែលគេបានបង្ហាញជូនដោយការិយាល័យសហចៅក្រមស៊ើបអង្កេត គឺ

ឯកសារនេះចុះកាលបរិច្ឆេទខែតុលា ឆ្នាំ៧៨។ លេខឯកសារនេះ គឺ E3/500 ហើយក៏មានលេខជា IS.20.1.40 និងឯកសារ D279/11។ ខ្ញុំសូមបង្ហាញឯកសារនេះជូនទៅសាក្សីចង់បញ្ជាក់ទៅគាត់ថា តើគាត់បាន ធ្លាប់បានឃើញឯកសារនេះពីមុនៗដែរឬក៏អត់? សូមការអនុញ្ញាតពីអង្គជំនុំជម្រះ។

[០៩:៤៥:០៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនសាក្សីពិនិត្យ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី ក្នុងឯកសារនេះគួរណាស់តែមានហត្ថលេខារបស់លោក តែយ៉ាងណាក៏ដោយ ខ្ញុំសូមសួរថា ពីមុនមកលោកធ្លាប់បានឃើញឯកសារនេះដែរឬទេ?

**លោក សគឹម ល្មុត៖**

**ឆ៖** បាទ ខ្ញុំមិនចាំថាបានឃើញទេឯកសារហ្នឹង។

[០៩:៤៦:០៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ឯកសារនេះគឺខ្ញុំយោងទៅលើសំណួរ និងចម្លើយ៥៨ នៃកំណត់ហេតុស្តាប់ចម្លើយនៃឯកសារ D279/6 ហើយបញ្ជីទំនិញនេះគឺថា វាជាប់ឧបសម្ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយនេះ គឺខ្ញុំយល់ឃើញថា សាក្សីមិនអាចចាំនូវឯកសារទេ បើបង្ហាញជូនគាត់គឺជាង២០ឯកសារឯណោះ។ ខ្ញុំបានដឹងថា ឯកសារនេះបានបង្ហាញជូនឲ្យសាក្សីហើយ។ ដូច្នេះចង់ឲ្យសាក្សីពិនិត្យមើលឯកសារនេះផ្ទាល់តែម្តង។ ដូច្នេះប្រសិនណាជាមានការអនុញ្ញាតពីអង្គជំនុំជម្រះ ខ្ញុំសូមបង្ហាញជូនឯកសារនេះទៅសាក្សីតែម្តង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញា យកទៅជូនសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

បើសិនណាជាមន្ត្រីបច្ចេកទេសអាចបង្ហាញជូនឯកសារនេះនៅលើអេក្រង់ថែមទៀតបាទ។

សូមអរគុណ។ ដោយសារតែពេលវេលាខ្លីនោះ ខ្ញុំសូមសួរតែម្តង។

[០៩:៤៧:២៦]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកល្អុត ឥឡូវនេះខ្ញុំសូមមើលឯកសារតែមួយសន្លឹកនេះទេ ដោយមានចំណារនៅផ្នែកខាងលើខាងឆ្វេងខាងលើនេះ។ ដើម្បីការកត់ត្រាទៅក្នុងប្រតិចារឹកនេះ ខ្ញុំសួរទៅលោកថាតើលោកអាចអានចំណងជើងនៅខាងលើ គឺចំកណ្តាលបន្ទាត់តែម្តង ចំណងជើងចំកណ្តាលតែម្តង ផ្នែកខាងលើលោកអាចអានបានទេ?

**លោក សគីម ល្អុត៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ឡើងវិញ គឺថាឯកសារនេះ អំមិញខ្ញុំបានជម្រាបអង្គតុលាការអំមិញថាពីមុនខ្ញុំមិនដែលបានឃើញទេ។ ប៉ុន្តែពេលដែលស៊ើបអង្កេតនោះ លោកស៊ើបអង្កេតបានយកបង្ហាញហើយខ្ញុំបានស៊ីញ៉េត្រង់នេះ ថាបានឃើញ។ ពីមុនអត់បានឃើញទេ តែមិនដឹងជាម៉េចឃើញមកនេះ។ ហើយនៅក្នុងហ្នឹងអានថា បានផ្ញើជូនបង វន និង ហែម ហើយ។ ហើយស៊ីញ៉េដែល លោក វ៉ាន់ រិទ្ធដដែលហ្នឹង ថ្ងៃ២១/១០ បានផ្ញើជូនបង វន និង ហែម ហើយ។

[០៩:៤៨:៥៥]

**ស៖** សូមអរគុណលោកសាក្សី។ ប៉ុន្តែខ្ញុំចង់ឲ្យលោកអានគឺចំណងជើងរបស់ឯកសារនេះតែម្តងនៅផ្នែកខាងលើចំកណ្តាលផ្នែកខាងលើនេះ។

**ឆ៖** បាទ ចំណងជើងដាក់ថា “ការប្រើប្រាស់ឥណទាន” នេះមិនច្បាស់ដែរ មិនដឹងប៉ុន្មានមួយរយ-- “ការប្រើប្រាស់ឥណទាន--” នៅតែមិនច្បាស់។ ឃើញមាន មិនដឹង១៤០ ឬក៏២០០ ទេ លានយ៉ន លេខហ្នឹងមិនច្បាស់ទេណា។ ខ្ញុំសូមអានថា ការប្រើប្រាស់ឥណទាន លេខមិនច្បាស់ទេ ដាក់ថាលានយ៉ន ត្រឹមថ្ងៃ ដូចជា ០៥ ឬ១៥ ទេ តុលា ឆ្នាំ១៩៧៨ បាទ។

[០៩:៥០:០០]

**ស៖** សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន លោក លោកស្រីចៅក្រម ដូចខ្ញុំបានជម្រាបខាងដើមហើយ ខ្ញុំសូមអានឯកសារលេខឯកសារបួន គឺបញ្ជីទំនិញសម្រាប់គោលបំណង ដោយសារវាមានគោលបំណងដូចគ្នា គឺជាអាច

មានកាលបរិច្ឆេទខុស និងតួលេខខុសគ្នា។ ឯកសារមុនបំផុត គឺឯកសារចុះកាលបរិច្ឆេទខែមករា ហើយ ឯកសារបន្ទាប់មកទៀតគឺឯកសារ D161/1.13 ហើយឯកសារនេះក៏បានទៅជា និងប្តូរជាលេខ ឯកសារ D279/6.7 គឺឯកសារចុះខែមេសា ៧៨ ឯកសារ D161/13 បាទឯកសារនេះជាន់គ្នាទេ សូមអធ្យាស្រ័យ ហើយឯកសារមួយទៀតចុះខែមេសា ៧៨ ឯកសារ D161/1.20 គឺឯកសារចុះកាលបរិច្ឆេទខែមេសា ៧៨ ឯកសារនេះមានលេខ D161/1.21 ហើយនិងឯកសារមួយទៀតចុះខែកក្កដា ឆ្នាំ ៧៩ (ស៊ីក) គឺឯកសារ D161/1.25។ យើងខ្ញុំបានបង្ហាញជូននូវឯកសារទីមួយ និងឯកសារចុងក្រោយ គឺទីប្រាំមួយហើយៗ ដែលមានចំណារដូចគ្នាតែមួយនោះ។

[០៩:៥១:៥២]

ឥឡូវនេះ សូមយើងចូលទៅនិយាយគ្នាអំពីឯកសារចុងក្រោយ ចុះកាលបរិច្ឆេទ ខែតុលា ៧៨ គេបង្ហាញឯកសារមួយចំនួនទៀតចុះខែមករា ៧៨-- ខែមករា រហូតទៅដល់ខែវិច្ឆិកា ៧៨ ដោយស្នើសុំការអនុញ្ញាតពីលោកប្រធានបង្ហាញឯកសារទីមួយ និងឯកសារចុងក្រោយដដែលនេះ ដើម្បីចង់ដឹងថាសាក្សីចាំ ឬមិនចាំ។ ឯកសារទីមួយនេះ គឺឯកសារ D279/6.12។ ឯកសារនេះក៏ជាឯកសារភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីនេះផងដែរ។ ដូច្នេះបើមានការអនុញ្ញាតពីអង្គជំនុំជម្រះ ខ្ញុំសូមបង្ហាញជូនសាក្សីតែម្តង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតជាបឋម! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ខ្ញុំសូមអធ្យាស្រ័យដោយសារការកាត់ទៅសហព្រះរាជអាជ្ញា។ មិនមែនជាការជំទាស់ខ្លាំងក្លាណាស់ណាទៅនឹងសំណួររបស់សហព្រះរាជអាជ្ញានោះទេ។ ទាក់ទងទៅនឹងការបង្ហាញឯកសារនេះ តាមដែលខ្ញុំដឹងគឺឯកសារបានអាននៅលើអេក្រង់រួចទៅហើយ។ ខ្ញុំ-- បើសិនណាជាអង្គជំនុំជម្រះមិនយល់ទាស់ទេ សូមសួរទៅសាក្សី ហើយឲ្យសាក្សីបញ្ជាក់មក--

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំបានបញ្ជាក់ហើយ ថានេះជាឯកសារមួយសេរីតែម្តង។ ខ្ញុំបានបង្ហាញទៅមេធាវីការពារក្តី

ក៏ដូចអ្នកដទៃទៀត ដើម្បីរកឲ្យឃើញថានេះគឺក្នុងពេលនោះ គឺគេបានបង្ហាញឯកសារមួយសេរីបែបនេះជូនទៅសាក្សី។ អ៊ីចឹងបានជាខ្ញុំចាប់ផ្តើមសាកសួរបែបនេះឯង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តការងាររបស់លោក!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត ជាថ្មីម្តងទៀត ក្រោយពីលោកមើលឯកសារទាំងអស់នេះហើយ ថាតើធ្លាប់បានឃើញឯកសារទាំងនេះទេ?

[០៩:៥៥:០០]

**លោក សគីម ល្អុត៖**

**ឆ៖** គឺមុនចៅក្រមស៊ើបអង្កេតទៅធ្វើបង្ហាញ យកឯកសារទៅបង្ហាញខ្ញុំពេលស៊ើបអង្កេតនោះ ខ្ញុំដូចមិនចាំថាបានឃើញឯកសារហ្នឹងទេ។ ពេលស៊ើបអង្កេតបានយកឯកសារហ្នឹង ខ្ញុំទៅឲ្យខ្ញុំអានបាទ។ ពីមុន ខ្ញុំមិនចាំថាបានឃើញ ឬក៏គេយកទៅបង្ហាញខ្ញុំយ៉ាងម៉េចៗ ខ្ញុំមិនចាំដែរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញឯកសារនៅលើអេក្រង់ និងដើម្បីឲ្យភាគីដទៃទៀត បានឃើញនោះ គឺឯកសារ D279/6.12។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋ-- មន្ត្រីជំនួយការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយនិងខាង អេ.វី បង្ហាញនេះ លើកញ្ចាក់-- លើអេក្រង់ទូរទស្សន៍ផងដែរ។

[០៩:៥៦:១៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត ខ្ញុំសូមសួរលោកសាជាថ្មីម្តងទៀត។ គឺសូមឲ្យលោកជួយអានចំណាងជើង

ឯកសារនៅផ្នែកខាងលើចំត្រង់កណ្ដាលនេះតែម្ដង ដើម្បីជាការកត់ត្រាចូលក្នុងប្រតិចារឹក។

**លោក សតឹម ល្មុត៖**

**ឆ៖** បាទ ខ្ញុំសូមអានចំណងជើងវាដាក់ថា "ការប្រើប្រាស់ឥណទាន ១៤០លានយ៉ន ត្រឹមថ្ងៃ៣១ តុលា ១៩៧៨"។ ហើយចំណារសរសេរថា "បានផ្ញើជូនបងៗ ហែម ហើយ ពីរច្បាប់ ថ្ងៃ០៤ ១១"។ បាទ ហត្ថលេខាហ្នឹង ដូចជាហត្ថលេខាលោក វ៉ាន់ រិទ្ធ។

**ស៖** ដោយហេតុថា គឺមានកាលបរិច្ឆេទនោះទៀត គឺថាលោកមើលខាងស្ដាំដៃ នៅមានអត្ថបទដែលវាយអង្គុលីលេខនៅខាងក្រោម។ បាទ បន្ទាត់ពីរខាងក្រោមនោះ អាចុង តើលោកបានឃើញទេនៅខាងស្ដាំដៃ អានថាម៉េច "ភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៧៨ គណៈកម្មាធិការពាណិជ្ជកម្ម"។ តើលោកបានឃើញទេ?

**ឆ៖** ខ្ញុំអានគឺថា "ភ្នំពេញ ថ្ងៃ០៤ វិច្ឆិកា ១៩៧៨ គណៈកម្មាធិការពាណិជ្ជកម្ម"។

**ស៖** សូមអរគុណ។ ឯកសារនេះ ដូចដែលលោកបានអាននេះ គឺបញ្ជូនគឺទៅតែ ហែម ទេ។ គឺគេបានជូនលោក ហែម។ បាទ នៅពេលនេះ តើ វន វ៉េត គាត់ទៅណា នៅដើមខែវិច្ឆិកា ឆ្នាំ១៩៧៨ បានយើងឃើញតែឈ្មោះ ហែម នៅលើចំណារនេះបាទ?

[០៩:៥៨:៥០]

**ឆ៖** បាទ លោកប្រធាន ខ្ញុំមិនដឹងទេបាទ។

**ស៖** តើលោកបាននៅកន្លែងធ្វើការរបស់លោករហូត ទាល់តែចុងបញ្ចប់នៃកម្ពុជាប្រជាធិប-តេយ្យហ្នឹង ដែរឬទេ? គឺរហូតដល់ថ្ងៃទី០៦ ឬទី០៧ មករា ឆ្នាំ១៩៧៩ នោះ មែនឬទេ?

**ឆ៖** បាទ ខ្ញុំនៅដល់ៗចុងបញ្ចប់ហ្នឹងបាទ។ នៅរហូតបាទ។

**ស៖** ដូច្នេះ ខ្ញុំពិនិត្យមើលទៅឃើញថា លោកមិនបានដឹងទេ ថាពេលនោះ លោកមិនដឹងថា វន វ៉េត នៅឯណា? តើលោកបានឃើញគាត់ ឬមិនបានឃើញគាត់នៅកន្លែងធ្វើការរបស់លោកនោះ? ខ្ញុំចង់សួរលោកថា នៅដំណាក់កាលនេះ គឺនៅ គឺនៅក្នុងខែធ្នូ ឆ្នាំពីរពាន់-- អ៊ំ ឆ្នាំ១៩៧៨ ហើយនិងដើមខែមករា ឆ្នាំ១៩៧៩ នោះ តើលោកបានឃើញគាត់ទេ?

[១០:០០:០៧]

**ឆ៖** សូមឆ្លើយអ៊ីចេះ គឺថានៅក្នុងកន្លែងគណៈកម្មាធិការពាណិជ្ជកម្ម ហើយនិងខ្ញុំធ្វើការក្បែរហ្នឹងៗ មុនមកក៏មិនដែលឃើញលោក វន វ៉េត ទៅធ្វើការនៅកន្លែងនុ៎ងដែរ ហើយក៏គាត់-- ហេតុអី

បានថាគាត់មិនឃើញកន្លែងនេះ ក៏ខ្ញុំមិនដឹងជា គាត់ទៅណាមកណា ពេលណា ក៏ខ្ញុំមិនដឹងបានដែរ ព្រោះមិនដែលទាក់ទងគ្នាមកទេបាទ។

[១០:០០:៤២]

**ស៖** តើលោកបានឮអ្វីខ្លះទេ ទាក់ទងទៅនឹងទីកន្លែងរបស់គាត់ ឬមុខងាររបស់គាត់នៅក្នុងសម័យកាលនោះ គឺក្នុងអំឡុងខែវិច្ឆិកា នោះគឺថា នៅប៉ុន្មានចុងក្រោយនៅរបបកម្ពុជាប្រជាធិបតេយ្យ ហ្នឹងទាក់ទងនឹង វន វ៉េត បាទ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេបាទ។

**ស៖** ដើម្បីឲ្យខ្ញុំយល់លោកបានច្បាស់នោះ លោកនិយាយថា លោកមិនបានដឹងអ្វីទេនៅក្នុងសម័យកាលនេះ គឺមិនបានដឹងពី វន វ៉េត ទេ បើមិនដឹង តើលោកមានបានឮអ្វីពីគាត់ដែរឬទេ?

**ឆ៖** ខ្ញុំក៏មិនបានឮដែរបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងអានឲ្យលោកស្តាប់នូវសេចក្តីដកស្រង់ចេញពីកំណត់ហេតុទីមួយរបស់លោក ដែលលោកបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតពីតុលាការនេះ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតជម្រាបលេខឯកសារនោះគឺយើងបានមើលឯកសារ D29/6 (ស៊ីក) បាទ។ បាទ ជាកំណត់ហេតុស្តាប់ចម្លើយសាក្សី ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ បាទ។ សូមអនុញ្ញាតតុលាការដើម្បីនឹងជូនសាក្សីទៅមើលផ្នែកមួយ នៃកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ បាទគឺ D279/6។

[១០:០២:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត តើលោកមានកំណត់ហ្នឹងហើយឬទេ? សូមលោកពិនិត្យទៅដល់សំណួរ និងចម្លើយលេខ៦០ បាទគឺ លេខ៦០ ហើយនិង៦១ ដែរ ដើម្បីឲ្យច្បាស់ ហើយយើងខ្ញុំនឹងឲ្យលោកពិនិត្យមើល យើងខ្ញុំនឹងអាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានសូមអនុញ្ញាត ដើម្បីបង្ហាញឯកសារនេះ នៅលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំនឹងអានជូនលោក ល្អុត ស្តាប់អំពីសំណួរនិងចម្លើយ។ បាទបន្ទាប់ពីផ្នែកមួយដែលលោកបានពិភាក្សាអំពីបញ្ជីទំនិញ ដែលយើងទើបតែបានសួរដេញដោលបន្ទាប់ទៅនេះបាទ។ នេះគឺជាសំណួរៗលេខ៦០ ដកស្រង់៖ “តើលោកអាចពន្យល់ប្រាប់យើងបានទេថា ហេតុអ្វីបានជាផ្ញើជូនទៅតែ ហែម ម្នាក់មិនផ្ញើទៅ វន វ៉េត?” ចម្លើយ៦០៖ “ខ្ញុំមិនដឹងទេ។ ប្រហែលជាមានការប្រែប្រួលនៅថ្នាក់លើ ហើយខ្ញុំមានឋានៈទាប ដូច្នេះខ្ញុំមិនដឹងមូលហេតុទេ”។ សំណួរបន្ទាប់៖ “ពេលនោះ វន វ៉េត បានបាត់ខ្លួនថាតើមានអ្នកណានិយាយអំពីរឿងនេះដែរឬទេ?” ចម្លើយ៦១ លោកបានឆ្លើយថា ដកស្រង់៖ “គ្មានអ្នកណានិយាយអំពីរឿងនេះទេ ខ្ញុំគ្រាន់តែឮថា គាត់ត្រូវបានគេផ្លាស់ចេញ តែគ្មានអ្នកណាម្នាក់បញ្ជាក់រឿងនេះឲ្យច្បាស់ទេ ហើយ រិទ្ធ ក៏មិនដែលនិយាយប្រាប់ខ្ញុំដែរ នៅពេលនោះទោះបីជា ខ្ញុំស្គាល់ វ៉ាន់ រិទ្ធ ច្បាស់ក៏ដោយ ខ្ញុំក៏មិនប៊ានសួរនាំអ្វីដែរ ដំបូងឡើយ គឺផ្ញើទៅជូនមនុស្សពីរនាក់ ប៉ុន្តែក្រោយមកគឺផ្ញើទៅកាន់តែម្នាក់។ ដូច្នេះ ខ្ញុំគិតថា ប្រហែលជាគាត់ត្រូវបានគេផ្លាស់ចេញហើយ ឬក៏គេដកហូតតួនាទីនោះចេញ ឬក៏គេដកគាត់ទៅទីណាក៏ខ្ញុំមិនដឹងដែរ”។

[១០:០៥:០០]

ខ្ញុំនឹងអានផ្នែកមួយទៀត ដើម្បីបញ្ចប់។ នៅពេលនោះ តើលោកដឹងថាអ្នកណាជាអ្នកផ្លាស់ វន វ៉េត ដែរឬទេ?” ចម្លើយ៦២៖ “ខ្ញុំមិនដឹងទេ”។ សំណួរបន្ទាប់ទៅទៀត៖ “តើលោកធ្លាប់ឃើញ វន វ៉េត ទៀតដែរឬទេ?” ចម្លើយ៦៣៖ “ខ្ញុំបានឃើញគាត់ពីមុន ប៉ុន្តែចាប់ពីពេលដែលខ្ញុំចូលមកធ្វើការក្នុងធនាគារមិនដែលឃើញគាត់ទៀតទេ”។ តើលោកនៅចាំទេលោកសាក្សី ល្អុត តើលោកបានឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេតថា គាត់បាន-- លោកបានឮថាគេបានដកហូតគាត់ ប៉ុន្តែលោកមិនប៊ានសួរ វ៉ាន់ រិទ្ធ ទេពីរឿងហ្នឹង?

**ឆ៖** បាទ ខ្ញុំសូមរក្សាកំណត់ហេតុហ្នឹងទាំងស្រុង។ មិនបាច់បញ្ជាក់អីថែមទៀតទេ គឺថាខ្ញុំរក្សាដែលអ្វីដែលព្រះរាជអាជ្ញាមាន ខ្ញុំរក្សាហ្នឹង។ ខ្ញុំបាទគ្មានអ្វីបន្ថែមបន្ថយទៀតទេបាទ។

[១០:០៦:០៨]

**ស៖** អរគុណលោកច្រើន។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម លោកប្រធាន ដើម្បីសន្សំពេលវេលានោះ ខ្ញុំនឹងគ្រាន់តែអាននូវលេខនូវឯកសារមួយចំនួនដែលបានពិភាក្សា នៅក្នុងផ្នែកនោះដែលទាក់ទង គឺខែវិច្ឆិកា រហូតដល់ឆ្នាំ-- ខែធ្នូ ឆ្នាំ១៩៧៨ គឺឯកសារមួយចំនួនដែលយើងពិនិត្យមើលនោះគឺយើងមាន D161/1.7 ឯកសារហ្នឹង គឺ D279/6.14 បាទគឺខែវិច្ឆិកា ឆ្នាំ៧៨។ ហើយឯកសារ D161/1.31 គឺឯកសារទី១០ ខែវិច្ឆិកា ឆ្នាំ៧៨គឺនិយាយអំពីបញ្ជីរាយនាមគ្រឿងបន្លាស់ គឺឯកសារ D279/6.2 ថ្ងៃទី២៦ ខែ១១ ឆ្នាំ១៩៧៨ គឺៗការនាំចូលគ្រឿងបន្លាស់មកពីប្រទេសយូហ្គោស្លាវី។ ហើយជាថ្មីម្តងទៀត គឺយើងនឹងទៅមុខឲ្យលឿននោះគឺខ្ញុំសូមកត់ត្រានៅក្នុងកំណត់ត្រារបស់តុលាការ ហើយឯកសារហ្នឹង គឺបានបង្ហាញសាក្សីហើយ។ ហើយខ្លឹមសារស្របទៅតាមកំណត់ត្រា ដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះផងដែរ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត ខ្ញុំចង់បង្ហាញជូនលោកនូវឯកសារមួយទៀត ដែលលោកបានពិភាក្សាជាមួយអ្នកស៊ើបអង្កេតមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត គឺថ្ងៃទី៣ ធ្នូ ឆ្នាំ១៩៧៨ ដែលជាកិច្ចប្រជុំរបស់កម្ពុជាប្រជាធិបតេយ្យជាមួយគណៈប្រតិភូចិន។ ហើយដើម្បីឲ្យទៅតាមលំដាប់លំដោយនៃពេលវេលា កាលនោះខ្ញុំសូមអនុញ្ញាតពិនិត្យជាដំបូង បង្ហាញជូនលោកជាដំបូង ឯកសារចុះថ្ងៃទី២ ខែធ្នូ ដែលលោកបានពិភាក្សាជាមួយអ្នកស៊ើបអង្កេត។

[១០:០៨:៥៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវឯកសារ D279/7.11។ នេះជាកំណត់ហេតុអង្គប្រជុំមួយ ដែលគេបានបង្ហាញជូនសាក្សីហើយបានចង្អុលបង្ហាញថា គាត់បានចូលរួមនៅក្នុងកិច្ចប្រជុំនេះ គឺនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨។ ខ្ញុំសូមលោកប្រធាន ដើម្បីបង្ហាញជូនឯកសារនេះទៅសាក្សីបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១០:១០:០០]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្មុត តើលោកស្គាល់ឯកសារនេះទេ? តើលោកនឹកឃើញថាបានពិភាក្សាលើឯកសារនេះជាមួយអ្នកស៊ើបអង្កេតដែរឬទេ?

**លោក សគីម ល្មុត៖**

**ឆ៖** បាទ បានបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតលោកប្រធាន ខ្ញុំសូមបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ និងទាំងលើអេក្រង់ទូរទស្សន៍ផងដែរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ជាឯកសារសរសេរដោយផ្ទាល់ដៃទេ ប្រហែលជាពិបាកអានបន្តិច លោក ល្មុត តើលោកបើយើងពិនិត្យមើលទំព័រទីមួយ។ ឯកសារនេះបង្ហាញថា នេះគឺជាអង្គប្រជុំរវាងសមមិត្ត អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេស ហើយនិងគណៈប្រតិភូពាណិជ្ជកម្មមកពីសាធារណរដ្ឋប្រជាមានិតចិន បាទនៅថ្ងៃទី២ ខែ១២ ឆ្នាំ១៩៧៨ ហើយខ្ញុំអានបន្ទាត់មួយ "អ្នកចូលរួមជាមួយសមមិត្ត អៀង សារី នោះគឺមាន សេង ទុំ, សាន, អន ហើយនិង ល្មុត ផងដែរ"។ តើលោកនៅចាំទេថា លោកបានចូលរួមនៅក្នុងការប្រជុំនោះ?

[១០:១១:៥៨]

**លោក សគីម ល្មុត៖**

**ឆ៖** បាទ តាមពិតខ្ញុំមិនចាំទេ។ ប្រជុំនុ៎ងវាយូរហើយ ហើយដល់បានឃើញឯកសារហ្នឹងមកខ្ញុំថា ខ្ញុំក៏ទទួលថាបានចូល។ ហើយថាមុនហ្នឹង ខ្ញុំមិនចាំទេ ពីព្រោះដូចជាចម្លែកដែរ ព្រោះថាលោក អៀង សារី គាត់ជាក្រសួងការបរទេស ហើយសម្រាប់តែប្រជុំជាមួយនែ៎ គណៈប្រតិភូអីនែ៎! ពាណិជ្ជកម្ម។ ខ្ញុំវាស្រពិចស្រពិលដែរពេលនុ៎ង ខ្ញុំ តាមពិតមិនចាំថា បាន ឬមិនបានទេ។ ប៉ុន្តែដល់ឃើញឯកសារ

នោះ ខ្ញុំក៏មិនបដិសេធដែរ។ ហើយត្រង់ថា អ្នកសរសេររបាយការណ៍នេះ ខ្ញុំមិនដឹងជាអក្សរដៃ មិនដឹងអ្នកណាគាត់សរសេរដែល ហើយខ្ញុំមិនចាំថាពេលបានឲ្យនេះ អានេះឲ្យខ្ញុំអានទេ ព្រោះគេប្រជុំ គេអ្នកធ្វើរបាយការណ៍ គេធ្វើទៅ ហើយក៏មិនបានយកមកឲ្យខ្ញុំអានអីវិញដែរ។

[១០:១៣:២១]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតដើម្បីបង្ហាញឯកសារនៅលើអេក្រង់ គឺថាមានចំណារផ្ទាល់ដៃ ដែលខ្ញុំចង់អានដើម្បីឲ្យលោកនឹកឃើញ នៅចាំឡើងវិញដែរឬទេ។ បាទ លោក ល្អុត គឺថានៅខាងឆ្វេងដៃខាងលើ ខ្ញុំនឹងអានដើម្បីសន្សំពេលវេលា "បងជាទីគោរព សូមផ្ញើគម្រោងកំណត់ហេតុនេះ ដែលរៀបចំឡើងដោយលោក ល្អុត ដើម្បីជូនជាព័ត៌មានជ្រាបជូនបង គឺ បាទ នៅខេ បាទ ក-៥១ ៣/១២"។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** តើលោកនៅចាំទេថា លោកជាអ្នករៀបចំកំណត់ហេតុនោះ? ជាអ្នកធ្វើសេចក្តីព្រាងនោះបាទ?

**លោក សគីម ល្អុត៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនបានព្រាងធ្វើកំណត់ហេតុនេះទេ ហើយអក្សរនេះ ក៏មិនមែនអក្សរខ្ញុំដែរ ហើយក្នុងហ្នឹងឃើញមាននិយាយអីណាទៅ ស្អីឯណា ឈ្លានពានអីណា ខ្ញុំមិនដឹងរឿងអីទេ អាហ្នឹងអត់ដឹង។ ហើយនៅក្នុងចំណងជើងគេដាក់ថា "បងជាទីគោរព សូមផ្ញើកំណត់ហេតុ-- អ៊ូ!គម្រោងកំណត់ហេតុនេះ ដែលបងល្អុត បានកត់ត្រាយកជូន-- មកជូនបង ដើម្បីៗ (ដូចមិនសូវដាច់) ដើម្បី បងមិនច្បាស់ ដូចជា ជ្រាបជាព័ត៌មាន និងមតិណែនាំដោយគោរព ក-៥១។ ថ្ងៃ០៣ ខែ១២"។ អានេះខ្ញុំបដិសេធ ខ្ញុំមិនបាន--

[១០:១៥:៣៥]

**ស៖** សូមអរគុណ។ លោកសាក្សី លោកបាននិយាយថា លោកមានការភ្ញាក់ផ្អើលដែលបានឃើញលោក អៀង សារី ចូលរួមក្នុងកិច្ចប្រជុំនោះ ហេតុអ្វីក៏លោកមានការភ្ញាក់ផ្អើលកាលនោះនោះ?

**ឆ៖** ការភ្ញាក់ផ្អើលនេះគ្រាន់ជាការគិតក្នុងខ្លួនខ្ញុំទេ ពីព្រោះថា កន្លងមករឿងៗកិច្ចការពាណិជ្ជកម្មហ្នឹងដូចមិនដែលឃើញ មិនដែលឮថាគាត់ចូល ហើយទើបតែលើកនេះ គាត់ធ្វើជាប្រធានខាងៗនែប្រធានគណៈប្រតិភូខ្មែរនេះ។ ខ្ញុំគ្រាន់តែឆ្ងល់នឹងអីចេះទេ។ ប៉ុន្តែមិនហ៊ានសន្និដ្ឋានថា យ៉ាងម៉េចៗទេ។

ហើយខ្ញុំទៅនេះ គ្រាន់ថា តែកាលណាមានរឿងពាណិជ្ជកម្ម គេឲ្យខាងខ្ញុំនេះ ខាងធនាគារក៏មានមុខដែរ ហើយ។ ប៉ុន្តែក៏មិនមែនមានមុខនោះ ទៅនិយាយពីរឿងនេះ រឿងនោះទេ គ្រាន់តែថាមានមុខក្នុងអង្គប្រជុំហ្នឹង។ ហើយដូចថា របាយការណ៍នេះ វែងណាស់ ហើយខ្ញុំមិនដឹងជាស្ទើមិន គឺថាវានិយាយអំពីក្រៅពីរឿងពាណិជ្ជកម្មទៀត។ មើលទៅខ្ញុំមិន--។

[១០:១៧:០៥]

**ស៖** សូមអរគុណលោកសាក្សី។ លោកនិយាយថា លោកបានចូលរួមក្នុងការប្រជុំ ហើយលោកអាចនឹងបានចូលរួមក្នុងនាមធនាគារ។ ផ្អែកទៅតាមការងារពិសោធន៍ ឬក៏ការងាររបស់លោកកាលនោះ ថាតើនេះជាការប្រជុំដ៏សំខាន់ ជាការប្រជុំថ្នាក់លើ ថ្នាក់ខ្ពស់ ឬក៏កម្រិតណាដែរ? សូមលោកបញ្ជាក់ប្រាប់តុលាការផងបាទ។

**ឆ៖** ខ្ញុំអាចនិយាយបានថា ជាការងារប្រជុំសំខាន់ហើយពីព្រោះថ្នាក់ខាងខ្មែរយើង ខាងភាគីកម្ពុជាប្រជាធិបតេយ្យមានទាល់តែរដ្ឋមន្ត្រីក្រសួងការបរទេសប្រធាន ហៅថា អាចចាត់ទុកជាសំខាន់ណាស់ តាមយោបល់ខ្ញុំ។

[១០:១៨:១៤]

**ស៖** អរគុណលោកច្រើន។ ឥឡូវខ្ញុំសូមអនុញ្ញាតទៅរកកំណត់ហេតុមួយទៀតនៃអង្គប្រជុំដែលប្រជុំជាមួយគណៈប្រតិភូចិន ដែលធ្វើឡើងនៅបន្ទាប់ នៅថ្ងៃបន្ទាប់នោះលោក ល្អុត បាទ។ ហើយយើងខ្ញុំនឹងឲ្យលោកបញ្ជាក់ផងដែរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ឯកសារបន្ទាប់ហ្នឹង គឺថ្ងៃទី០៣ ធ្នូ ឆ្នាំ១៩៧៨ គឺលេខ E3/828 បាទ។ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សី ហើយអ្នកស៊ើបអង្កេតបានបង្ហាញជូនគាត់ ហើយបានកាលណោះ គឺឯកសារនេះ គឺដាក់លេខថា D279/710 ហើយសូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារនេះជូនលោកសាក្សីពិនិត្យបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិយកទៅជូនសាក្សីពិនិត្យ!

[១០:១៩:៤៥]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត តើលោកនៅនឹកឃើញដែរឬទេ ថាបានឃើញ-- ថាបានពិភាក្សាឯកសារនេះជាមួយអ្នកស៊ើបអង្កេតនោះ?

**លោក សគីម ល្អុត៖**

**ឆ៖** បាទ ខ្ញុំបានទទួលឯកសារនេះពេលដែលអ្នកស៊ើបអង្កេតធ្វើការ បាទ។ ខ្ញុំបានៗឃើញ។

**ស៖** ដូច្នេះការប្រជុំនេះគឺធ្វើឡើងមួយថ្ងៃបន្ទាប់ពីការប្រជុំចុងក្រោយ ដែលយើងបានពិភាក្សាអម្បាញ់មិញនេះ។ តើលោកអាចពិនិត្យមើលទំព័រចុងក្រោយ។ បាទ លោកសាក្សី គឺទំព័រចុងក្រោយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតតុលាការដើម្បីបង្ហាញលើអេក្រង់ផងដែរ និងទូរទស្សន៍ គឺបាទ គឺ D279/7.10 គឺយកទំព័រចុងក្រោយបំផុតបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត និងឲ្យបុគ្គលិកពាក់ព័ន្ធបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ និងលើអេក្រង់ទូរទស្សន៍ផង!

**លោក អាប់ឌុលឡាក់ ថារីក៖**

នៅពេលដែលយើងកំពុងរង់ចាំនេះ--

[១០:២១:១៣]

**លោក អាកទួរ វែកកែន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោក អាកទួរ វែកកែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ដូចតទៅនេះ ខ្ញុំគិតថា ដូចមិនមានផលប្រយោជន៍អីទេ នៅពេលដែលសួរសំណួរពាក់ព័ន្ធទៅនឹងពេលវេលាដែលថាស្គាល់ឯកសារ ឬមិនស្គាល់។ ព្រោះថាវាមានរយៈពេលច្រើនឆ្នាំមកហើយ បន្ទាប់ពីអង្គហេតុ។ ដូច្នេះសាក្សីគាត់មិនអាចកំណត់អំពីឯកសារនេះបានទេ។

**ប្រធានអង្គជំនុំ៖**

ជំទាស់គ្មានប្រសិទ្ធភាព។ នីតិវិធីនេះយើងបានអនុវត្តជាបន្តបន្ទាប់មកហើយ គឺឯកសារដែលសាក្សីបានជួបប្រទះ និងបានមើលអាន ធ្លាប់អានកន្លងមកគឺភាគីពាក់ព័ន្ធអាច ប្រសិនបើយល់ឃើញថាមានប្រយោជន៍ក្នុងការដេញដោល អាចលើកមកដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះបាន។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១០:២២:២២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នេះគឺជាលោកសាក្សី ទំព័រចុងក្រោយ។ ចំណុចនេះចង្អុលបង្ហាញថា ដូច្នេះខ្ញុំនឹងអានជូនលោកស្តាប់។ ផ្ញើនៅភ្នំពេញ ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៧៨ ផ្ញើជូន បងវ៉ាន់ មួយច្បាប់ បងហែម មួយច្បាប់ ក-៥១ មួយច្បាប់ ហើយនិងឯកសារពីរច្បាប់។ បាទនៅក្នុងអេក្រង់ គឺនៅខាងឆ្វេងដៃខាងក្រោមបាទ។ ការប្រជុំដែលយើងពិនិត្យមើលគឺថា មួយថ្ងៃបន្ទាប់ពីការប្រជុំកម្រិតខ្ពស់ដែលលោកអៀង សារីបានចូលរួមនោះឯង។ តើលោកបានចូលរួមការប្រជុំមួយនេះទេ តាមអ្វីដែលលោកចាំមកដល់ពេលនេះនោះបាទ?

**លោក សគីម ល្មុត៖**

**ឆ៖** ខ្ញុំមិនចាំទេបាទ។

**ស៖** បាទ មិនអីទេ។ ថាតើហេតុអ្វីដែលឯកសារនេះ ត្រូវបានបញ្ជូនទៅឲ្យ បងវ៉ាន់ ហើយនិង បង ហែម នោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! អ៎! តំណាង-- សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន នេះគឺជា ៗការសួរឲ្យសាក្សីគាត់ស្មាន ដោយសារគាត់មិនបានឃើញឯកសារនេះពីមុនទេ ដូច្នេះហើយគាត់ក៏មិនបានចូលរួមក្នុងកិច្ចប្រជុំ។ ហើយយើងមិនអាចសួរគាត់ ឲ្យគាត់សន្និដ្ឋានថាហេតុអីបានជាគេបញ្ជូនឯកសារនោះទៅបុគ្គលដែលទទួល ដែលដូចមាន បងវ៉ាន់, បងហែម នេះ។

[១០:២៤:៣៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំយល់ស្របជាមួយនឹងមេធាវី គឺថាគាត់មិនចូលរួមកិច្ចប្រជុំនេះមែន ប៉ុន្តែគាត់បានចូលប្រជុំនៅក្នុងការប្រជុំផ្សេងៗទៀត ក្នុងនាមធនាគាររបស់កម្ពុជាប្រជាធិបតេយ្យ ហើយគាត់បានចូលរួមអង្គប្រជុំជាមួយលោក អៀង សារី នៅក្នុងគណៈប្រតិភូកម្ពុជា ហើយគាត់បានរៀបរាប់ថា នោះគឺជាកិច្ចប្រជុំថ្នាក់ខ្ពស់ នេះគឺជាការប្រជុំមួយបន្ទាប់ពី ដើម្បីតាមដានការប្រជុំខាងដើមនោះ។ ហើយខ្ញុំនឹងយោងទៅរកកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ ក៏បានយោងទៅខ្លឹមសារនេះដែរ។ ដូច្នេះជាការសមស្របដែលថា ដើម្បីសួរគាត់ឲ្យគាត់បញ្ជាក់ការសង្កេតថា តើឯកសារហ្នឹងវាជាការប្រជុំហ្នឹងគឺជាការប្រជុំតាមដានការ-- នៃប្រជុំថ្នាក់ខ្ពស់ដំបូងដែរឬអត់? អ៊ីចឹងសាក្សីគាត់នៅក្នុងជំហរមួយដែលគាត់អាចបញ្ជាក់បានលោកប្រធាន។

[១០:២៥:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា គ្មានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញាចុងក្រោយអម្បាញ់មិញនេះ។ ប្រសិនបើសាក្សីនៅចងចាំសំណួរ។

**លោក សគឹម ល្មុត៖**

ម្តងទៀត។

**ប្រធានអង្គជំនុំ៖**

ទំនងជាគាត់ភ្លេចហើយ សូមលោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរនេះ ចុងក្រោយអម្បាញ់មិញនេះសាជាថ្មី!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សំណួរនោះចង់សួរលោកសាក្សីថា ហេតុអ្វីក៏កំណត់ហេតុ ឬក៏របាយការណ៍នេះត្រូវបានបញ្ជូនទៅ បងវ៉ាន់ និង បងហែម បាទ?

**លោក សគឹម ល្មុត៖**

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់ពីហេតុអ្វីទេបាទ។

**ស៖** ដោយហេតុថាយើងបានឃើញរបាយការណ៍មួយចំនួនច្រើន ដែលត្រូវបានបញ្ជូនទៅបង ហែម និង វន ពីដើមនោះ ឥឡូវនេះគឺយើងឃើញរបាយការណ៍នេះលើកនេះបញ្ជូនមកបង វ៉ាន់ និងបង ហែម បាទ។ ផ្អែកតាមបទពិសោធន៍របស់លោកកាលនោះ តើលោកអាចសន្និដ្ឋានអ្វីបានទេ ទាក់ទងថា ហេតុអ្វីបានជាពេលនេះរបាយការណ៍គេបញ្ជូនទៅបង វ៉ាន់ និង បង ហែម តែមិនមានបង វន ទៀតទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ ព្រោះសំណួរដែលបំណងឲ្យសាក្សីធ្វើសេចក្ដីសន្និដ្ឋាន។ សំណួរនេះយើងបានប្រាប់តាំងពីដើមមក គឺមិនអនុញ្ញាតឲ្យតាំងសំណួរ បំណងឲ្យសាក្សីឆ្លើយតប បង្ហាញពីការយល់ដឹងអត្តនោម័តិរបស់ខ្លួនចំពោះ--

មន្ត្រីរដ្ឋបាលតុលាការរកមើលថ្មឲ្យ--

[១០:២៨:៣២]

សំណួរអម្បាញ់មិញនេះរបស់តំណាងសហព្រះរាជអាជ្ញា គឺសាក្សីមិនចាំបាច់ឆ្លើយទេ ពីព្រោះ សំណួរនេះ សំណួរបំណងឲ្យលោកសាក្សីឆ្លើយធ្វើជាសេចក្ដីសន្និដ្ឋាន បង្ហាញពីគំនិតអត្តនោម័តិរបស់ ខ្លួន។ សាក្សីគ្មានភារកិច្ចធ្វើសេចក្ដីសន្និដ្ឋានឡើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ឥឡូវនេះខ្ញុំចូលទៅក្នុងកំណត់ហេតុស្ដាប់ចម្លើយមួយផ្សេងទៀត។ យោងទៅតាមពេលវេលានេះ លោកប្រធាន ថាតើគួរឲ្យខ្ញុំបន្តសួរសំណួរបន្តទៅទៀត ឬក៏អាចសម្រាកសិន?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការ សវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្រួលសម្រួល និងផ្តល់កន្លែងសមរម្យដល់សាក្សី ហើយនិងឲ្យអញ្ជើញ គាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅម៉ោងបានកំណត់។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣០នាទី ដល់ម៉ោង ១០:៥០ នាទី)*

[១០:៥០:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ដើម្បីគោលបំណងកាលវិភាគ ដើម្បីជួយដល់មេធាវីការពារក្តី គឺថាយើង ហើយយើងនឹងបន្តការសួរដេញដោលរបស់យើងថ្ងៃនេះ។ ហើយបន្ទាប់មក គឺថាសូមការអនុញ្ញាតពីតុលាការ ដើម្បីប្រគល់វេទិការទៅឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្ត។

ខ្ញុំគិតថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងប្រើពេលមួយថ្ងៃកន្លះ។ ដូច្នេះ សូមជម្រាបដល់ភាគី មេធាវីការពារក្តីឲ្យបានជ្រាប ថាតើលោកពួកគាត់យល់ដូចម្តេចអំពីការរៀបចំនេះបាទ?

[១០:៥២:១៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ហើយសូមជម្រាបសួរផងដែរ លោក សគីម ល្អុត។ ខ្ញុំនឹងចូលទៅដល់ប្រធានបទមួយថ្មី។ លោកនៅចាំទេ នៅថ្ងៃព្រហស្បតិ៍ ថ្ងៃទី៣១ នៃខែឧសភា យើងបានបង្ហាញលោកមើលឯកសារមួយចំនួន និយាយអំពីការនាំចេញផលិតកសិកម្ម ពីកម្ពុជាប្រជាធិតេយ្យដែលយើងយោងទៅរកការនាំចេញនោះ។ ហើយខ្ញុំបានសួរលោក ថាលោកចាំដែរឬទេ អំពីបរិមាណនៃទំនិញនាំចេញនោះ ហើយលោកបាននិយាយថា លោកមិនចាំទេនៅពេលនោះ។ លោកបាននិយាយថា ប្រសិនបើ ខ្ញុំអាចជ្រាបបាន-- បើឃើញឯកសារពីប្រធានបទនោះ គឺថាលោកអាចបំភ្លឺ ឬក៏អាចជួយបានបន្ថែមទៀត។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវឯកសារមួយចំនួន ដើម្បីឲ្យលោកសាក្សីអាចជួយបំភ្លឺដល់តុលាការ ឬក៏សហព្រះរាជអាជ្ញានោះ។ ឯកសារទីមួយ គឺ D366/7.1.487។ ហើយខ្ញុំជម្រាបថា ឥឡូវនេះ មិនទាន់បានពិភាក្សានៅក្នុងការសម្ភាសន៍របស់គាត់ទេ ជាមួយសាក្សី ទាក់ទងទៅនឹងកំណត់ត្រារបស់ក្រសួងពាណិជ្ជកម្ម ប៉ុន្តែឥឡូវនេះ ខ្ញុំសូមអនុញ្ញាតបង្ហាញគាត់ ដើម្បីថាតើគាត់អាចជម្រាបតុលាការបន្ថែមអ្វីក្រៅពីលើឯកសារដែរឬអត់បាទ?

[១០:៥៤:០៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ជាបឋម ឲ្យមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារនេះ ពីតំណាងសហព្រះរាជអាជ្ញាជូនទៅសាក្សីពិនិត្យជាមុនសិន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត សូមលោកមើលឯកសារនេះ ហើយតើលោកប្រាប់ខ្ញុំបានទេ តើលោកបានឃើញឯកសារហ្នឹង ពីមុនទេ? ឬក៏បានឃើញកំណត់ត្រាប្រហាក់ប្រហែលហ្នឹង គឺដើម្បីប្រតិចារឹកគឺថា គឺរបាយការណ៍និយាយអំពីស្រូវឆ្នាំ១៩៧៧ ដែលចេញដោយក្រសួងពាណិជ្ជកម្ម?

**លោក សគីម ល្អុត៖**

**ឆ៖** បាទ លោកប្រធាន ខ្ញុំមិនដែលបានឃើញរបាយការណ៍នេះទេបាទ។ ខ្ញុំមិនដែលបានឃើញទេបាទ។

**ស៖** តើលោកបានឃើញតារាងបញ្ជីអ្វីស្រដៀងនេះទេ តាមការងាររបស់លោក ដែលនិយាយអំពីបញ្ជីទំនិញផ្សេងៗ ដែលយើងបានពិភាក្សាពីសប្តាហ៍មុន។ តើអាហ្នឹងវាប្រហាក់ប្រហែលទេទៅនឹងឯកសារផ្សេងៗដែលលោកបានឃើញនោះ?

**ឆ៖** ឯកសារផ្សេងៗ ដូចខ្ញុំមិនឃើញមានស្អីប្រហាក់ប្រហែលហ្នឹងដែរ ដូចនេះ មិនដែលឃើញមានទេបាទ អត់ទេបាទ។

[១០:៥៦:០០]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ ដកឯកសារអម្បាញ់មិញនេះពីសាក្សីវិញ ត្រឡប់មកវិញ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត ឥឡូវនេះយើងនឹងបង្ហាញជូនឯកសារមួយទៀត ដើម្បីឲ្យលោកពិនិត្យមើលថាតើលោកអាចជួយជម្រាបតុលាការបានទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

ឯកសារនេះលោកប្រធាន គឺ D161/1.32 គឺជាលិខិតមួយដែលផ្ញើជូនទៅស្ថានទូតយូហ្គោស្លាវីដែលរហូតបាទ ដែលបញ្ជាក់អំពីការដឹកទំនិញមួយចំនួន។ សូមអនុញ្ញាតតុលាការ ដើម្បីបង្ហាញឯកសារ

នេះជូនទៅលោកសាក្សី គឺ D161/1.32 បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ជាបឋម មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារនេះ ពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

[១០:៥៧:៣២]

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោក ល្មុត តើលោកបានចាំទេថាលោកបានឃើញឯកសារនេះ ឬក៏មានឯកសារណាស្រដៀងនឹងឯកសារនេះដែរឬទេ ក្នុងការងាររបស់លោកនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ នៅក្នុងផ្នែកពាណិជ្ជកម្ម ឬក៏ធនាគាររបស់លោកនោះ?

**លោក សគឹម ល្មុត៖**

**ឆ៖** លោកប្រធានបាទ ខ្ញុំមិនដែលធ្លាប់បានឃើញឯកសាររបៀបនេះទេបាទ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន ខ្ញុំនឹងបង្ហាញជូនសាក្សីនូវឯកសារមួយទៀត ដើម្បីឲ្យលោកសាក្សីពិនិត្យមើលថាតើលោកបានឃើញដែរឬអត់ គឺឯកសារ IS16.24។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត! ជាបឋម មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ IS16.24 ពីតំណាងសហព្រះរាជអាជ្ញា យកទៅជូនសាក្សីពិនិត្យ ហើយនិងដកវិញនូវឯកសារ D161/1.32!

[១០:៥៩:១៤]

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោកមើលឯកសារនេះ ថាតើលោកអាចជម្រាបតុលាការបានអ្វីខ្លះពីការយល់ដឹងរបស់លោក?

**លោក សគឹម ល្មុត៖**

**ឆ៖** បាទ លោកប្រធាន ខ្ញុំក៏មិនធ្លាប់បានឃើញឯកសារនេះដែរបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ ដកហូតឯកសារអម្បាញ់មិញនេះ ចុងក្រោយ IS16.24 ពីសាក្សីវិញ!

លោកតំណាងអយ្យការ គួរតែត្រូវបានជ្រើសរើសនូវឯកសារមកដេញដោល ឲ្យមានមូលដ្ឋានដែលនឹងអាចធានាថាសាក្សីធ្លាប់បានពិនិត្យ និងបានឃើញនូវឯកសារដែលលោកមានបំណងលើកមកយកដាក់ដេញដោលនេះ ចៀសវាងចំណាយពេលវេលា ខ្ជះខ្ជាយពេលវេលាឥតប្រយោជន៍។ បើសិនជាលោកមិនជ្រើសរើស ចេះតែលើកមកដោយមិនបានពិចារណាអំពីភាពពាក់ព័ន្ធនៃឯកសារ អំពីលទ្ធភាពនៃសាក្សីដែលអាចឆ្លើយបំភ្លឺបាននោះ នឹងអាចចំណាយពេលវេលាច្រើនឥតបានការទេ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំព្យាយាមដើម្បីឲ្យសាក្សីគាត់អាចមើលដើម្បីថា តើគាត់អាចពន្យល់អ្វីដែលឬទេ ទាក់ទងទៅនឹងឯកសារមួយចំនួនទាក់ទងនឹងការនាំចេញ ប៉ុន្តែខ្ញុំចូលទៅប្រធានថ្មីមួយទៀត។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត តើលោកស្គាល់បុគ្គលម្នាក់ឈ្មោះ កុយ ធួន ដែរឬទេ? តើគាត់ជានរណា? គាត់មានតំណែងជាអ្វីបាទ?

**លោក សគីម ល្អុត៖**

**ឆ៖** លោកប្រធានបាទ ខ្ញុំមិនធ្លាប់ស្គាល់គាត់ទេបាទ។

[១១:០១:៣២]

**ស៖** បាទ មិនអីទេ។ ដូច្នេះ ប្រសិនបើយើងត្រឡប់ទៅរកឯកសារមួយដែលយើងបានពិភាក្សានៅសវនាការចុងក្រោមកាលពីសប្តាហ៍មុន ថ្ងៃ៣១ ខែឧសភា ដែលសហចៅក្រមស៊ើបអង្កេតបានបង្ហាញជូនលោកកាលពីដំណាក់កាលស៊ើបអង្កេតនោះ។ ខ្ញុំកត់សម្គាល់ថា លោកបានបញ្ជាក់ថា លោកមិនបានចូលរួមក្នុងកិច្ចប្រជុំនោះទេ ប៉ុន្តែលោកស្គាល់មនុស្សមួយចំនួនដែលមានឈ្មោះនៅលើកំណត់ហេតុនោះ។ នេះគឺជាកំណត់ហេតុនៃសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ចុះថ្ងៃ១៩ ដល់ ២១ ខែមេសា ឆ្នាំ១៩៧៦ ដែលមានលេខ E3/235។ គឺជាឯកសារដែលគេបានបង្ហាញជូនសាក្សីក្នុងការសម្ភាសទីពីរនៅពេលនោះបានចុះលេខ D279/7.1។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រមអាចនឹងនឹកឃើញអំពីចំណុចនេះគឺថា ផ្នែកមួយនៃឯកសារនេះគឺមានការយោងទៅរកឈ្មោះសាក្សីរូបនេះ។ ហើយខ្ញុំសូមអនុញ្ញាតតុលាការដើម្បីបង្ហាញឯកសារនេះជូន

លោកសាក្សីផងដែរបាទ។

[១១:០៣:០៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ជាបឋម មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សី ដើម្បីពិនិត្យ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្មុត តើលោកនឹកឃើញទេ នេះគឺជាឯកសារមួយដែលយើងបានពិភាក្សា។ ហើយលោកបាននិយាយថា លោកមិនបានចូលរួមនៅក្នុងការប្រជុំនោះទេ ប៉ុន្តែលោកស្គាល់មនុស្សខ្លះនៅក្នុងឯកសារនោះ។ តើលោកនៅចាំទេថាយើងបានពិភាក្សាឯកសារនេះកាលពីសប្តាហ៍មុន?

**ឆ៖** បាទៗ ទទួលស្គាល់បាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ ប្រសិនបើយើង-- បាទ សូមអនុញ្ញាត ដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ គឺថាជាពិសេសបញ្ចាំងទំព័រលេខមួយនៃឯកសារនេះបាទ។

[១១:០៥:២២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកដែលពាក់ព័ន្ធសូមបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ និងទាំងអេក្រង់ទូរទស្សន៍ផងដែរ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

ដូច្នេះ យើងនឹងពិនិត្យមើលនៅលើអេក្រង់កុំព្យូទ័រ។ បាទ អាចជាបញ្ហាបច្ចេកទេស ប៉ុន្តែយើង--ខាងប្រព័ន្ធសោតទស្សន៍គាត់ពិបាកបញ្ចាំងបន្តិច។

**ស៖** សូមអរគុណ។ យើងបានពិភាក្សាអំពីបញ្ហាគណៈកម្មាធិការពាណិជ្ជកម្មហ្នឹងបានល្អិតល្អន់ លោក ល្មុត ឥឡូវនេះ យើងនឹងពិភាក្សាដោយសង្ខេបអំពីសមាសភាពនៅថ្នាក់ខាងលើនៃគណៈកម្មា-ធិការនោះ។ហើយយើងបង្វិលទៅខាងមុខនៅក្រោម អ៊ំ! នៅលើទំព័រទីមួយ នេះ គឺថាមានបញ្ជីសមាជិកនៃគណៈកម្មាធិការពាណិជ្ជកម្ម។ ហើយដើម្បីអានផ្នែកហ្នឹង ដើម្បីកត់ត្រាតុលាការ ទីមួយ អំពីការរៀបចំចាត់តាំងគណៈកម្មាធិការផ្សេងៗ គឺនៅជុំវិញ ៨៧០ យើងមានសមមិត្ត វិទ្ធ ដែល លោកសាក្សី

ស្គាល់។ ហើយយើងឃើញសមមិត្ត ញ៉ែម ហើយនិងសមមិត្ត ឈឿន។ លោក ល្មុត តើលោកនៅនឹកឃើញដែរឬទេ? សមមិត្ត ឈឿន តើសមមិត្ត ឈឿន នេះ ជាអ្នកណា? គាត់ធ្លាប់ធ្វើអ្វីដែរ?

[១១:០៦:៥៩]

**ឆ៖** បាទ ខ្ញុំមិនធ្លាប់ស្គាល់ទេបាទ។ ក្នុងហ្នឹងខ្ញុំស្គាល់តែសមមិត្ត រិទ្ធ ម្នាក់ទេ។

**ស៖** យើងត្រឡប់ទៅខាងមុខនៅក្នុងឯកសារ ទៅក្នុងផ្នែកមួយដែលយើងបានមើលពីសប្តាហ៍មុនដែរ គឺថា ដែលចាប់ផ្តើមពីលេខរ៉ូម៉ាំងបួន ដែល--

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរ លោកប្រធាន គឺថានៅលេខរ៉ូម៉ាំងបួន។ បាទ សូមខាងប្រព័ន្ធសោតទស្សន៍មេត្តាបង្ហាញលើអេក្រង់ ខ្ញុំនឹងផ្តោតទៅលើផ្នែកដែលពាក់ព័ន្ធនេះ គឺៗនៅខាងក្រោមទំព័រលេខប្រាំ និងដើមទំព័រលេខប្រាំមួយ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** យើងបានមើលផ្នែកនេះហើយកាលពីមុននោះ លោក ល្មុត។ នៅក្នុងលេខពីរ ទាក់ទងទៅនឹងគណៈប្រតិភូពាណិជ្ជកម្មចិន មានសេចក្តីសម្រេចក្នុងការរៀបចំទទួល និងចរចាជាមួយគណៈប្រតិភូនោះដែលមានសមមិត្ត ឌឿន, សមមិត្ត គ្រិន ជាបុគ្គលម្នាក់ទៀតដែលលោកបានរៀបរាប់ថា ជាប្រធានកំពង់ផែ ហើយសមមិត្ត សី អ៎! សមមិត្ត សាយ ហើយបន្ទាប់មកគឺ សមមិត្ត ឈឿន ហើយនៅខាងចុងបន្ទាត់នេះ គឺសមមិត្ត ល្មុត។ ដូច្នេះ តើលោកនៅនឹកឃើញទេ? ដែលលោកបានទទួលការចាត់តាំងឲ្យនៅក្នុងគណៈកម្មការប្រតិភូខាងកម្ពុជាមួយ ដើម្បីធ្វើការជាមួយគណៈប្រតិភូចិន នោះដែរឬទេ?

[១១:០៩:០៣]

**លោក សគឹម ល្មុត៖**

**ឆ៖** បាទ ខ្ញុំចាំ តែមិនចាំថ្ងៃខែណាទេបាទ។ ពេលនុ៎ងចាំថា មានសមមិត្ត ឌឿន ហ្នឹងដូចជាៗប្រធានគណៈប្រតិភូ ចាំអ៊ីចឹងបាទ។

**ស៖** តើលោកនឹកឃើញទេ ថាតើសមមិត្ត ឈឿន ហ្នឹងគាត់មានបញ្ហាអ្វីដែរទេ បន្ទាប់ពីការចរចា ឬក៏បន្ទាប់ពីប្រជុំនោះមកនោះ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ បាទ។

[១១:១០:០៤]

**ស៖** សូមអរគុណ។ ដើម្បីកត់ត្រាប្រតិចារឹកឲ្យបានត្រឹមត្រូវ ចម្លើយសារភាពរបស់ ឈឿន នៅក្នុង ស-២១ នោះគឺ IS5.104។ លោក ល្អុត យើងនឹងត្រឡប់មួយជំហានថយក្រោយទៅវិញ នៅក្នុងគណៈកម្មាធិការនោះ គឺនៅទំព័រមួយ ហើយយើងនិយាយឃើញថា សមមិត្ត រិទ្ធ, សមមិត្ត ញ៉ែម ហើយនិងសមមិត្ត ឈឿន។ បាទ តើលោកនៅនឹកឃើញដែរឬទេ? សមមិត្ត ញ៉ែម ហ្នឹងជានរណា? តើលោកធ្វើការជាមួយគាត់ដែរឬទេ? តើគាត់-- លោកបានជួបគាត់ទេ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** សូមបញ្ជាក់ថា ទាំងសមមិត្ត ញ៉ែម, ឈឿន នេះខ្ញុំមិនដែលធ្វើការទាក់ទងអ្វីជាមួយអស់លោកទាំងហ្នឹងទេ គឺធ្វើតែជាមួយលោក រិទ្ធ ដែលគាត់-- ជាក់ស្តែងគឺថា រិទ្ធ ហ្នឹងទេបាទ។ ពីរនាក់ទៀតគឺមិនដែលទាក់ទងគ្នាធ្វើការអ្វីផ្សេងៗទៀតទេបាទ។

[១១:១១:១៦]

**ស៖** សូមអរគុណ។ ហើយមុននឹងយើងបញ្ចប់ពីបញ្ហាសមមិត្ត ញ៉ែម នេះគឺថា ឈ្មោះ ញ៉ែម នេះគឺមាននៅក្នុងបញ្ជីស-២១ គឺឯកសារ D288/6.68.1 គឺ ERN 00330065 លេខចុះបញ្ចូលគឺ ១០៨០។ លោក ល្អុត យើងបានឃើញនៅក្នុងផ្នែកមួយដែលលោកបានពិភាក្សាជាមួយអ្នកស៊ើបអង្កេតបាទឬក៏នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ទាក់ទងទៅនឹងការដកចេញ ឬក៏ការបាត់ខ្លួន វន់ វ៉េត។ លោកបាននិយាយថា លោកមិនប៉ានសួរ វ៉ាន់ រិទ្ធ អំពីបញ្ហារបស់គាត់នោះទេ។ តើលោកបានដឹងទេ នៅកាលនោះអំពីការបាត់ខ្លួនរបស់មនុស្សផ្សេងៗទៀត របស់មនុស្សដែលលោកបានធ្វើការនៅក្នុងក្រសួងពាណិជ្ជកម្មហ្នឹង ក្រៅពីឈ្មោះដែលយើងនិយាយអំមិញនេះ?

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេ ប៉ុន្តែក្រៅពីនុ៎ង មានតែ មានម្នាក់ធ្វើការជាបុគ្គលិក ជាអ្នកបកប្រែដែរនៅក្រសួងពាណិជ្ជកម្ម ឃើញដូចជាគេដកយកទៅ គេថាឈប់ឲ្យធ្វើការទៅ។ តែខ្ញុំក៏មិនដឹងជាជោគវាសនារបស់គាត់យ៉ាងម៉េចដែរទេ។ ក្រៅពីនុ៎ងខ្ញុំអត់ដឹងទេ។

[១១:១៣:១៩]

**ស៖** តើនៅពេលនោះ លោកយល់ដូចម្តេចទេ នៅកាលនោះគឺថា បើមានមនុស្សបាត់ខ្លួនពីកន្លែងធ្វើការ ពីមន្ទីរ តើលោកយល់ដូចម្តេច? តើលោកមានអារម្មណ៍ដូចម្តេចកាល់នុ៎ងនោះ?

**ឆ៖** គឺថាមានអារម្មណ៍បារម្ភអីចឹងដែរ មិនដឹងជាថា ទៅឯណាទីនេះទេ គឺថាដូចជានៅពាណិជ្ជអីចឹងមានម្នាក់យក គឺថា យកចេញទៅ ខ្ញុំក៏មិនដឹងទៅណាដែរ។ ហើយឃើញថាផ្ទាល់ខ្លួនក៏មានការ

ព្រួយបារម្ភដែរ។

[១១:១៤:១០]

**ស៖** ថាតើលោកដឹងទេថា អ្នកណាជាអ្នកដកហូតមនុស្សដែលបាត់ខ្លួនហ្នឹងទៅនោះបាទ?

**ឆ៖** ខ្ញុំមិនដឹងដែរទេបាទ។

**ស៖** តើលោកធ្លាប់ជជែកគ្នាអំពីការបាត់ខ្លួនបែបនេះជាមួយលោក វ៉ាន់ រិទ្ធ ដែរឬទេ ដែលជាប្រធានរបស់លោកដូចកាលនោះ?

**ឆ៖** សូមបញ្ជាក់អ៊ីចេះគឺថា លោក វ៉ាន់ រិទ្ធ នេះមិនមែនជាប្រធានខាងខ្ញុំទេ គឺថា មិនមែនជាប្រធានខាងធនាគារពាណិជ្ជកម្មក្រៅប្រទេសហ្នឹងទេ។ ហើយក៏ៗ មិនដែលជជែកជាមួយគាត់អំពីថាអ្នកណាបាត់ អ្នកណាអីណាក៏មិនដែលជជែកជាមួយគាត់ដែរ។

**ស៖** លោកនិយាយថា លោកផ្ទាល់ខ្លួនហ្នឹងមានការព្រួយបារម្ភអំពីឃើញមនុស្សបាត់ខ្លួន ចុះលោកអាចសង្កេតបានទេកាលណោះ ថាតើអ្នកដែលធ្វើការជិតៗលោកនោះ លោកបានពិភាក្សាជាមួយពួកអ្នកនោះទេ អំពីបញ្ហាដែលថាមានមនុស្សបាត់ខ្លួននោះណា?

**ឆ៖** បាទ ខ្ញុំអត់មានការជជែកអីជាមួយអ្នកណាផ្សេងទៀតទេបាទ។

**ស៖** ខ្ញុំសូមបង្ហាញជូនលោកនូវឯកសារមួយលោក ល្មុត ដើម្បីឱ្យលោកជួយជម្រាបខ្ញុំ និងតុលាការបានឬទេ។ នេះគឺជាសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្មចុះថ្ងៃទី១៧ តុលា ឆ្នាំ១៩៧៦។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ឯកសារ E-- អ៊ំ! D108/26.27។ សូមអនុញ្ញាតតុលាការដើម្បីបង្ហាញឯកសារនេះជូនសាក្សីជាមុនសិនបាទ។

[១១:១៧:១២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ជាបឋមមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

ដើម្បីបញ្ជាក់ ដើម្បីបានកំណត់ត្រាតុលាការ គឺថាចំណងជើងឯកសារនេះ គឺឯកសាររបស់ក្រសួងពាណិជ្ជកម្ម គណៈកម្មាធិការក្រសួងពាណិជ្ជកម្មបន្ទាប់ពីស្នើសុំមតិយោបល់ពីផ្នែក និងក្រសួង

ផ្សេងៗគឺសម្រេចចិត្តចាប់ខ្លួន និងបញ្ជូនមនុស្សមួយចំនួនទៅមន្ទីរសន្តិសុខ ដើម្បីសួរចម្លើយ ហើយនិងវិធានការបន្ត។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត តើលោកបានធ្លាប់បានឃើញឯកសារនេះពីមុនដែរឬទេ? ឬក៏ឯកសារនេះលោកប្រហាក់ប្រហែលឃើញស្រដៀងហ្នឹងដែរឬទេ?

**លោក សគីម ល្អុត៖**

**ឆ៖** លោកប្រធាន បាទ មិនដែលឃើញឯកសារនេះទេ ហើយក៏មិនដែលឃើញឯកសារអីដែលប្រហាក់ប្រហែលនេះ គឺថាមិនដែលឃើញទាល់តែសោះ។

[១១:១៨:២៧]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទៅដកយកឯកសារអម្បាញ់មិញនេះចេញពីសាក្សីវិញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំនឹងបង្ហាញឯកសារលោកសាក្សីមួយទៀត អំពីប្រធានបទនេះវាខុសគ្នាបន្តិចពីខាងដើម។ ខ្ញុំសូមអនុញ្ញាតុលាការ ដើម្បីឲ្យលោកសាក្សីជួយខ្ញុំ គឺថាលោក លោកស្រីចៅក្រម គឺនេះជាឯកសារ D366/7.1.159 គឺជាឯកសារចុះថ្ងៃទី១៧ តុលា ឆ្នាំ១៩៧៦។ សូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារលើក្រដាសទៅលោកសាក្សី ដើម្បីឲ្យលោកឆ្លើយថាលោកស្គាល់ ឬមិនស្គាល់បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ជាបឋម មន្ត្រីរដ្ឋបាលតុលាការទទួលជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាជូនទៅឲ្យសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

ដូចឯកសារមុនដែរគឺថា ដើម្បីកំណត់ត្រាតុលាការនោះ គឺថាមិន-- ឯកសារនោះនិយាយថា បន្ទាប់ពីការពិភាក្សាផ្នែកផ្សេងៗ គណៈកម្មាធិការក្រសួងពាណិជ្ជកម្មសម្រេចចិត្តបញ្ជូនមនុស្សដូចខាងក្រោមនេះ ដើម្បីទៅទទួលការអប់រំកែប្រែ។ ហើយលោក ល្អុត លោកសាក្សី តើលោកអាចស្គាល់ ឬធ្លាប់ឃើញឯកសារបែបនេះដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំបាទមិនដែលឃើញ ឬក៏ធ្លាប់ឯកសាររបៀបនេះទេបាទ។ មិនដែលឃើញទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ មន្ត្រីរដ្ឋបាលតុលាការដកហូតយកឯកសារចុងក្រោយអម្បាញ់មិញនេះពីសាក្សីត្រឡប់មកវិញ។ អង្គជំនុំជម្រះសូមរំឭកតំណាងសហព្រះរាជអាជ្ញាសាជាថ្មីម្ដងទៀត សូមតំណាងសហព្រះរាជអាជ្ញាពិនិត្យ និងការជ្រើសរើសនូវឯកសារឯណាដែលមានបំណងដាក់ដេញដោលចំពោះសាក្សី នូវឯកសារណាដែលទំនង ឬក៏មានភស្តុតាង ទំនងអាចបញ្ជាក់បានថា សាក្សីធ្លាប់បានដឹង បានស្គាល់ បានអានឯកសារនោះពីមុនមក មិនគប្បីលើកយកឯកសារព្រាវៗយកមកដាក់បង្ហាញដូច្នេះទេ។ ទីពីរ រំឭកឡើងវិញថា សាក្សីនេះ មិនមែនធ្វើការនៅក្នុងក្រសួងពាណិជ្ជកម្មទេ គាត់នៅធនាគារ ដែលជាផ្នែកមួយដាច់ដោយឡែកពីគេ។

[១១:២១:១១]

ប្រសិនបើធ្វើដូច្នោះ គឺថាពេលវេលា ចំណាយពេលវេលាច្រើន ហើយប្រសិនបើអស់សំណួរហើយ គឺគួរតែត្រូវបានបញ្ឈប់ការសួរ បញ្ចប់ការសួររបស់ខ្លួនទៅ។ មិនមែនពេលវេលាដែលស្នើសុំហ្នឹង គឺប្រឹងប្រែងធ្វើឲ្យអស់ ទោះបីសំណួរដដែលៗ ហើយយកឯកសារដែលមិនពាក់ព័ន្ធយកមកបង្ហាញឯកសាររបៀបនេះក៏ដោយនោះ ចេះតែធ្វើនោះទេ។ សង្ឃឹមថា តំណាងសហព្រះរាជអាជ្ញានឹងមានការគិតគូរពិចារណាអំពីបញ្ហានេះ ឲ្យបានល្អសាជាថ្មីម្ដងទៀត។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ជម្រាបថា យើងមិនដឹងថា តើសាក្សីបានដឹង ឬមិនដឹងនោះទេ ពីព្រោះថា ដោយគាត់ធ្វើការនៅ-- មានទំនាក់ទំនងជាមួយក្រសួងនោះ។ យើងខ្ញុំយល់ថា គាត់អាចនឹងជួយបាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ដូច្នេះ ខ្ញុំសួរបន្តទៀត លោក ល្មុត លោកបានធ្វើការជាមួយ វ៉ាន់ រិទ្ធ។ គឺលោកបានចូលរួមប្រជុំជាមួយលោក វ៉ាន់ រិទ្ធ ហ្នឹងមួយចំនួនដែរ។ លោកមិនបានឃើញឯកសារទាំងអម្បាលមាណ ដូចដែលលោក-- ខ្ញុំបញ្ជូនលោកទេ ប៉ុន្តែខ្ញុំសួរទៀត ថាតើលោកដឹងថា មានការសម្រេចរបស់ក្រសួងពាណិជ្ជកម្មក្នុងការបញ្ជូនមនុស្សមួយចំនួនទៅមន្ទីរសន្តិសុខដែរឬទេ?

[១១:២២:៥២]

**លោក សតឹម ល្អុត៖**

**ឆ៖** ខ្ញុំមិនបានទេបាទ។ មិនបានចូលរួមអីសម្រេចពីរឿងបញ្ជូនអ្នកណា ទៅណាមកណាទេ ព្រោះអាហ្នឹងជារឿងរបស់ក្រសួងពាណិជ្ជកម្ម ហើយគ្មានរឿងនឹងឲ្យខាងខ្ញុំនេះទៅៗចូលរួមមានមតិ ព្រោះខ្ញុំមិនទាំងស្គាល់អស់លោកទាំងហ្នឹងផង។ ពិតមែនតែនៅជាប់គ្នា វិទ្ធ- វ៉ាន់ វិទ្ធ មែន ក៏ការងារគាត់ការងារខ្ញុំ ហើយខ្ញុំដឹងខ្លួនថាមិនត្រូវជ្រៀតជ្រែក ត្រូវឈ្មុសឈ្មុលដឹងការងារគេទេ គឺថាដើម្បីជាសន្តិសុខផ្ទាល់ខ្លួន ត្រូវឲ្យដាច់។ អាហ្នឹងខ្ញុំជា-- អាកប្បកិរិយាខ្ញុំអ៊ីចឹង។ អរគុណ។

**ស៖** សូមអរគុណ។ យើងជឿជាក់ថា លោកបានប្រាប់យើងអំពីអ្វីៗដែលលោកអាចចាំបានដឹងបាន ហើយមានចេតនានឹងជម្រាបខ្ញុំ និងតុលាការឲ្យបានដឹង។ ខ្ញុំសូមអនុញ្ញាតបន្តទៅប្រធានបទមួយទៀត ហើយខ្ញុំចង់បញ្ជាក់ជាមួយលោកថា យើងយល់ឲ្យច្បាស់ទាំងអស់គ្នាអំពីសេចក្ដីសម្រេច ឬក៏មុខងាររបស់លោក ហើយនិងអ្វីៗដែលលោកបានជួបប្រទះពីឆ្នាំ១៩៧៦ ដល់៧៨។ ពីសប្ដាហ៍មុន បាទដល់ ៧៩ ហើយលោកបាននិយាយថា លោកជាប្រធានធនាគារកម្ពុជាប្រជាធិបតេយ្យ ថាតើមុខងារហ្នឹង តើលោកធ្វើការភ្លាមៗ បន្ទាប់ពីត្រឡប់មកពីជម្លៀសហ្នឹង មកភ្នំពេញក្នុងឆ្នាំ១៩៧៦ ឬក៏មួយរយៈពេលខ្លី មុននឹងចាប់ផ្ដើមការងារនោះ?

[១១:២៤:៤៧]

**ឆ៖** សូមបញ្ជាក់ថា ធនាគារនោះ ហើយមិនមែនជាធនាគារជាតិ ដូចយើងធនាគារមានសព្វថ្ងៃនេះទេ ព្រោះសម័យនោះ អត់ចាយលុយទេ។ ហើយគេដែលបង្កើតពេលនោះ គឺហៅធនាគារពាណិជ្ជកម្មក្រៅប្រទេស សម្រាប់តែទាក់ទងខ្លះទៅនឹងការលក់ដូរអីវ៉ាន់ទៅក្រៅទេ ទិញដូរទេគេត្រូវការឯកសារខ្លះធ្វើទៅ ប៉ុន្តែខ្ញុំបញ្ជាក់ថា មិនមែនជាធនាគារជាតិ ដូចយើងដែលស្គាល់រាល់ថ្ងៃនេះទេ ហើយដែលខ្ញុំយកពីសហករណ៍មកក៏-- មកដល់ភ្លាមក៏ៗមិនទាន់មានការបង្កើតអីដែរ ដល់តែមានជួបជាមួយគណៈប្រតិភូចិនហើយ គេណែនាំថា គួរមានធនាគារសម្រាប់ធ្វើឯកសារនាំចេញនាំចូលបានក៏បង្កើត ហើយបង្កើតហ្នឹងទៀត ក៏វាមានតែលើក្រដាសទេ។ ហេតុអ្វីក៏ខ្ញុំថាអ៊ីចឹង? ពីព្រោះថា ធនាគារហ្នឹង ទីមួយខ្ញុំបញ្ជាក់ថា ខ្ញុំមិនដឹងជាមានទុនប៉ុន្មានទេ។ ហើយអ្នកដែលធ្វើការហ្នឹងគេដាក់ថា មាន-- ថ្នាក់ដឹកនាំមានអគ្គនាយក ឬក៏ថាប្រធានអ៊ីចឹង។ អគ្គនាយកហ្នឹងដាក់ឈ្មោះ ម៉ី អីមិនដឹង ខ្ញុំមិនចាំទេ។ ខ្ញុំចាំតែនាមត្រកូល ម៉ីៗ ហើយគេជាយើងថា អគ្គនាយក ឬក៏ប្រធានអ៊ីចឹងចុះ ហើយដាក់ឈ្មោះខ្ញុំនេះជា

នាយករង ហើយទាំងពីរនាក់ហ្នឹង មិនដែលជួបមុខគ្នាទេ ខ្ញុំមិនដែលឃើញមុខប្រធានហ្នឹងមុខមាត់ម៉េចទេ។ ហើយធនាគារហ្នឹងមានតែម្នាក់ ហើយខ្ញុំសួរថាតើខ្ញុំធ្វើអីទៅ? មានអីធ្វើអីគ្មានគណនេយ្យ គ្មានអី គ្មានបុគ្គលិកអីទេ ពេលនោះរូបភាពធនាគារនោះវាអ៊ីចឹង។ ខ្ញុំជម្រាបបានតែប៉ុណ្ណឹងទេបាទ។

[១១:២៦:៥០]

**ស៖** លោកមិនបានសំណួរខ្ញុំទាំងស្រុងនោះទេ ប៉ុន្តែនៅដំណាក់កាលណាមួយ កាលបរិច្ឆេទណាដែលៗលោកស្មាន ឬក៏លោកចាំច្បាស់ទេ ដែលគេចាត់តាំងឲ្យលោកធ្វើជាអនុប្រធានធនាគារហ្នឹងនោះបាទ?

**ឆ៖** បាទ ខ្ញុំមិនចាំថ្ងៃខែទេបាទ ព្រោះដូចខ្ញុំនិយាយដដែលៗ វាសាមសិបប្រាំ-- សាមសិបជាងហើយ គឺគ្មានឯកសារអីនៅនឹងមុខផង ហើយខ្ញុំមិនអាចចាំបានទេបាទ។ អាចក្នុង៧៦ ហ្នឹង ឬក៏កណ្តាលឆ្នាំចុងឆ្នាំ ខ្ញុំក៏មិនចាំច្បាស់ទេបាទ។

**ស៖** សូមអរគុណ។ បាទ ឥឡូវនេះយើងនិយាយថា សង្ខេបអំពីភស្តុតាង ដែលលោកបានផ្តល់សក្ខីកម្មអស់រយៈពេលពីរថ្ងៃកន្លងមកនេះ លោកបានប្រាប់ខ្ញុំថា លោកបានចូលរួមកិច្ចប្រជុំ ពេលខ្លះលោកចូលរួមជាអ្នកបកប្រែទេ ហើយថ្ងៃនេះពេលខ្លះលោកចូលរួមក្នុងឋានៈជា ជាអ្នកសមាជិកអង្គប្រជុំកាលណាគេនិយាយពីបញ្ហាធនាគារ ឬក៏ហិរញ្ញវត្ថុ។ តើអ៊ីចឹងវាឆ្លុះបញ្ចាំងពីគំនិតដែលលោកបញ្ជាក់ដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន ប៉ុន្តែសូមបញ្ជាក់ថា ពេលដែលទៅចូលរួមជាសមាជិកទាំងអស់-- គណៈប្រតិភូហ្នឹងក៏ចូលអ៊ីចឹងក៏មិនដែលមានមតិអីដោយឡែកដែរ លើកលែងតែគេសួរពន្យល់ថា រឿងបច្ចេកទេសពិធីធ្វើម៉េចៗអាហ្នឹងណាបានមាននិយាយ។ តែភាគច្រើនគ្រាន់តែទៅអង្គុយស្តាប់អ៊ីចឹងទេ បាទហើយរឿងបកប្រែរឿងផ្សេងបាទ។

[១១:២៩:១៣]

**ស៖** សូមអរគុណ។ តើលោកនៅឆ្នាំដែរឬទេ ថាលោកបានចូលរួមការប្រជុំណាមួយជាមួយគណៈប្រតិភូអន្តរជាតិ ឬក៏បរទេស ឬក៏គណៈប្រតិភូផ្សេងដែលលោកជាប្រធាន នៃគណៈប្រតិភូដែរឬទេ ធ្លាប់មានអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ មិនដែលមានទេបាទ។

[១១:២៩:៥៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

ហើយយើងពិនិត្យមើលការចងចាំរបស់លោកសាក្សី។ លោកប្រធាន ខ្ញុំសូមបង្ហាញអនុញ្ញាត បង្ហាញសាក្សីនូវឯកសារមួយគឺលេខ D366/7.1.341។ ឯកសារនេះ គឺជារបាយការណ៍នៃការជួបជាមួយគណៈប្រតិភូកូរ៉េ ចុះថ្ងៃទី៥ ខែ១០ ឆ្នាំ១៩៧៨។

ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារនេះជូនសាក្សីពិនិត្យបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

ជាបឋមមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ នៅពេលដែលឯកសារកំពុងតែពិនិត្យមើលទៅលើឯកសារនេះគឺដើម្បីជាការកត់ត្រាក្នុងប្រតិចារឹក គឺនិយាយអំពីការ-- ដើម្បីជូនទៅដល់សមមិត្តវៀន នៅថ្ងៃទី៥ តុលា ៧៨ នៅម៉ោង-- ចាប់ពីម៉ោងប្រាំបីព្រឹក រហូតទៅដល់ម៉ោងដប់ព្រឹក នៅគណៈកម្មាធិការពាណិជ្ជកម្ម។ ហើយឃ្លាបន្ទាប់មក គឺយើងខាងភាគីកម្ពុជាមាន សមមិត្ត ល្មុត, សមមិត្ត ប៉ែន, និងសមមិត្ត ស្នួន។

[១១:៣១:៣២]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្មុត លោកស្គាល់ឯកសារនេះទេ? ហើយលោកនៅចាំ ថាលោកបានចូលរួមនៅក្នុងកិច្ចប្រជុំនេះទេ?

**លោក សគឹម ល្មុត៖**

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេ ហើយឯកសារនេះ ខ្ញុំមិនដែលឃើញផង។ ហើយបើមើលតាមខ្លឹមសារទៅនេះ គឺថាខាងកម្ពុជាមានដាក់សមមិត្តល្មុត, ផន និង ស្នួន។ ផន និងស្នួន តាមខ្ញុំស្រពេចស្រពិលប្រហែលជាថ្នាក់ អាដែងពាណិជ្ជកម្ម ថ្នាក់តូចទេ។ ហើយសមមិត្តកូរ៉េមាន ទីប្រឹក្សាពាណិជ្ជកម្ម លេខាទីបី ដូច្នេះក៏ជាថ្នាក់តូចដែរ។ ន៎ស តាមខ្ញុំចាំគឺថាគឺសុទ្ធតែថ្នាក់តូចៗទេ ហើយជជែកពីគ្នាពីរឿងអីខ្ញុំមិនទាន់បានអានទេ មិនដឹងជជែករឿងអីទេ បើទុកពេលឲ្យខ្ញុំអានមើល ខ្ញុំអាចនឹង អាចបំភ្លឺបានខ្លះ។ ហើយខ្ញុំមិនចាំថា ខ្ញុំទៅធ្វើជាប្រធាន ហើយបើរឿងវាអ៊ីចឹងមែនក៏ប្រជុំអ្នកតូចតាច ខាងក្រោម។

ហើយខ្ញុំនេះ គេចាត់ទុកជាអ្នកតូចតាចទេ មិនមែនជាអ្នកធំអីនៅនុ៎ងទេ។ សូមបញ្ជាក់ប៉ុណ្ណឹងសិនបាទ។

[១១:៣៣:១៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ លោកប្រធាន តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកាលពីសប្តាហ៍មុន យើងខ្ញុំសូមស្នើបង្ហាញជូនឯកសារណា ដែលសមស្របពាក់ព័ន្ធនៅអេក្រង់កុំព្យូទ័រ ក្នុងករណីណាដែលសាក្សីគាត់មិនបដិសេធថា គាត់បានចូលរួមប្រជុំនោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ ខ្ញុំសូមបង្ហាញជូននូវទំព័រទីមួយ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត យើងខ្ញុំមិនមានចំណាប់អារម្មណ៍ពាក់ព័ន្ធទៅនឹងការពិភាក្សាជាលម្អិតនោះទេ។ យើងខ្ញុំគ្រាន់តែចង់យល់ដឹងពីទំនាក់ទំនងរបស់លោកជាមួយក្រសួងពាណិជ្ជកម្ម ហើយនិងតួនាទីរបស់លោកនៅក្នុងកិច្ចប្រជុំបែបនេះ។ កថាខណ្ឌទីមួយ ខ្ញុំសូមអានកថាខណ្ឌទីមួយ។ សូមដកស្រង់ "មុននឹងចាប់ផ្តើមពិភាក្សាអំពីបញ្ហាពាណិជ្ជកម្ម បន្ទាប់ពីបានសួរសុខទុក្ខគ្នាទៅវិញទៅមក យើងខ្ញុំបានជម្រាបសមមិត្តកូរ៉េថា ដោយសមមិត្ត វ៉ាន់ រិទ្ធ ជាប់បំពេញភារកិច្ចនៅក្រៅភ្នំពេញ។ យើងខ្ញុំទាំងបីនាក់នេះត្រូវបានចាត់តាំងឲ្យមកទទួលមិត្តកូរ៉េនៅថ្ងៃនេះ"។ ឃ្លានេះបញ្ជាក់សំខាន់បំផុតថា គឺលោកត្រូវបានចាត់តាំងឲ្យចូលរួមប្រជុំនេះ ជំនួសសមមិត្ត វ៉ាន់ រិទ្ធ។ តើលោកនៅចាំថា លោកត្រូវបានចាត់តាំងឲ្យចូលប្រជុំជំនួសសមមិត្ត វ៉ាន់ រិទ្ធនៅក្នុងកិច្ចប្រជុំជាមួយនឹងមិត្តកូរ៉េនេះដែរទេ?

**ឆ៖** ខ្ញុំមិនៗច្បាស់លាស់ទេ។ ប៉ុន្តែក៏ ខ្ញុំក៏មិនបដិសេធថាបានប្រជុំទេ តែខ្ញុំមិនច្បាស់ទេ មិនច្បាស់ទេបាទ។ អាចថាលោក វ៉ាន់ រិទ្ធ ហ្នឹងគាត់មិននៅ ឲ្យក៏ខាងនុ៎ងមានបីនាក់ហ្នឹង គឺមាន ខ្ញុំ, ផន ហើយនិង សួន នេះ។ ខ្ញុំមិន ខ្ញុំប្រហែលទេ ប្រហែលជានៅក្នុងពាណិជ្ជកម្មហ្នឹងហើយ ហើយជួបនឹងលេខាទីបី។ ដូច្នេះ ជាថ្នាក់ទាបៗទេនេះ។ ហើយដល់សរសេរនេះ ខ្ញុំមិនដឹងជា ខ្ញុំមិនបានដូចថាត្រៀមរៀបចំសរសេរ សរសេរឲ្យវែរបៀបម៉េច ខ្ញុំដូចជា ខ្ញុំមិនចាំទេបាទ ខ្ញុំមិនចាំទេ។

[១១:៣៦:៣៧]

**ស៖** ថាតើលោកចាំទេ អ្នកណាជាអ្នកចាត់តាំងឲ្យលោកចូលរួមនៅក្នុងកិច្ចប្រជុំនេះជំនួសសមមិត្ត វ៉ាន់ រិទ្ធ នោះ?

**ឆ៖** បាទ ខ្ញុំមិនចាំទេបាទ។ ពិនិត្យទៅៗ ខ្ញុំសូមមើលអានេះ ខាងចុងបន្តិច ខ្ញុំៗចង់មើលបន្តិចបាទ ខ្ញុំសូមទោស។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ដោយសារថាមិនមានការជំទាស់ ខ្ញុំសូមឲ្យសាក្សីគឺថាមើលឯកសារនេះទាំងស្រុងតែម្តង។

*(សាក្សីពិនិត្យមើលឯកសារ)*

[១១:៣៨:៣៩]

**លោក សគីម ល្មុត៖**

**ឆ៖** មើលតាមឯកសារនេះទៅ គឺថា ខាងកូរ៉េ គេលើកថា ចង់ទិញអីៗ។ ហើយដល់របៀបសរសេរនេះ ដូចជាមានអ្នកនៅពីលើខាងយើងខ្ញុំទៀតន៎ែ។ បើសិនជាខ្ញុំធ្វើជាប្រធាន ខ្ញុំមិន-- ខ្ញុំដូចមិនសរសេររបៀបហ្នឹងទេ។ សរសេររបៀប ដូចថាមានអ្នកណានៅពីលើទៅទៀត ប្រជុំហ្នឹង ឬក៏គាត់ធ្វើរបាយការណ៍យ៉ាងម៉េច? ខ្ញុំមិនដឹងដែរ។ ព្រោះជម្រាបដោយត្រង់គឺថា មើលមួយភ្លែតអ៊ីចឹង ខ្ញុំរកៗយល់ឲ្យច្បាស់លាស់ មិនបានទេ ព្រោះថា ម្យ៉ាងវាភ្លេច ម្យ៉ាងគឺការវិភាគក្នុងអង្គប្រជុំធំធេងរបៀបនេះមើលត្រួសៗហើយសន្និដ្ឋានថា អ៊ីចេះ អ៊ីចុះ ខ្ញុំមិនអាចថាបានទេ។ គឺសរសេរហ្នឹង មិនរបៀបជាខ្ញុំសរសេរ ខ្ញុំមិន។ ដូចៗ មើល៍ដូចជាមានអ្នកណាដែលនៅពីលើទៀត សរសេរហ្នឹងណ៎ះ។ ព្រោះសរសេរនិយាយពីរឿងអីណាដែលខ្ញុំមិនដឹងផង។ សុំទោស បាទអស់ហើយ។

[១១:៤០:០០]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកបាននិយាយថា ហាក់បីដូចជាមានអ្នកណាម្នាក់ផ្សេងទៀតជាអ្នកដឹកនាំការប្រជុំនេះ។ តើលោកយល់ស្របជាមួយខ្ញុំទេថា នៅក្នុងនេះគឺលោកត្រូវបានចុះឈ្មោះជាៗអ្នកនាំមុខគេនៅក្នុងខាងភាគីកម្ពុជាក្នុងការដឹកនាំកិច្ចប្រជុំនេះលោកយល់ស្របជាមួយខ្ញុំទេ?

**ឆ៖** ខ្ញុំមិនពិតប្រាកដទេ ព្រោះក្នុងហ្នឹងគេដាក់ថា អ៊ីចេះ ខាងកម្ពុជាមានសមមិត្ត ល្អុត, ផន និង សួន។ ហើយក៏គ្មានដាក់ថាអ្នកណាជាប្រធាន ជាអីដែរ។ ដាក់អ៊ីចឹង ហើយរឿងនេះពាក់ព័ន្ធទៅអីណារឿងលក់កៅស៊ូ លក់អីណា ហើយរឿងអស់ហ្នឹងខ្ញុំសុទ្ធតែអត់ដឹង។ លក់កៅស៊ូ លក់អីហ្នឹងខ្ញុំ ឬក៏ខាងអ្នកណានៅក្នុងពាណិជ្ជហ្នឹងគេនិយាយក៏មិនដឹង ក្នុងពីរនាក់ទៀតនេះ ផន ហើយនិង សួន ហ្នឹងបាទ។ ខ្ញុំមិនដឹងអ្នកណានិយាយដែរទេ ហើយក្នុងហ្នឹងក៏មិនបញ្ជាក់ថា ខ្ញុំជាប្រធានដែរទេ។ ដូច្នេះ រឿងនេះ ខ្ញុំ-- អាចមានប្រជុំអ៊ីចឹង ប៉ុន្តែថាឲ្យខ្ញុំថា ច្បាស់ជាខ្ញុំហ្នឹងជាប្រធានមានសិទ្ធិថា អ៊ីចេះ ថាអ៊ីចុះ ខ្ញុំមិនចាំច្បាស់ទេ ពេលនុំងបាទ។

[១១:៤១:៥៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្តសំណួរថ្មីៗផ្សេងទៀត! ទៅមុខទៀតៗ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត តើលោកយល់ស្របជាមួយខ្ញុំទេថា ការដែលគេចាត់តាំងលោកឲ្យចូលរួមនៅក្នុងកិច្ចប្រជុំនេះ គឺថាក្នុងឋានៈលោកខ្ពស់ជាងអ្នកដទៃក្នុងនេះ បញ្ជាក់ថា លោកមានតួនាទីទទួលខុសត្រូវពាក់ព័ន្ធទៅនឹងតួនាទីរបស់ក្រសួងពាណិជ្ជកម្មនេះ លោកយល់ស្របជាមួយខ្ញុំទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយ!

អញ្ជើញលោកមេធាវីជាតិការពារក្ដីឲ្យលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទ សូមជំទាស់នឹងសំណួរនេះ ដោយសារតំណាងសហព្រះរាជអាជ្ញាសួរសំណួរច្រំដែល ដដែលៗ ហើយសាក្សីបានឆ្លើយរួចហើយអំពីសមាសភាពរបស់លោកនៅ-- ពាក់ព័ន្ធនៅក្នុងការប្រជុំនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់មេធាវីជាតិការពារក្ដីលោក ខៀវ សំផន មានប្រសិទ្ធភាព។ សំណួរនេះ

ពិតជាសំណួរច្រំដែល។

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញាដែលបានសួរលោកអម្បាញ់មិញនេះទេ!

[១១:៤៥:០២]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** បើពិនិត្យមើលទៅឯកសារនេះ លោក ល្អុត! តើលោកអាចរៀបរាប់ការយល់ដឹងរបស់លោក នៅចំពោះកិច្ចការរបស់ក្រសួងពាណិជ្ជកម្មបានប៉ុនណាដែរ? តើលោកអាចរៀបចំចាត់ចែង ឬក៏ថាអាចបកស្រាយ ឬក៏បើមិនដូច្នេះទេ ថាតើឯកសារនេះគឺជាឯកសារពិតតែម្តង ឬយ៉ាងណា?

**លោក សគីម ល្អុត៖**

**ឆ៖** ក្រៅតែពីខ្ញុំបាទ បានជម្រាបហូរហែមកកិច្ចការអ្វីៗដែលចំពោះរបស់គណៈកម្មការពាណិជ្ជនេះ ខ្ញុំមិនអាចបញ្ជាក់បន្ថែមទៀតទេ។ ហើយចំពោះឯកសារ ដូចខ្ញុំជម្រាបអំមិញវា វាមានការស្រពេចស្រពិលដែរ ខ្ញុំមើលទៅ ខ្ញុំឆ្ងល់ខ្លួនឯងដែរ។ ប៉ុន្តែខ្ញុំថា ខ្ញុំមិនប៊ានបដិសេធទេ តែខ្ញុំថា របៀបសរសេរ របៀបអីហ្នឹង ហើយរឿងខ្លះខ្ញុំមិនដឹងផង ក៏សរសេរបីដូចជាខ្ញុំដឹងដែរ។ អានេះខ្ញុំពិបាកវិភាគណាស់ ខ្ញុំមិនៗ អាចបញ្ជាក់ឲ្យៗដាច់ណាត់ថាវាអីចេះ អីចុះទេ។ តែពីរឿងរ៉ាវទាក់ទងជាមួយកូរ៉េនោះ វាមាន ទិញដូរអីចឹងទៅ ទិញនេះលក់នោះ វាមានដូចក្នុងឯកសារហ្នឹងនិយាយមែន ហើយដល់នៅក្នុងហ្នឹង ដូចខ្ញុំនិយាយដដែលៗពីសមាសភាពវាមាន ក្រសួង-- វាមានពីរនាក់ ខ្ញុំសង្ស័យពីខាងពាណិជ្ជគឺរឿងខ្លះគេនិយាយ។ ដូច្នេះ គឺថាខ្ញុំនិយាយដដែលគេមានដាក់ថាខ្ញុំប្រធានទេ វាមាននៅក្នុងហ្នឹងខ្ញុំវាអាចថាអ្នកចាស់ទុំជាងគេ ហើយយល់ដឹងការងារជាងគេ។ ហើយមិនមានការចូលរួមសម្រេចការទទួលខុសត្រូវរឿងទិញនេះ ទិញនោះ លក់ដូរនេះ គឺថាខ្ញុំ ក្នុងឯកសារនេះ ខ្ញុំមានការអឺ-- ស្រពេចស្រពិល ហើយម្យ៉ាងទៀតនៅក្នុងគឺថា មិនដឹងនរណាដែលអ្នកធ្វើទៅនេះ ក្នុងរបាយការណ៍ នរណា? មិនត្រឹមដាក់ មិនដាក់ឈ្មោះផង មិនដឹងនរណាដែលធ្វើរបាយការណ៍ហ្នឹង។

[១១:៤៦:៣២]

**ស៖** ខ្ញុំសូមអរគុណលោក ល្អុត។ លោកបានឆ្លើយតបច្បាស់លាស់ហើយ ជាការពិតហើយថាកិច្ចប្រជុំនេះគឺ ចាប់ទៅប្រជុំនៅថ្ងៃទី០៥ តុលា ៧៨ ហើយដើម្បីជាការកត់ត្រាទៅក្នុងប្រតិចារឹកនោះគឺនៅថ្ងៃ០៦ មករា ៧៩ នោះ គឺរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំទៅ។ នៅពេលនោះ តើលោក

ធ្វើដំណើរទៅទីណានៅថ្ងៃទី០៦ ឬថ្ងៃទី០៧ មករា ៧៩ ហ្នឹង ឬក៏លោកស្នាក់នៅក្នុងទីក្រុងភ្នំពេញ?

**ឆ៖** គឺខ្ញុំស្នាក់នៅភ្នំពេញរហូតដល់ថ្ងៃចុងក្រោយតែម្តង ចុងក្រោយហ្នឹងគឺជម្លៀសខ្លួនទៅនឹងគេ ឯងអ៊ីចឹងទៅ។ អត់មានទៅណាមកណាទេ។

**សៈ** ហើយក្រោយពីពេលនោះមក ក្រោយពីការភៀសខ្លួនចេញពីទីក្រុងភ្នំពេញ តើលោកនៅបន្តធ្វើការជាមួយអ្នកដែលធ្វើការជាមួយលោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យតទៅទៀតដែរឬទេ? ហើយបើលោកនៅបន្តធ្វើការតើលោកមានតួនាទី មានមុខងារជាអ្វីដែរ?

**ឆ៖** លោកប្រធានបាទ ខ្ញុំគិតថាកម្ពុជាប្រជាធិបតេយ្យនុ៎ងវាចប់ត្រឹមថ្ងៃហ្នឹងហើយ ហើយខ្ញុំ-- រឿងតទៅទៀតជារឿងថ្មីមួយទៀត មិនដឹងថាតើខ្ញុំត្រូវតែឆ្លើយឬយ៉ាងម៉េច? ខ្ញុំ ស្រេចតែលោកប្រធានបញ្ជា ឬបង្គាប់។

**ប្រធានអង្គជំនុំ៖**

មិនចាំបាច់ឆ្លើយទេ សំណួរមិនពាក់ព័ន្ធទេ។

[១១:៤៩:១១]

**លោក អាប់ឌុលឡាក់ ថារីក៖**

យើងខ្ញុំគោរពលើសម្រេចនេះ ប៉ុន្តែគោលបំណងនៃការតាំងសំណួរបែបនេះដើម្បីបញ្ជាក់ទៅលើភស្តុតាងចំពោះទំនាក់ទំនងរបស់សាក្សីរូបនេះទៅនឹងមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ។ មុននឹងបញ្ចប់ការតាំងសំណួររបស់ខ្ញុំនោះគឺ ខ្ញុំនឹងមិនសួរសាក្សីចំពោះរឿងហ្នឹងតទៅទៀតទេ ប៉ុន្តែខ្ញុំសួរឯកសារ E3/14.35 ចុះថ្ងៃ១៨ ឆ្នាំ១៩៧៩ ឯកសារពាក់ព័ន្ធ ERN គឺ S000988, ERN ជាភាសាខ្មែរ គឺ 0059274 និងជាភាសាបារាំង 0059820 និយាយអំពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលពេលនោះគឺថា សាក្សីរូបនេះគឺជារដ្ឋលេខាធិការទទួលបន្ទុកខាងការដឹកជញ្ជូន និងគមនាគមន៍។ ខ្ញុំសូមអរគុណអង្គជំនុំជម្រះដែលបានផ្តល់ពេលវេលាបន្ថែមមកលើខ្ញុំ។ ខ្ញុំលែងមានសំណួរអ្វីសួរសាក្សីតទៅទៀតហើយ។ ហើយសូមអរគុណសាក្សី សគឹម ល្មុត ដែលលោកបានឆ្លើយទៅនឹងបណ្តាសំណួរទាំងឡាយរបស់ខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី? មេធាវីទទួលសិទ្ធិ តើក្នុងការសួរដេញដោលសាក្សីរូបនេះទំនងជាចំណាយពេលវេលាប៉ុន្មានទៅ?

[១១:៥១:១៩]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំជម្រាបសួរអស់លោក លោកស្រីចៅក្រមទាំងអស់ ចំពោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺថាយើងត្រូវការប្រហែលជារយៈពេលពីរម៉ោង គឺថារសៀលនេះ គឺថាជាការគ្រប់គ្រាន់ហើយសម្រាប់ពួកយើងទាំងអស់គ្នាក្នុងការចោទសំណួរទៅសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការផ្តល់ដំណឹងនេះ។

ឥឡូវនេះពេលវេលាសមល្មមសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរ-- មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យ សម្រាប់សាក្សីរូបនេះសម្រាកនៅក្នុងអំឡុងពេលអាហារថ្ងៃត្រង់ ហើយនិងអាចអញ្ជើញឲ្យគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទី។

អង្គុយចុះ!

សូមអញ្ជើញលោកមេធាវី!

[១១:៥២:១៨]

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន កូនក្តីរបស់យើងខ្ញុំសូមការអនុញ្ញាតចូលរួមតាមដានដំណើរការនីតិវិធីនៅក្នុងបន្ទប់បំពាក់ប្រព័ន្ធសោតទស្សន៍នៅខាងក្រោមនេះ ហើយយើងខ្ញុំនឹងដាក់សំណើសុំជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះតែម្តង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមតាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ក្រុមមេធាវីការពារក្តីរបស់គាត់បានសន្យាថា នឹងប្រគល់

មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃរបស់ជនជាប់ចោទ នួន ជា។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលដំណើរការសវនាការសម្រាប់រសៀលនេះ។

[១១:៥៣:៥៧]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឲ្យ នួន ជា នៅបន្តតាមដានសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់ចូលរួមសវនាការពីចម្ងាយ។ ដោយឡែកឲ្យនាំខ្លួន ខៀវ សំផន មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី!**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥៥ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយពេលវេលាបន្តទៅនេះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិពីមេធាវីនាំមុខតំណាង

ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម។ ចាស សូមគោរពភាគីដែលបានចូលរួមក្នុងបន្ទប់សវនាការនេះ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

សូមគោរពលោកសាក្សី។ ចាសៗ ខ្ញុំជឿជាក់ថាវត្តមានរបស់លោកសាក្សីថ្ងៃនេះសំខាន់ណាស់ ចាស ពីព្រោះលោកសាក្សីជាសាក្សីមួយឯករាជ្យ។ ចាស ហើយដើម្បីដូចថាស្វែងរកយុត្តិធម៌ដល់ៗ-- ស្វែងរកការពិត និងយុត្តិធម៌។ ចាស ពាក្យថា "ការពិត យុត្តិធម៌" គឺយើងសំដៅទៅលើទាំងជនជាប់ចោទ និងជនរងគ្រោះ។ ចាស ហេតុនេះសូមឲ្យលោកមេត្តាសហការជាមួយយើង ដើម្បីយើងឆ្លើយនូវសំណួរអ្វីដែលលោកបានដឹង ដែលលោកបានឃើញ ហើយដែលលោកបានជួបប្រទះដើម្បីស្វែករកយុត្តិធម៌ទាំងអស់គ្នា។

**ស៖** ចាស ឥឡូវខ្ញុំចង់ជម្រាបសួរលោកថា កាលលោកបានឆ្លើយថា កាលពីថ្ងៃទី៣០ ខែ៥ ឆ្នាំ ២០១២ លោកបានឆ្លើយថា លោកបានចូលក្នុងចលនាតស៊ូនៅក្នុងសម័យសង្គមរាស្ត្រនិយម។ ខ្ញុំចង់ជម្រាបសួរលោកថា តើក្នុងសម័យសង្គមរាស្ត្រនិយម តើប្រហែលជាក្នុងអំឡុងឆ្នាំណាដែរ ដែលលោកចូលចាស?

[១៣:៣២:៤៧]

**លោក សគីម ល្មុត៖**

**ឆ៖** ខ្ញុំមិនចាំឆ្នាំច្បាស់លាស់ទេបាទ វាយូរពេកណាស់ទៅហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាង-- អំលោកមេធាវីការពារក្តី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់ជំទាស់ទេ សូមអភ័យទោស ប៉ុន្តែប្រហែលថាសំណួរនេះគប្បីគ្របដណ្តប់ទៅលើផ្នែកដែលមិនទាន់បានសួររួចហើយ បើមិនដូច្នោះទេ មិនមានអត្ថន័យក្នុងការសួរ

សំណួរដដែលពីរដងបីដង។ ដូច្នេះសូមឲ្យមេធាវីចាប់ផ្ដើមពីចំណុចណា ដែលសហព្រះរាជអាជ្ញាមិនបានសួរ។ អ៊ីចឹងគឺថា ដូច្នោះហើយបើសិនជាមិនធ្វើដូច្នោះទេ សាក្សីរូបនេះបានឆ្លើយសំណួរនេះរួចហើយ។ ខ្ញុំគិតថា យើងគប្បីតែពិចារណាចំណុចនេះ។ សូមលោកប្រធានមេត្តាសម្រេច សូមអរគុណ។

[១៣:៣៣:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការកត់សម្គាល់របស់លោកមេធាវី។ ហើយអង្គជំនុំជម្រះសង្ឃឹមថាភាគីដែលពាក់ព័ន្ធនឹងកិច្ចដំណើរការសវនាការនឹងប្រើប្រាស់ពេលវេលាដ៏មានប្រសិទ្ធភាព ហើយនិងសន្សំសំចៃពេលវេលាបំផុតនៅក្នុងការដេញដោល។ សំដៅធ្វើយ៉ាងណាឲ្យកិច្ចដំណើរការពិភាក្សាដេញដោលរឿងក្ដីនេះឆាប់បានចប់។

ហើយបញ្ហារំឭកមួយទៀតថា គប្បីការតាំងសំណួរធ្វើម៉េចឲ្យញែកឲ្យដាច់រវាងសាក្សី ដែលគាត់មកចំពោះមុខតុលាការនេះក្នុងនាមជាសាក្សី ក្រែងលោជួនការសំណួរខ្លះអាចភ័ន្តច្រឡំ ក្រែងលោច្រឡំថាគាត់ជាជនជាប់ចោទ។ ហាក់ដូចជាដេញដោលសាវតាររបស់គាត់ហ្នឹងច្រើនជាងសាវតាររបស់ជនជាប់ចោទទៅទៀត។ សាវតារហ្នឹង អង្គជំនុំជម្រះបានជម្រាបបឋមរួចហើយ កម្រិតដែលសមរម្យគឺអាចទទួលយកបានហើយ អង្គជំនុំជម្រះបានសួរដេញដោលគាត់តាំងពីដំបូងនៃការប្រាប់សិទ្ធិដល់គាត់នៅពេលដែលគាត់មកដល់ ដែលអាចទទួលយកបានក្នុងកម្រិតអត្តសញ្ញាណសាក្សីនៅចំពោះមុខតុលាការ។

[១៣:៣៤:៥១]

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។ ចាស សំណួរដែលខ្ញុំចង់សួរគាត់ដឹងពីឆ្នាំហ្នឹង ពីព្រោះៗកន្លងមក ខាងសហព្រះរាជអាជ្ញាលោកបានសួរ គឺគាត់បានឆ្លើយតែពីក្នុងសម័យសង្គមរាស្ត្រនិយម។ ហេតុហ្នឹងបានសួរឲ្យគាត់ជួយបញ្ជាក់ឆ្នាំ ចាំ៖។ ចាស មិនថ្វីទេចាស សូមអរគុណ។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស ខ្ញុំសូមសួរលោកបន្តទៀតថា នៅពេលដែលលោកធ្វើការនៅផ្នែកធនាគារ ចាស លោកធ្វើការនៅធនាគារពាណិជ្ជកម្ម ហើយលោកទទួលខាងផ្នែកខាងប្រធាន ទទួលឥណទានកម្ចីមែនទេលោក?

**លោក សគីម ល្មុត៖**

**ឆ៖** បាទ នៅគឺថាក្នុងធនាគារមួយ ដែលមុនសម័យកម្ពុជាប្រជាធិបតេយ្យឯណោះ ធនាគារហ្នឹងបាទ។

**ស៖** ចាស អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកហ្នឹង គឺក្នុងសម័យមុនកម្ពុជាប្រជាធិបតេយ្យហ្នឹង។ ខ្ញុំចង់សួរលោកថា ក្នុងពេលដែលលោកធ្វើជាប្រធានផ្នែកខាងៗឥណទានកម្ចី ខ្ញុំចង់សួរថា តើពេលនោះមានអតិថិជនមកខ្ចីប្រាក់ក្នុងធនាគារហ្នឹងទេ?

[១៣:៣៥:៥៥]

**ប្រធានអង្គជំនុំ៖**

សំណួរហ្នឹង មិនពាក់ព័ន្ធទេ សាក្សីមិនបាច់ឆ្លើយទេ!

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណ។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ខ្ញុំចង់ជម្រាបសួរលោកបន្តទៀត ថានៅពេលដែលលោកចូលបដិវត្តន៍ ចាស លោកៗបានឆ្លើយ លោកបានចូលក្នុងចលនាតស៊ូបដិវត្តន៍ ហើយលោកបានជួយឧបត្ថម្ភថវិកាជាលុយកាក់បន្តិចបន្តួច។ ខ្ញុំចង់សួរថា ក្នុងនាមលោកជាបញ្ញាជន តើលោកយល់បែបណាដែរ ដែលលោកជួយថវិកាដល់បដិវត្តន៍ហ្នឹង?

**លោក សគីម ល្មុត៖**

**ឆ៖** សូមបញ្ជាក់ថា រឿងនេះ ក៏វារឿងមុនកម្ពុជាប្រជាធិបតេយ្យ។ គឺពេលហ្នឹង ចលនាហ្នឹងគេអង្គាសលុយបន្តិចបន្តួច ក៏ជួយទៅ។ មានស្អីធំដុំទេ ហើយខ្ញុំថា គិតថារឿងនេះ វាតាំងពីមុនកម្ពុជាប្រជាធិបតេយ្យ ហើយសម័យហ្នឹង ក៏មិនទាន់និយាយអីពីណា បក្សកុម្មុយនីស្ត បក្សអីណាទេ។ ខ្ញុំចាំអ៊ីចឹង អត់មាននិយាយពី-- ពិតមែនតែរៀនទ្រឹស្តីអីៗ អ៊ីចេះ ប៉ុន្តែថាដូចមិនទាន់ចំហថា បក្សកុម្មុយនីស្តទេ ពេលនុ៎ង គឺនៅគឺថារណសិរ្សជាមួយព្រះករុណាអីអ៊ីចឹង។ ហ្នឹង ខ្ញុំអាចបញ្ជាក់បានប៉ុណ្ណឹងបាទ។

[១៣:៣៧:២៣]

**ស៖** ចាស សូមអរគុណ។ ចាស បន្ទាប់ទៀត ខ្ញុំចង់ជម្រាបសួរលោក ថាក្នុងអំឡុងពេលដែលលោកជួយជាលុយកាក់ ចាស ដល់បដិវត្តន៍ហ្នឹង ពេលនោះ លោកៗបានឆ្លើយកាលពីថ្ងៃទី៣០ ខែ៥

លោកបានឆ្លើយថា លោកបានចូលរួមប្រជុំដែរ ចាសហើយការប្រជុំៗជាសម្ងាត់ ម្តងផ្ទះអ្នកនេះ ម្តងផ្ទះអ្នកនោះ។ ខ្ញុំចង់ជម្រាបសួរថា តើការប្រជុំដែលលោកជម្រាបថាប្រជុំនុ៎ង ប្រជុំនៅភ្នំពេញ ឬក៏ប្រជុំនៅទីណាដែរ?

**ផ៖** ដោយសារតែខ្ញុំធ្វើការនៅភ្នំពេញ គឺប្រជុំនៅភ្នំពេញបាទ។

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំសូមជម្រាបសួរលោកបន្តទៀតថា តើការប្រជុំហ្នឹង គេប្រជុំនិយាយអំពីអ្វីដែរលោក?

**ផ៖** ខ្ញុំចាំមិនច្បាស់ទេ តែតាមធម្មតាច្រើនតែពិនិត្យពីសភាពការរួម ក្នុងស្រុកអីៗអីចឹងៗបាទឲ្យលម្អិត ខ្ញុំមិនចាំទេបាទ។

**ស៖** ចាស សូមអរគុណ។ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកថា លោកស្គាល់លោក វ៉ាន់ រិទ្ធ ច្បាស់មែនទេ?

**ផ៖** បាទ ស្គាល់ច្បាស់បាទ។

**ស៖** ចាស អរគុណ។ លោកស្គាល់លោក វ៉ាន់ រិទ្ធ ច្បាស់។ ពេលនុ៎ង លោកស្គាល់នៅពេលណា? ធ្វើការជាមួយលោក ឬក៏យ៉ាងណាដែរ ដែលលោកស្គាល់នោះ?

[១៣:៣៨:៤៥]

**ផ៖** បាទ ស្គាល់គាត់ តាំងពីពេលគាត់ធ្វើការជាមួយខ្ញុំ ហើយស្គាល់មុនហ្នឹងទៀត គឺថាពីដើមគាត់ជា រៀននៅវិទ្យាល័យស៊ីសុវត្ថិ ហើយខ្ញុំជាសាស្ត្រាចារ្យ ហើយគាត់តាមពិត គាត់ជាកូនសិស្សខ្ញុំ។

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំចង់ជម្រាបសួរលោកបន្តទៀត ថាក្រោយ-- លោកបានឆ្លើយថា លោក វ៉ាន់ រិទ្ធ គាត់ ដូចថាគាត់មានបញ្ហាជាមួយខាង លន់ នល់ គាត់ក៏បានរត់ចូលឲ្យបដិវត្តន៍មែនទេលោក?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ ឆ្លើយ-- លោកសាក្សីឆ្លើយរួចហើយ។ សំណួរច្រំដែល។

មេធាវីប្រយ័ត្នប្រយែងនូវការតាំងសំណួរឲ្យមែនទែន សម្រិតសម្រាំងនូវសំណួរណាដែលមានសក្តានុពល ហើយចៀសវៀងសំណួរច្រំដែល សំណួរដឹកមុខ សំណួរក្រៅអង្គហេតុ ឬក៏សំណួរមិនពាក់ព័ន្ធ ឬក៏សំណួរសុំឲ្យសាក្សីផ្តល់នូវសន្និដ្ឋានជាដើម។ អង្គជំនុំជម្រះនឹងប្រឹងប្រែងខិតខំឲ្យអស់ពី

សមត្ថភាពក្នុងការគ្រប់គ្រង ឲ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ពេលវេលាក្នុងការដេញដោល ចាប់ពីពេលនេះតទៅ។

[១៣:៤០:០១]

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ខ្ញុំចង់ជម្រាបសួរលោកពីការជម្លៀសចេញពីភ្នំពេញ ពីឆ្នាំ៧៥ ដល់៧៩។ លោកបានឆ្លើយជាមួយសហព្រះរាជអាជ្ញាពីម្សិល ពីម្សិលមិញ ក៏ដូចជាពីថ្ងៃម្សិលម៉្ងៃ លោកបានឆ្លើយថា លោកត្រូវបានគេ ប្រាប់លោកឲ្យជម្លៀសចេញពីភ្នំពេញនៅពេលរសៀល គឺដំណើររបស់លោកគឺលោកចេញពីភ្នំពេញ ទៅកៀនស្វាយ។ ខ្ញុំចង់ជម្រាបសួរលោក ហើយលោកបាននិយាយបន្តទៀតថា គោលដៅរបស់លោក គឺលោកមិនមានបំណងទៅកៀនស្វាយទេ គឺលោកបំណងរបស់លោក គឺលោកទៅខេត្តកំពត ហើយលោកបាននិយាយទៀតថា ដោយសារផ្លូវចង្អៀតផង ទីមួយ។ ទីពីរ ដោយសារភាពភ័យខ្លាចរបស់លោក លោកក៏ហួសទៅស្នាក់នៅកៀនស្វាយ។ ខ្ញុំចង់ជម្រាបសួរលោកថា អាភាពភ័យខ្លាចរបស់លោកហ្នឹង គឺលោកចង់មានន័យថា ម៉េចដែរចំា បានជាលោកទៅខុសទិសដៅរបស់លោកហ្នឹងចំា?

[១៣:៤១:០៥]

**លោក សគីម ល្អុត៖**

**ឆ៖** អានេះ ខ្ញុំសូមកែតម្រូវអ៊ីចេះ។ ខ្ញុំមិនបាន ដូចជាមិនបានថា ខ្ញុំភ័យខ្លាចទេ ខ្ញុំគឺថាទិសដៅថា ទៅកំពតហ្នឹងហើយ ប៉ុន្តែត្រូវទៅតាមតាខ្មៅ តែទៅដល់ម្ដុំក្បាលថ្នាក់ហ្នឹង វាចង្អៀតពេក ហើយគេអ្នកនិយាយហ្នឹងគេថា ទៅមិនបានទេ ឥឡូវឡើងទៅតាមស្ពានសិនទៅ ទៅតាមផ្លូវជាតិលេខ១ទៅ។ ទៅដោយសារតែសភាពការណ៍តម្រូវឲ្យទៅ ពេលហ្នឹងមិនទាន់ថា ជាខ្លាចអីយ៉ាងម៉េចៗ គ្រាន់ថា វាចង្អៀតអ៊ីចឹង ហើយគេមិនឲ្យទៅ ក៏មិនទៅៗ។ ទៅក៏ទៅមិនរួច ក៏ឡើងស្ពានហ្នឹង ទៅតិចៗទៅចេះឡើងបាន។ អាហ្នឹងខ្ញុំសូមបញ្ជាក់បំភ្លឺប៉ុណ្ណឹងបាទ។

**ស៖** ចំា សូមអរគុណ។ ចំា លោកបានជម្រាបកាលពីថ្ងៃម្សិលថា លោក ហើយក្រុមគ្រួសារលោក ត្រូវបានជម្លៀសទៅនៅសហករណ៍កៀនស្វាយ។ ខ្ញុំចង់ជម្រាបសួរលោកថា គ្រួសាររបស់លោកពេលនោះ តើអង្គការគេចាត់គ្រួសាររបស់លោកជាគ្រួសារ ជាប្រជាជន១៧មេសា ឬជាប្រជាជនរំដោះ?

[១៣:៤២:១៧]

**ឆ៖** ទៅដល់ពេលនោះគឺថា មិនទាន់ទៅដល់ផ្សារគៀនស្វាយទេ នៅម្តុំហៅថា ភូមិចំប៉ាហ្នឹង។ មិនទាន់មានការចាត់តាំងអី សហករណ៍អី មិនទាន់ច្បាស់លាស់ទេ ហើយទៅដល់នោះក៏មិនមានគេចាត់ថា ខ្ញុំហ្នឹងថា ជាប្រជាជនថ្មីចាស់អីទេ គឺថានៅហ្នឹងមួយសន្ទុះទៅប៉ុន្មានអាទិត្យអីចឹងទៅ គេបង្កើតសហករណ៍ក៏សុំមានបងប្អូនទៅណា សុំនៅហ្នឹងចូលសហករណ៍ហ្នឹងផងទៅ ប៉ុន្តែមិនទាន់មានជាចាត់តាំងច្បាស់លាស់អ្នកណាប្រធាន អ្នកណាអីទេ គឺថានៅក្នុងភាពដូចថា បណ្តោះអាសន្នទើបមួយខែ ប៉ុន្តែនៅដូចច្របូកច្របល់បន្តិចដែរ ហើយក៏សុំគេនៅហ្នឹង ដូចមិនចង់ទៅណាមកណាទៀតទេ គិតនៅហ្នឹងទៅ ហើយក៏នៅហ្នឹងទៅ តែកាលនោះមិនទាន់មានចាត់ថា អ្នកនេះ ប្រជាជនថ្មី អ្នកនេះអីទេ គឺថាពេលនោះមិនទាន់មានអីទេបាទ។

**ស៖** ចា៎ សូមអរគុណ។ ចុះពេលណាទៅ ដែលគេចាត់ជាប្រជាជនចាស់ ប្រជាជនថ្មីហ្នឹង ក្នុងអំឡុងពេលណា? ឆ្នាំណាទៅលោក?

[១៣:៤៣:២៤]

**ឆ៖** ខ្ញុំមិនដឹងច្បាស់ទេ ព្រោះខ្ញុំនៅសហករណ៍ហ្នឹង បានរយៈខ្លីក៏គេមកប្រាប់ថា ខ្ញុំមកនៅសហករណ៍មួយនៅជិតភ្នំពេញនេះ ម្តុំខាងត្បូងស្ទឹងមានជ័យហ្នឹង។ ហើយកន្លែងហ្នឹងក៏ សមាសភាពនៅហ្នឹងវាមានបញ្ញាជន ដែលចេញពីក្រុងទៅ វាមានកម្មករ កម្មកររោងចក្រដែលចេញពីភ្នំពេញទៅ ហើយវាមានកសិករមូលដ្ឋានខ្លះនៅហ្នឹង ប៉ុន្តែក៏មិនមានឃើញថា បែងចែកអីច្បាស់លាស់ ធ្វើការប្រហាក់ប្រហែលតែគ្នា ដូចគ្នាទាំងអស់នៅហ្នឹង។ ហើយដែលកសិករដែលមកនៅហ្នឹងក៏ មិនមែនជាកសិករក្រីក្រទេ គឺថាមានគោ មានក្របីអីមកនៅចូលគ្នាអីចឹងទៅ គោក្របីគាត់ហ្នឹងក៏ដាក់ចូលរួមអីចឹងទៅ ហើយដូចជាមិនមានឃើញធ្វើការបែងចែកអីថា អ្នកនេះថ្មីអ្នកនេះចាស់អីទេ តាមពិតទៅនៅក្នុងសហករណ៍ហ្នឹងវាថ្មីទាំងអស់តែគ្នា ទាំងកសិករក៏មកថ្មី មកពីភូមិផ្សេង ហើយមានគោមានក្របីមកជាមួយ។ ពួកកសិករបញ្ញាជនទៅពីភ្នំពេញទៅ ហើយខ្ញុំដឹង ដឹងតែប៉ុណ្ណឹងទេ ហើយត្រង់ទៅសហករណ៍ទូទាំងប្រទេស គេបែងចែកយ៉ាងម៉េចៗ ខ្ញុំមិនបានដឹងទេ ព្រោះមិនបានចូលរួមនៅជាមួយ ហើយក៏មិនបានទៅដែរ រហូតដល់បែកកម្ពុជាប្រជាធិបតេយ្យហ្នឹងទៅបាទ។

[១៣:៤៤:៥៣]

**ស៖** ចា៎ សូមអរគុណ។ លោកបានឆ្លើយជម្រាបអង្គសវនាការកាលពីថ្ងៃម្សិលដែរ លោកថា

លោកឡើងមកភ្នំពេញ គឺលោកឡើងមកតែម្នាក់លោកទេ ចំណែកឯក្រុមគ្រួសារលោកស្នាក់នៅសហករណ៍ចំប៉ាហ្នឹង សហករណ៍នៅវត្តចំប៉ានៅកៀនស្វាយហ្នឹង។ ចាសអ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកថា ដែលថាលោកឡើងមកភ្នំពេញ ចាស លោកឡើងមកភ្នំពេញម្នាក់ឯងលោកមានដឹងថាអី វ៉ាន់ៗ រិទ្ធ ជាអ្នកហៅលោកមក ឬក៏អ្នកណាផ្សេង ដែលជាអ្នកហៅលោកឡើងមកភ្នំពេញហ្នឹង?

**ឆ៖** លោកប្រធាន ខ្ញុំសូមបញ្ជាក់តម្រូវបន្តិចបាទ។ ពេលដែលមកពីចំប៉ាមក សហករណ៍មកក្បែរភ្នំពេញហ្នឹង គឺមកទាំងអស់គ្នា ខ្ញុំមិនបានថាមកតែខ្ញុំទេ។ ហើយមកតែខ្ញុំ គឺពេលដែលយកខ្ញុំពីសហករណ៍ភ្នំពេញយកមកនៅក្នុង-- ធ្វើការនៅភ្នំពេញ បានមកតែខ្ញុំ។ ហើយមកពីចំប៉ាហ្នឹង គឺមកទាំងអស់គ្នា។ ហើយទៅនៅសហករណ៍ថ្មី។ ដល់ពេលយកខ្ញុំមកភ្នំពេញ គឺគ្រួសារខ្ញុំនៅសហករណ៍ថ្មីទាំងអស់ មិនមែននៅឯចំប៉ានោះទេបាទ។ រឿងពិតអ៊ីចឹងបាទ។

[១៣:៤៦:០៥]

**ស៖** ចាស សំណួរខ្ញុំដែលខ្ញុំសួរលោកគឺខ្ញុំៗចង់សួរថាអ៊ីចឹង សួរថាពេលដែលលោកជម្លៀសពីភ្នំពេញមក លោកនៅសហ-- នៅក្នុងវត្តចំប៉ាហ្នឹង គឺលោករស់នៅទាំងអស់គ្នា ទាំងក្រុមគ្រួសារលោកដល់ពេលក្រោយមក លោករស់នៅបានប្រហែលពីរខែ ចាស អង្គការគេបានហៅលោកឡើងមកភ្នំពេញការដែលលោកឡើងមកភ្នំពេញ គឺលោកអញ្ជើញមកតែម្នាក់ឯងទេ។ ខ្ញុំចង់ចម្រាបសួរលោកថា លោកមានដឹងទេ ដែលអង្គការហៅលោកឡើងមកភ្នំពេញ ឡើងមកដោយសារលោក វ៉ាន់ រិទ្ធ ជាអ្នកហៅលោកដែលធ្លាប់ស្គាល់លោកនៅក្រសួងពាណិជ្ជកម្ម ឬក៏អ្នកណាផ្សេងដែលជាអ្នកហៅលោកឡើងមកភ្នំពេញ?

**ឆ៖** សូមបញ្ជាក់ម្តងទៀតថា ពេលដែលនៅសហករណ៍ចំប៉ាហ្នឹង នរណាទៅហៅខ្ញុំមក ខ្ញុំមិនដឹងទេ ហើយខ្ញុំបញ្ជាក់ម្តងទៀតថាមកទាំងអស់គ្នា ហើយមកមិនមែនមកភ្នំពេញទេ មកនៅសហករណ៍មួយនៅក្បែរភ្នំពេញ។ មិនមែនមកភ្នំពេញត្រង់ទេ។ អាហ្នឹងគឺដល់មកនៅសហករណ៍ថ្មីហ្នឹងក៏មកទាំងអស់គ្នា ដល់ចេញពីសហករណ៍ថ្មីមកភ្នំពេញហ្នឹងបានមកតែខ្ញុំ។ គ្រួសារនៅសហករណ៍ថ្មីដដែល។ នេះសូមបញ្ជាក់ជាថ្មីម្តងទៀត ហើយសូមអស់ប៉ុណ្ណឹង។ សូមអរគុណ។

[១៣:៤៧:២១]

**ប្រធានអង្គជំនុំ៖**

សំណួរទំនងមិនអ៊ីចឹងទេ សំណួរសួរថា ពេលដែលគេអញ្ជើញលោកពីសហករណ៍ថ្មីមកកាន់--

មកធ្វើការនៅភ្នំពេញតែម្នាក់ឯងនោះថា តើលោក-- ថាតើអ្នកណាជាអ្នកជាអ្នកទៅហៅមក? វ៉ាន់ រិទ្ធ ឬក៏អ្នកផ្សេងដទៃទៀត? សំណួរតែប៉ុណ្ណឹងទេ តើឈ្មោះ វ៉ាន់ រិទ្ធ ហ្នឹងឬក៏ឈ្មោះអ្នកផ្សេងទៀតដែលជាអ្នកហៅលោកមកធ្វើការនៅឯភ្នំពេញ ដែលលោកក្រោយមកលោកធ្វើជាអនុប្រធាន អ្ហឺ! អគ្គនាយករងធនាគារនោះ?

**លោក សគឹម ល្អុត៖**

**ឆ៖** លោកប្រធាន ខ្ញុំថាអត់បានដឹងទេបាទ។ មិនដឹងអ្នកណាចង្អុលឈ្មោះខ្ញុំមកទេ។ បាទ អត់ដឹងទេ។

**លោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស សូមអរគុណ។ ពេលដែលលោកមកភ្នំពេញ ចាស អ្នកណាជាអ្នកទទួលលោក ហើយអ្នកណាជាអ្នករៀបចំកន្លែងឲ្យលោកស្នាក់នៅចាស?

**ឆ៖** បញ្ហានេះដូចជាខ្ញុំបានជម្រាបម្តងហើយ គឺមកនៅនឹងផ្ទះនៅក្បែរគណៈកម្មាធិការឧស្សាហកម្ម អាចហៅថា "ក្រសួងឧស្សាហកម្ម" អ៊ីចឹង។ ហើយកន្លែងហ្នឹង គឺមានលោក អន ហ្នឹងជាអ្នកគិតគូរឲ្យស្នាក់នៅក្បែរកន្លែងគាត់ហ្នឹង លោក។

[១៣:៤៨:៥១]

**ស៖** ចាស សូមអរគុណ។ លោកមានដឹងមុនទេ ពេលដែលលោកឡើងមកភ្នំពេញ លោកៗថា លោកនឹងទទួលមុខតំណែងជានាយករងធនាគារក្រៅប្រទេស លោកមានបានដឹងមុនទេ?

**ឆ៖** ខ្ញុំមិនដឹងមុនទេ ហើយក៏មិនដឹងថា គេមានគម្រោងនឹង ន៎ែ! បង្កើតធនាគារយ៉ាងម៉េចៗក៏ខ្ញុំអត់ដឹងដែរ គ្រាន់ថាខាងសហករណ៍នោះគេថា អង្គការឲ្យន៎ែសមមិត្តទៅធ្វើការនៅភ្នំពេញតែប៉ុណ្ណឹង ដឹងតែប៉ុណ្ណឹង។ ថាមកថាទៅធ្វើអីៗ ខ្ញុំក៏មិនដឹងមុនដែរបាទ។

**ស៖** ចាស សូមអរគុណ។ ចាស ក្នុងអំឡុងពេលដែលលោកមកភ្នំពេញ ចាស លោកបានជម្រាបអង្គសវនាការថា ក្នុងអំឡុងពេលហ្នឹង បើលោកចង់ទៅលេងប្រពន្ធកូននៅឯកៀនស្វាយ លោកគ្រាន់តែប្រាប់គេទៅលោកនឹងអាចទៅលេងប្រពន្ធកូនរបស់លោកនៅកៀនស្វាយបាន មិនអ៊ីចឹងលោកមែនទេ លោកថ្លៃណោះ?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយនូវសំណួរហ្នឹងទេ! មេធាវីក្តាប់អង្គហេតុមិនបានទេ ក្តាប់ចម្លើយសាក្សីមិនបានទេ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស អរគុណលោកប្រធាន។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស ខ្ញុំសូមសួរលោកបន្តទៀតថា ពេលដែលលោកទៅលេងប្រពន្ធកូនលោក។ ចាស ខ្ញុំចង់ជម្រាបសួរថា លោកក្នុងនាមលោកជាបញ្ញាជន ហើយសម័យហ្នឹងគឺ លោករស់នៅបែកប្រពន្ធកូនលោក។ តើលោកមានអារម្មណ៍ម៉េចដែរ ចំពោះរបបហ្នឹង ពេលដែលប្ដីប្រពន្ធរស់នៅបែកគ្នាហ្នឹង?

**លោក សគីម ល្មុត៖**

**ឆ៖** ខ្ញុំយល់ថា អានេះមិនមែនចាំថា បញ្ញាជន មិនបញ្ញាជនទេ ដូចថាតែរស់បែកគ្នាវាមានអារម្មណ៍ហើយ មិនពេញចិត្តដែរ។

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតថា លោកបានឆ្លើយជាមួយសហព្រះរាជអាជ្ញាថា នៅក្នុងសហករណ៍របស់លោក មុនពេលដែលលោកទៅភ្នំពេញ គឺលោកអត់ដឹងថា តើសហករណ៍ហ្នឹងមានការរៀបការ ឬក៏មិនមានទេ? ខ្ញុំចង់ជម្រាបសួរលោកថា ចុះកន្លងមកក្នុងឆ្នាំ៧៦, ៧៧, ៧៨, ៧៩ លោកមានបានដឹងថា នៅក្នុងសហករណ៍ផ្សេងៗ ឬនៅក្នុងក្រសួងរបស់លោកធនាគារក្រៅប្រទេសរបស់លោកហ្នឹង មានការរៀបការឬអត់ក្នុងសម័យហ្នឹង?

[១៣:៥១:៣៤]

**ឆ៖** ខ្ញុំសូមវែកញែកអ៊ីចេះ។ ពេលដែល ខ្ញុំនៅសហករណ៍ក្បែរស្ទឹងមានជ័យ ខ្ញុំមិនដឹងថានៅសហករណ៍ឯទៀតៗ មានការយ៉ាងម៉េចទេ។ គេរៀបចំការដោយបង្ខំ ខ្ញុំមិនដឹងដែរ មិនដឹងការអី។ ដឹងតែកន្លែងដែលខ្ញុំនៅហ្នឹង គឺមានការរៀបការ តែដូចជាមិនឃើញបង្ខំទេ ក្នុងការដែលនៅសហករណ៍ហ្នឹង មិនឃើញទេ។ ហើយដល់មកនៅកន្លែងពាណិជ្ជកម្មនៅភ្នំពេញហ្នឹង មានតែខ្ញុំម្នាក់ឯងបុគ្គលិកហើយនិងក្មេងៗពីរបីនាក់។ ដូច្នេះ គ្មានការរៀបការ រៀបអីទេ ហើយបើក្នុងក្រសួងពាណិជ្ជ បើគេមានក៏គេមានតែក្នុងផ្នែកគេ ខ្ញុំមិនដឹងថា អ្នកណាបង្ខំ អ្នកណាមិនបង្ខំទេ ខ្ញុំមិនអាចឆ្លើយបានទេបាទ។

[១៣:៥២:២១]

**ស៖** ចាស សូមអរគុណ។ លោកបានជម្រាបអង្គសវនាការអំមិញថា នៅសហករណ៍នុំងលោកធ្លាប់បានធ្លាប់ឃើញគេរៀបការដែរ។ ប៉ុន្តែឃើញថា ការរៀបការមិនបង្ខំ ហើយខ្ញុំចង់ជម្រាបសួរលោកបន្តថា តើការរៀបការដែលលោកមើលឃើញថា មិនបង្ខំហ្នឹង ខ្ញុំចង់ជម្រាបសួរថា តើមានការ

ចូលរួមពីសាច់ញាតិបងប្អូន ហើយការរៀបការហ្នឹងគឺរៀបការតាមប្រពៃណី មានភ្លេងខ្មែរ មានអាចារ្យ មានលោក ឲ្យពរឲ្យជ័យ ឬក៏ម៉េច ចាស?

**ឆ៖** បាទ គ្មាន វាគ្មានធ្វើតាមរបៀបយើងប្រពៃណី មានភ្លេង មានអីនោះ អស់ហើយពេលនុ៎ង នោះ។ ហើយគ្រាន់តែពេលនេះហ្នឹង គេប្រជុំ ដូចជាមីទ្និង អ៊ីចឹងទៅ ប្រកាសអ៊ីចឹងទៅ ហើយបើមាន ឪពុកម្ដាយនៅនុ៎ងក៏គេឲ្យចូលរួមទៅ។ ប៉ុណ្ណឹង បាទ គ្មានភ្លេងប្រពៃណី គ្មានភ្លេងភ្លាត់អីទេ បាទ អត់ មានទេបាទ។

[១៣:៥៣:២០]

**ស៖** ចាស សូមអរគុណ។ ចាស លោកបានជម្រាបថា រៀបការគ្មានភ្លេង គ្មានភ្លាត់តាម ប្រពៃណី។ ខ្ញុំចង់ជម្រាបសួរលោកថា តើការរៀបការបែបនេះ សួរថាតើផ្ទុយពីឆន្ទៈរបស់អ្នកដែល រៀបការឬទេ ដែលហៅថាការរៀបការមិនតាមប្រពៃណី គ្មានអាចារ្យឲ្យពរ ឲ្យជ័យហ្នឹង តាមគំនិត របស់លោក តើផ្ទុយពីឆន្ទៈរបស់អ្នក--

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេសាក្សី! ពីព្រោះសាក្សីមិនអាចធ្វើសេចក្ដីសន្និដ្ឋានទៅដល់ដឹងចិត្តគំនិតរបស់អ្នក ដទៃផ្សេងទៀត ក្រៅពីលោកទេ។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស សូមអរគុណ។ ខ្ញុំចង់ជម្រាបសួរលោកបន្ត តើលោកស្គាល់ ឌឿន ច្បាស់ទេចាស?

**លោក សគឹម ល្មុត៖**

**ឆ៖** មុនដែលខ្ញុំ គេហៅមកធ្វើការនៅភ្នំពេញហ្នឹង ពីមុនមិនដែលស្គាល់គាត់ទេ។ តែដល់មក គាត់ ដឹងថាគាត់ធ្វើជាប្រធានពាណិជ្ជកម្ម ជាអ្នកកាន់គណៈកម្មការពាណិជ្ជកម្ម ហើយខ្ញុំក៏ត្រូវធ្វើការជា មួយគាត់ សហការជាមួយគាត់។ ហើយពីមុនមក ខ្ញុំមិនដែលស្គាល់គាត់ទេ មិនដឹងជាគាត់ ប្រវត្តិគាត់ យ៉ាងម៉េចៗ ខ្ញុំមិនដែលបានដឹងដែរ បាទ។

**ស៖** ចាស សូមអរគុណ។ ចុះដែលកាលដែលលោកដឹងថា គាត់ជាប្រធានគណៈកម្មាធិការ ពាណិជ្ជកម្មហ្នឹង។ ចុះលោកមានបានដឹងថា តើឌឿនជាប្រធានមន្ទីរ៨៧០ទេ ចាស?

**ឆ៖** បាទ ខ្ញុំបាទអត់បានដឹងទេបាទ។ ហើយខ្ញុំក៏មិនស្គាល់លេខ៨៧០ហ្នឹងដែរ។

[១៣:៥៥:០៦]

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំចង់សួរលោកបន្តទៀតថា តើលោកស្គាល់ឈ្មោះ អន ច្បាស់ទេ?

**ឆ៖** បាទ ឈ្មោះ អន ខ្ញុំស្គាល់នៅពេលដែលខ្ញុំមកស្នាក់នៅជាមួយគាត់ហ្នឹង ពីមុនមកក៏មិនដែលខ្ញុំដែរ អន ហ្នឹងបាទ។

**ស៖** ចាស សូមអរគុណ។ អន ហ្នឹងគាត់ជាប្រធានផ្នែកឧស្សាហកម្មមែនទេ?

**ឆ៖** បើតាម ឃើញតាមពីកន្លែងហ្នឹង ឃើញថាគាត់ជាប្រធានហើយ ប៉ុន្តែត្រង់ថាជាការចាត់តាំងមករបៀបម៉េចក៏ខ្ញុំមិនបាន មិនថាមានជាឯកសារអី អ្នកណាមកឧទ្ទេសសនាមខ្ញុំថា គាត់ជាប្រធានតែដល់ចាត់ការនៅកន្លែងនុំង ឃើញថា មើលឃើញថាដូចជាគាត់ហ្នឹងជាប្រធានហើយ។

[១៣:៥៥:៥៦]

**ស៖** ចាស សូមអរគុណ។ ចាស ចុះលោកបានស្គាល់ វន វ៉េត ច្បាស់ទេ វន វ៉េត?

**ឆ៖** បាទ វន វ៉េត ហ្នឹងក៏ជួបគ្នាតែពេលដែលមកហើយ ក៏គាត់មកឧទ្ទេសនាមខ្ញុំថា ត្រូវៗមានការងារអីផ្សេងៗហ្នឹង។ បាន ស្គាល់គាត់តាំងពី-- ហើយជួបតែម្តងហ្នឹងដល់ក្រោយៗមកក៏មិនដែលធ្វើការអីជាមួយគាត់ទៀតដែរបាទ។

**ស៖** ចាស លោកស្គាល់ប្រហែលជាក្នុងឆ្នាំណាដែរចាស?

**ឆ៖** ឲ្យខ្ញុំចាំឆ្នាំ មិនច្បាស់ទេ ប្រហែលជាដើម-- ខ្ញុំមកពីសហករណ៍ ប្រហែលជាដើមឆ្នាំ៧៦ អីក៏មិនដឹងទេ។ ខ្ញុំមិនៗច្បាស់ ដើមឆ្នាំ ចុងឆ្នាំ រឿងឆ្នាំហ្នឹងខ្ញុំសូមអភ័យទោស ខ្ញុំមិនចាំច្បាស់ទេ។ តែប្រហែលជាដើម ៧៦ ហ្នឹងមិនដឹង ព្រោះធ្វើស្រែហើយមួយវស្សា ច្រូតស្រូវហើយបានមកភ្នំពេញ។

[១៣:៥៧:០៦]

**ស៖** ចាស សូមអរគុណ។ ចាស អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកថា លោកធ្លាប់ធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យស៊ីសុវត្ថិ ខ្ញុំចង់សួរថាតើលោកស្គាល់លោក អៀង សារី លោក សាឡុត ស ហើយអ្នកស្រី ខៀវ ធីរិទ្ធ ទេចាស? ព្រោះគាត់ជាសាស្ត្រាចារ្យនៅសាលាស៊ីសុវត្ថិដែរ។

**ឆ៖** គឺអស់លោកទាំងនេះ គឺថាខ្ញុំមិនមែនស្គាល់នៅពេលដែលខ្ញុំមកធ្វើសាស្ត្រាចារ្យទេ គឺស្គាល់ពីមុន គឺថាតាំងពីនៅរៀនឯណោះ។ ដូចថា លោកស្រី អៀង ធីរិទ្ធ ក៏ជារៀនស្រករៗគ្នា លោក អៀង សារី រៀនមុន តែក៏នៅស៊ីសុវត្ថិដែរ។ ហើយលោក សាឡុត ស ហ្នឹងក៏មកស៊ីសុវត្ថិ តែពីមុនគាត់រៀននៅខាងកំពង់ចាម ទេ ហើយដល់មកចូលមកក៏រួមថ្នាក់គ្នាបានមួយរយៈ គាត់ក៏ឈប់រៀននៅហ្នឹង ទៅរៀន

អីណាផ្សេងទៀតទៅបាទ។

[១៣:៥៨:១៤]

**ស៖** ចាស សូមអរគុណ។ ចាស លោកបានឆ្លើយថា ឆ្លើយពីថ្ងៃម្សិលក៏ដូចជាព្រឹកមិញដែរ ថាលោកធ្វើការនៅផ្នែកធនាគារក្រៅប្រទេស ហើយគឺលោកធ្វើការនៅធនាគារក្រៅប្រទេស គឺលោកធ្វើការតាមចំណេះដឹងរបស់លោកផង និងតាមការខ្លាចផង។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើលោកខ្លាចហ្នឹងលោកខ្លាចរបៀបម៉េចដែរ ដែលលោកធ្វើការតាមរបៀបខ្លាចផងហ្នឹងចាស?

**ឆ៖** ខ្លាចថា ធ្វើការខុសឆ្គងទៅគេប្រកាន់ទោសអីចេះ អីចុះ ដូចថា ដូចយើងចេះដែរថាមិនចេះអីចេះ អីចុះទៅ ប្រកាន់ទោសអីចឹងទៅបាទ។

**ស៖** ចាស សូមអរគុណ។ អីចឹងពាក្យខ្លាចរបស់លោក លោកថា ខ្លាចគេប្រកាន់ទោស ដូចករណីលោក ឌឿន ហើយលោក វន វ៉េត ហ្នឹងមែនទេចាស?

[១៣:៥៩:១៩]

**ឆ៖** ខ្ញុំមិនអាចប្រៀបធៀបបានទេ ពីព្រោះខ្ញុំមិនដឹងថា គេប្រកាន់ទោស វន វ៉េត, ឌឿន ហ្នឹងរឿងអីផង។ ខ្ញុំមិនអាចប្រៀបធៀបបានទេបាទ។ ខ្ញុំមិនអាចប្រៀបធៀបបានទេ។ ពេលនុ៎ងខ្ញុំមិនដឹងជាគេទោស មិនមានទោសផង។ ខ្ញុំទើបមកដឹងក្រោយនេះ ពេលស៊ើបសួរខ្ញុំ យកឯកសារមកឲ្យខ្ញុំមើលទេ បានខ្ញុំដឹង ពេលនោះខ្ញុំអត់ដឹងទេបាទ។

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំចង់ជម្រាបសួលោកបន្តទៀតថា លោករស់នៅភ្នំពេញបែកប្រពន្ធលោកតាំងពីឆ្នាំ៧៥ រហូតមកដល់៧៩ ពេលវៀតណាមចូល ឬក៏ម៉េចដែរចាស?

[១៤:០០:០១]

**ឆ៖** បាទ ប៉ុន្តែថា បែកទាំងស្រុង ក៏វាដូចមិនបែក ព្រោះថា ពេលដែលខ្ញុំមកនៅ គេអនុញ្ញាតឲ្យខ្ញុំទៅលេងប្រពន្ធកូនកន្លះខែអីអីចឹងម្តងដែរ ទៅសហករណ៍វានៅជិតគ្នា ទៅនៅខាងត្បូងស្ទឹងមានជ័យ។ ដូច្នេះថា ៗបែកក៏មិនបែក ឲ្យវាៗដាច់ស្រឡះដែររហូតមមក។

**ស៖** សូមអរគុណ។ ខ្ញុំចង់ជម្រាបសួរលោកបន្តថា ក្នុងនាមលោកជានាយករងធនាគារក្រៅប្រទេសនៅភ្នំពេញហ្នឹង ខ្ញុំចង់សួរថា តើលោកធ្វើការជានាយករងហ្នឹងតាំងពីឆ្នាំណាដែរ-- ពីឆ្នាំណាដែរលោក? តាំងពីឆ្នាំដែលលោកផ្លាស់មកភ្នំពេញដំបូងហ្នឹង រហូតដល់បែកភ្នំពេញ ឬក៏យ៉ាងណាដែរក្នុងតួនាទីរបស់លោកហ្នឹង?

**ឆ៖** គឺពេលដែលគេបង្កើតធនាគារនេះឲ្យឈ្មោះថា ធនាគារពាណិជ្ជកម្មក្រៅប្រទេសហ្នឹង។ ប៉ុន្តែខ្ញុំមិនចាំខែទេ ប៉ុន្តែអាចថាក្នុងកណ្តាលខែ ឬចុង-- អំ! កណ្តាលឆ្នាំ ឬចុងឆ្នាំ ៧៦ហ្នឹងបាទ។ ខ្ញុំមិនចាំខែច្បាស់លាស់ទេបាទ។

[១៤:០១:១៣]

**ស៖** សូមអរគុណ។ អ៊ីចឹងក្នុងនាមលោកធ្វើការជានាយករងធនាគារក្រៅប្រទេសហ្នឹង ខ្ញុំចង់ជម្រាបសួរថា រាល់ការងារនៅក្នុងធនាគារក្រៅប្រទេសហ្នឹង តើលោកធ្វើហ្នឹងមានការបញ្ជាថ្នាក់ណាដែរ ដែលលោកធ្វើការងារហ្នឹងពីមុន?

**ឆ៖** ការបញ្ជាហ្នឹងវាគ្មានទទួលបញ្ជាផ្ទាល់ពីអ្នកនេះអ្នកនោះមកទេ។ តែដូចថាឯកសារខ្លះវាមានមន្ទីរកណ្តាលគេយកមកមាននីរសារយកមក ៗយើងធ្វើទៅតាមគេណែនាំថាចង់ធ្វើអី ធ្វើអ៊ីចឹងទៅទៅតាមអាខែងដែលខ្ញុំធ្វើកើតអ៊ីចឹងទៅ។ មិនមែនថា ធ្វើនៅឈ្មោះណា ឈ្មោះនរណា ណាហ្នឹងបញ្ជាមកជាអ៊ីចេះអ៊ីចុះទេបាទ។ មកតាមមានមន្ទីរកណ្តាលមួយ តាមនីរសារយកមក។ ខ្ញុំមិនដឹងជាបុគ្គលអ្នកលើមកនរណាទេបាទ។

**ស៖** សូមអរគុណ។ ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតថា ការងារប្រតិបត្តិការស្នូលរបស់ធនាគារក្រៅប្រទេសហ្នឹង តើគេសំដៅទៅលើអ្វីដែរលោក?

**ឆ៖** ការងារស្នូលគឺដូចឈ្មោះធនាគារអ៊ីចឹង។ ធនាគារពាណិជ្ជកម្មក្រៅប្រទេស គឺប្រតិបត្តិការសម្រាប់ការទិញដូររវាងខ្មែរហ្នឹង ហើយនិងបរទេស។ ប៉ុន្តែវានេះជាឈ្មោះទេ ដូចខ្ញុំបានជម្រាបពីៗព្រឹក ពីថ្ងៃមុននោះគឺថា ធនាគារហ្នឹងមានតែពីរនាក់។ ម្នាក់ខ្ញុំមិនដែលឃើញមុខ ហើយមានម្នាក់ខ្ញុំ។ វាគ្មានគណនី គ្មានអីៗទេ។ គ្មានបញ្ជីម្រុយធ្វើខាតចំណេញអីទេ។ ហើយគឺដូចជាគ្មានខ្លឹមសារទេ មានតែឈ្មោះអ៊ីចឹងទេ។ បាទ ខ្ញុំសូមជម្រាបប៉ុណ្ណឹងបាទ។

[១៤:០៣:១៣]

**ស៖** សូមអរគុណ។ តាំងពីលោកចូលធ្វើការក្នុងនាមជានាយករងធនាគារក្រៅប្រទេសក្នុងឆ្នាំអំឡុងប្រហែលជាឆ្នាំ៧៦ ហ្នឹង។ ខ្ញុំចង់ជម្រាបសួរថា ការងារដែលរវល់ខ្លាំងជាងគេ ប្រហែលជាក្នុងអំឡុងឆ្នាំណា ៧៧, ៧៨ ឬក៏៧៩ ដែលរវល់ខ្លាំងជាងគេហ្នឹង?

**ឆ៖** បាទ មានការងារខ្លះដូចរវាង៧៨, ៧៩ ហ្នឹងប៉ុន្តែមិនមែនថា រវល់ដល់តែងាកខ្លួនមិនរួចទេ ការងារនោះវាមានការងារអីធំដុំប៉ុន្មានទេ គឺពេលក្រៅពីហ្នឹងខ្ញុំទៅដាំបន្លែ ចិញ្ចឹមមាន់ ចិញ្ចឹមទាជាមួយ

ក្មេងៗទៅ មិនមែនការងារហ្នឹងជាស្នូលអីប៉ុន្មានទេ។

**សៈ** សូមអរគុណ។ លោកបានជម្រាបអង្គសវនាការកន្លងមកថា រាល់ទំនិញនាំចេញ ឬនាំចូល លោកជាអ្នកកត់ត្រាដោយផ្ទាល់។ ខ្ញុំចង់ជម្រាបសួរថា លោកកត់ត្រា ៗរបៀបម៉េច? លោកចុះទៅកន្លែងដែលដឹកទំនិញមកដល់កន្លែងហ្នឹង លោកចុះទៅផ្ទាល់ ឬក៏លោកកត់ត្រាតាមៗដូចថា តាមការដែលគេប្រាប់។ ឧទាហរណ៍ថា ឥឡូវនេះត្រូវនាំថ្នាំពេទ្យចូលប៉ុន្មានតោន កំណត់ចូលប៉ុន្មានតោន លោកធ្វើរបៀបអាកំណត់ត្រាខ្យល់ ឬកំណត់ត្រាជាក់ស្តែង?

[១៤:០៤:៥៥]

**ឆៈ** សូមទោស បើខ្ញុំមិនច្រឡំទេ ខ្ញុំមិនបានបញ្ជាក់ថា ខ្ញុំកត់ត្រាអីចេញចូលអីទេ គឺពេលខ្លះខាងគេឲ្យគត់ក៏កត់ទៅ មានៗចេញចូល ប៉ុន្តែក៏មានទំនិញខ្លះគេខាងពាណិជ្ជកម្ម គេចេញទៅក៏គេអត់មានឲ្យខ្ញុំកត់ខ្ញុំអីដែរ។ អត់មានជាផ្តើមគំនិត ហើយក៏កត់ត្រាតាមដានគេទៅ ចេញអីប៉ុន្មាន អីប៉ុន្មានអត់ទេ គឺថាយូរៗគេហៅថាជួយមើលបញ្ជីនេះ កត់ត្រាទៅ វាគ្នាស្អីក្នុងធនាគារទេ គ្មាន ដូចជម្រាបដដែលៗគឺថាគ្មានគណនេយ្យ គ្មានបញ្ជីខាតចំណេញ គ្មានអី ហើយវា៣០ឆ្នាំជាងហើយ ខ្ញុំមិនអាចថាអ៊ីចេះថាអ៊ីចុះ។ ហើយជម្រាបដដែលៗគឺថាវាមានដូចថាខ្យល់ហួង យកជាការអីមិនបានទេ។ ហើយខ្ញុំបញ្ជាក់ថែមទៀតគឺថាពីព្រឹកនេះមានឯកសារមួយថា ចិនឲ្យខ្ចីណាៗ នៃ១៤០លានយ័នហ្នឹង ក៏ខ្ញុំមិនដឹង។ អាហ្នឹងជាកិច្ចព្រមព្រៀងរវាងចិន ភាគីចិន និងភាគីពាណិជ្ជកម្មក្រៅប្រទេស។ ហើយមិនមែនការងារធនាគារ គឺខ្ញុំដឹងដោយសារឯកសារហ្នឹងទេ គ្មានៗ-- និយាយដដែលៗគឺគ្មានបញ្ជីគណនេយ្យ គ្មានអីទេ។

[១៤:០៦:១៧]

**សៈ** ចាស សូមអរគុណ។ ចាស ចុះកន្លងមក ការងារដែលលោកកត់ទំនិញចូលមកស្រុកខ្មែរហ្នឹង កន្លងមកៗលោកដែលបានឃើញទំនិញដែលដឹកចូលពីបរទេសចូលមកស្រុកខ្មែរហ្នឹងមានអាវុធ មានគ្រាប់រំសេវ មានអីទេចាស?

**ឆៈ** មានបញ្ជីជាទំនិញស៊ីវិលខ្លះ ប៉ុន្តែរឿងគ្រាប់រំសេវគឺអត់ដែលមានទេ ហើយខ្ញុំមិនជឿថាគេឲ្យមកចុះបញ្ជីអីនៅកន្លែងអ៊ីចឹងៗទេ តាមខ្ញុំៗអត្តនោម័តិខ្ញុំទេ ខ្ញុំមិនដែលឃើញមាន ព្រោះគ្រឿងអាវុធវាមិនមែនជាការដោះដូរទេរវាងប្រទេសទេ គឺជារវាងរដ្ឋ ហើយនិងរដ្ឋ។ ដូច្នេះខ្ញុំមិនអាចនិយាយទៅដល់រឿងហ្នឹងបានទេបាទ។ សូមទោស។

**សៈ** ចាស សូមអរគុណ។ ចាស ចុះ-- សូមលោករៀបរាប់ពីទំនាក់ទំនងធនាគារក្រៅប្រទេស

តើធនាគារក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ ដែលលោកគ្រប់គ្រងហ្នឹង តើធ្លាប់មានទំនាក់ទំនងជាមួយធនាគារបរទេសណាខ្លះដែរ លោក?

**ឆ៖** ខ្ញុំមិនចាំអស់ទេ ប៉ុន្តែក៏ដូចជាមិនច្រើនទេ។ ដូចប្រទេសខ្លះ ដូចជាប្រទេស យូហ្គោស្លាវី ដូចប្រទេស ម៉ាដាហ្គាស្កា ហើយនិងប្រទេសចិន នេះក៏ខ្ញុំមិនច្បាស់ មិនដឹងជាមាន ឬអត់ទេ ព្រោះអ្វីៗគេច្រើនទាក់ទងផ្ទាល់ជាមួយក្រសួងពាណិជ្ជ។ ខ្ញុំជូនបានខ្លះៗប៉ុណ្ណឹង។ ខ្ញុំ ដែលវាមិនច្បាស់ ខ្ញុំមិនសូវ-- មិនៗប៊ានថា ព្រោះប៉ះពាល់គេបាទ។

[១៤:០៨:១៥]

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំសូមឱ្យលោកជួយរៀបរាប់ពីរចនាសម្ព័ន្ធគណៈកម្មាធិការពាណិជ្ជកម្មក្រៅប្រទេស ហើយនិងមន្ទីរផ្សេងៗដែលក្រោមឱវាទនោះ លោកអាចរៀបរាប់បានទេចាស?

**ឆ៖** គឺរចនាសម្ព័ន្ធគណៈកម្មាធិការពាណិជ្ជកម្មនោះមានក្នុងឯកសារ ដែលជជែកគ្នាមកពីព្រឹកពីម្សិលអស់ហើយ ហើយត្រង់កន្លែងណាផ្សេងទៀត គឺថាខ្ញុំអត់ដឹងទេបាទ។ ពីព្រោះរចនាសម្ព័ន្ធហ្នឹងគេមិនដែលផ្សព្វផ្សាយទេ ហើយដែលខ្ញុំដឹងខ្លះដោយសារពេលដែលស៊ើបអង្កេតហ្នឹង គឺយកឯកសារមកឱ្យខ្ញុំមក ឬពីពេលមុនហ្នឹងយកមកខ្ញុំមើល មុនហ្នឹង ខ្ញុំអត់ដឹងទេ ហើយត្រង់ឯក-- រចនាសម្ព័ន្ធផ្សេងៗទៀត ខ្ញុំអត់ដែរបាទ។ អត់ដឹងទេបាទ។

**ស៖** ចាស សូមអរគុណ។ ចាស យើងឃើញថា ការរៀបរាប់របស់លោក កន្លងមក យើងឃើញថាការងារស្នូលរបស់លោក គឺជាការងារពាក់ព័ន្ធនឹងធនាគារក្រៅប្រទេស ចាស ហើយការងារបន្ទាប់បន្សំរបស់លោក គឺលោកបានជម្រាបអង្គសវនាការកន្លងមកថា លោកជាអ្នកដូចថា ដើរបកប្រែពេលដែលមានប្រតិភូ ចាសប្រតិភូដទៃៗទៀតចូលមកស្រុកខ្មែរចាស។ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកថារាល់គណៈប្រតិភូដែលមកស្រុកខ្មែរ ដូចជាគណៈប្រតិភូចិន យូហ្គោស្លាវី។ល។ ហ្នឹង តើពេលហ្នឹងខ្ញុំចង់ជម្រាបសួរលោកថា លោកដើរបកប្រែរាល់ទស្សនកិច្ចរបស់គណៈប្រតិភូទាំងអស់ហ្នឹងគ្រប់ពេល ឬក៏យ៉ាងណាចាស?

[១៤:១០:០៥]

**ឆ៖** ខ្ញុំសូមបញ្ជាក់អ៊ីចេះ ចំពោះគណៈប្រតិភូចិន គេមានអ្នកបកប្រែខ្មែរ។ ខ្មែរមានអ្នកបកប្រែចិន។ ហើយដែលខ្ញុំចូលរួមម្តងម្កាល គឺថានៅពេលណាដែលមានសេដ្ឋកិច្ច ដូចហិរញ្ញៗនិងពាណិជ្ជកម្មៗ

ទេ ហើយដល់គណៈប្រតិភូផ្សេងៗទៀត ដល់អ្នកណាគេនិយាយភាសាបារាំង ហើយក៏ខ្ញុំទៅបកប្រែជាភាសាបារាំងហើយ ហើយមិនមែនចេះតែទៅ ពេលណាក៏ចេះតែទៅតាមគេដែរ ពេលណាគេត្រូវការឲ្យខ្ញុំទៅៗ គេមិនឲ្យទៅ ក៏អត់ទៅ។ ទាល់តែពេលគេប្រជុំអ៊ីចឹងត្រូវការបកជាភាសាបារាំងហ្នឹង គេច្រើនតែឲ្យខ្ញុំចូលទៅ មិនមែនតែខ្ញុំហ្នឹង មានខាងក្រសួងការបរទេស ក៏មានអ្នកពីក្រសួងការបរទេសមកដែរ។ ហើយដល់ពេលគេឃើញថាខ្ញុំយល់ដឹងភាសាបារាំងគួរសម ក៏ឲ្យជួយបកប្រែទៅបាទ។

**ស៖** ចាស សូមអរគុណ។ ចុះដល់ភាគច្រើនដែលគណៈប្រតិភូមកទស្សនកិច្ចនៅស្រុកខ្មែរហ្នឹង ភាគច្រើនទៅកន្លែងណាខ្លះលោក? លោកមានដឹងទេ?

**ឆ៖** សូមជម្រាបថា នៅភ្នំពេញមានផ្ទះច្រើនណាស់ ជាផ្ទះវីឡា ជាកន្លែងប្រជុំម្តង គេទៅទីនេះម្តង ទៅនោះអ៊ីចឹងទៅ។ ចង់យកកន្លែងណាក៏បានដែរ ផ្ទះមួយគំនរ។

[១៤:១១:៣៦]

**ស៖** ចាស អរគុណ។ ចុះដែលដើរទស្សនកិច្ចតាមខេត្តដែរលោក?

**ឆ៖** ក្នុង-- ខ្ញុំចាំបានថា ពេលណាមានគណៈប្រតិភូ គេទៅទាមទារត្រូវការបកប្រែបារាំងហ្នឹងឲ្យខ្ញុំទៅជាមួយ ហើយទៅមានដូចជា មានតែសៀមរាបម្តង ហើយកំពង់សោមប៉ុណ្ណឹងទេ។

**ស៖** ចាស សូម-- ចាសៗអរគុណ។ អ៊ីចឹង រយៈពេលនៃទស្សនកិច្ច ឧទាហរណ៍ដូចទស្សនកិច្ចតាមខេត្ត ដូចសៀមរាប ហើយកំពង់សោម តើរយៈពេលទស្សនកិច្ចហ្នឹងមានរយៈពេលប៉ុន្មានថ្ងៃដែរលោក?

**ឆ៖** តាមខ្ញុំចាំ មិនហួសពីមួយយប់ទេ ដូចថាពីរថ្ងៃមួយយប់អីអ៊ីចឹង មិនដែលទៅនៅយូរអីទេ។

**ស៖** ចាស អរគុណ។ អ៊ីចឹងការដែលដើរទស្សនកិច្ចតាមខេត្ត ដូចសៀមរាប កំពង់សោម យើងទៅទស្សនកិច្ចនៅៗក្រសួងមន្ទីរណាខ្លះដែរលោក?

**ឆ៖** ខ្ញុំមិនចាំទេ ដូចថាទៅសៀមរាបអ៊ីចឹង ទៅគេនាំទៅមើលអង្គរវត្តអីបន្តិចអ៊ីចឹងទៅ ហើយគួរសមគ្នាអីជាមួយគណៈកម្មាធិការខេត្តគេទៅ ហើយកិច្ចការសំខាន់ៗ គេជជែកនៅភ្នំពេញនេះទេបាទ។ ហើយបើថានៅកំពង់សោម ជួបជាមួយត្រឹមផែ ទៅមើលអាឌែង ដូចថាមានកប៉ាល់គេមកអ៊ីចឹងគណៈខាងពាណិជ្ជកម្មហ្នឹង គេជួបទៅ ហើយខ្ញុំគ្រាន់តែជាអ្នកបកប្រែឲ្យគេបាទ។

[១៤:១៣:៣១]

**ស៖** ចាស លោកៗថាជាអ្នកបកប្រែ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរថា ពេលគណៈប្រតិភូមក ដូចជា

ទៅកំពង់សោម ទៅទស្សនកិច្ចនៅកប៉ាល់ទឹក កប៉ាល់អី ខ្ញុំចង់ជម្រាបសួរថា តើមានថ្នាក់លើណាដែលអមដំណើរគណៈប្រតិភូនោះ? ព្រោះលោក ក្នុងនាមលោកជាអ្នកបកប្រែ លោកមិនមែនជាអ្នកអមដំណើរទេចាស តើមានអ្នកណាចូលអមដំណើរក្នុងគណៈប្រតិភូហ្នឹង?

**ធ៖** ធម្មតាខាងពាណិជ្ជកម្ម មានតែលោក វ៉ាន់ រិទ្ធ ហ្នឹង គាត់ខាងពាណិជ្ជកម្មបាទ។

**ស៖** ចាស១ ខ្ញុំចង់ជម្រាបសួរលោកបន្តថា រាល់ដំណើរទស្សនកិច្ច ចាស ដែលភ្ញៀវមកស្រុកខ្មែរយើងហ្នឹង អ្នកណាជាអ្នករៀបចំ ដូចថាចាត់ចែង ថាឥឡូវត្រូវទៅកំពង់សោម ត្រូវសៀមរាប ឬត្រូវមកទស្សនានៅភ្នំពេញ ផ្ទះវីឡានេះ១ អ្នកណាជាអ្នកកំណត់ទិសដៅនៃការទស្សនកិច្ចហ្នឹង?

**ធ៖** បាទ ខ្ញុំមិនដឹងទេបាទ។

**ស៖** ចាស សូមអរគុណ។ ចាស បន្ទាប់ពីទស្សនកិច្ចចប់ហើយ ខ្ញុំចង់ជម្រាបសួរថា តើគណៈប្រតិភូទាំងអស់ហ្នឹងមានដែលទៅជួបថ្នាក់ដឹកនាំលើ១ទៀតទេ? មានដែលទៅជួប ដូចរបៀបថាទៅលេង ឬក៏ទៅរបៀបសំណេះសំណាលអីចឹងណ៎ះ?

[១៤:១៥:១៥]

**ធ៖** បាទ ខ្ញុំមិនដឹងទេបាទ។

**ស៖** ចាសសូមអរគុណ។ ចាស ឥឡូវពាក់ព័ន្ធនឹងការបកប្រែក្នុងពេលប្រជុំ ចាស ខ្ញុំចង់ជម្រាបសួរលោកថា ក្នុងនាមលោកជាអ្នកបកប្រែ ពេលដែលមានគណៈប្រតិភូមកចូលរួមប្រជុំហ្នឹង តើអ្នកណាខ្លះ ឬក៏ថ្នាក់ដឹកនាំណាខ្លះ ដែលចូលរួមក្នុងអង្គប្រជុំហ្នឹង ជាមួយគណៈប្រតិភូទាំងនុ៎ង?

**ធ៖** ខ្ញុំមិនបានចាំទេបាទ។ ខ្ញុំមិនបានចងចាំទេបាទ។

[១៤:១៥:៥៩]

**ស៖** ចាស សូមអរគុណ។ អីចឹង ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតថា តើអ្នកណាខ្លះជាប្រធាន ដូចថា ប្រធានក្នុងអង្គប្រជុំ ប្រធានក្នុងការ-- ក្នុងអង្គប្រជុំមុនដំបូងដែលត្រូវបើកកម្មវិធីនៅស្រុកខ្មែរនេះ អ្នកណាជាប្រធានអង្គប្រជុំហ្នឹង?

**ធ៖** សូមទោស សូមបញ្ជាក់ម្តងទៀត ខ្ញុំដូចមិនសូវយល់ទេសំណួរនេះ សូមលម្អិតម្តងទៀតបាទ។

**ស៖** ចាស សូមអរគុណ។ មុន ខ្ញុំជម្រាបសួរលោកថា ក្នុងពេលប្រជុំពេលគណៈប្រតិភូមកប្រជុំនៅស្រុកខ្មែរ ខ្ញុំចង់សួរថា តើមានអ្នកណាចូលរួមប្រជុំខ្លះ? លោកថា អត់ដឹង។ ចាស ហើយខ្ញុំចង់

ជម្រាបសួរលោកបន្តទៀតថា តើមានអ្នកដឹកនាំណា ឬក៏ថ្នាក់លើណាជាអ្នក ដូចថា ជាអ្នកបើកកម្មវិធីប្រជុំហ្នឹង?

[១៤:១៦:៥៧]

**ឆ៖** ដើម្បីឆ្លើយនឹងសំណួរនេះ ខ្ញុំសូមលើកជាក់ស្ដែង គឺថាឲ្យដើម្បីយល់។ ឧបមាថា គណៈប្រតិភូខាងគេនោះ ដូចជាថា ខាងពាណិជ្ជកម្មមក។ ហើយខាងខ្មែរមានគណៈប្រតិភូមួយដែរ ដូចថា ពីក្នុង៧៦ អ៊ីចឹង ដូចថា មានលោក ឌឿន អ៊ីចឹងគាត់ជាប្រធាន ហើយគាត់នោះជាអ្នកដឹកនាំប្រជុំទៅ ហើយមានសមាជិកទៀតៗ ខ្ញុំមិនចាំ មិនស្គាល់គេទេ ខ្លះក៏គេមកពីណា ខ្ញុំមិនប៉ានសួរឈ្មោះគេទេ គ្រាន់តែចាប់ដៃចាប់អីគួរសមអីអ៊ីចឹងទៅ តែ-- ជជែកគ្នាជាមួយគេទៅ ហើយត្រង់ថា អ្នកណាចាត់តាំងយ៉ាងម៉េចៗ ខ្ញុំមិនដឹងច្បាស់ដែរទេ មិនដឹងទេបាទៗ។ ឥឡូវ ឧទាហរណ៍មួយដើម្បីជ្រាបថា វាអ៊ីចឹង ឧបមា ប្រជុំមួយទៅ អ្នកនោះទៅ អ្នកហ្នឹងធ្វើប្រធានទៅខាងខ្មែរ ហើយត្រង់អ្នកណាពីលើចាត់តាំងមក ខ្ញុំមិនដឹងជាអ្នកណាទេ ឃើញតែអ្នកហ្នឹងទៅគេថា ប្រធាន ខ្ញុំទទួលស្គាល់ថា គេប្រធានទៅ។

**ស៖** ក្នុងនាមលោកជាអ្នកបកប្រែ តើការប្រជុំ និងប្រធានបទនៃការប្រជុំនោះ គេនិយាយពីបញ្ហាអ្វីដែរ? ការនាំចេញ នាំចូលហ្នឹងមានលើកទេក្នុងអង្គប្រជុំហ្នឹងចាស?

[១៤:១៨:២២]

**ឆ៖** រឿងនេះ វាៗរឿងខ្លះគេលើកទៅ រឿងខ្លះគេអត់លើកក៏មានដែរ ជួនកាលគេលើកពីរឿងទំនាក់ទំនងសេដ្ឋកិច្ចជាមិត្តភាព ជាអីអ៊ីចឹងទៅ គេនិយាយរួមៗអ៊ីចឹងទៅ ហើយបើថា រឿងលម្អិតៗទំនិញអីអាហ្នឹងវាជាភារៈរបស់ក្រសួងពាណិជ្ជកម្ម ហើយបើខ្ញុំបកប្រែដូចថា ជាមួយកូរ៉េអីអ៊ីចឹង មានៗឈ្មោះទំនិញ អ៊ីចឹងដែរបាទ ព្រោះខាងគាត់ក៏អត់-- ក៏និយាយបារាំង គ្នាខាងគាត់ក៏បារាំង ហើយខាងយើងក៏មានខ្ញុំបកប្រែអ៊ីចឹងទៅបាទ មិនមាននិយាយល្អិតអីថា ម៉េចៗ គឺថា ដូចមិនធ្លាប់បាននិយាយល្អិតពេកទេ។

**ស៖** ចាស សូមអរគុណ។ ធម្មតាការប្រជុំយើងមានកំណត់របៀបវារៈ ខ្ញុំចង់ជម្រាបសួរលោកថា របៀបវារៈនៃការប្រជុំជាមួយ គណៈប្រតិភូហ្នឹង តើរបៀបវារៈហ្នឹងអ្នកណាជាអ្នកបង្គាប់បញ្ហាឲ្យដាក់ចូលនៅក្នុងរបៀបវារៈនៃការប្រជុំហ្នឹង?

**ឆ៖** ខ្ញុំមិនដឹងទេ រឿងអ៊ីចេះគឺថា ធម្មតាប្រជុំអី គេមិនដែលមានរបៀបវារៈ ដូចយើងសព្វថ្ងៃថា មានប្រជុំទីមួយ ពីរ បី អីអត់មានទេ គឺថាពេលប្រជុំហ្នឹងគឺប្រធានគណៈប្រតិភូខាងខ្មែរហ្នឹង ថាខ្ញុំមាន

បញ្ហាអីលើកទៅ ខាងនោះមានអីលើកទៅ ហើយអ្នកទៅហែរហមនោះគឺមិនដឹងថា មានអីច្បាស់ទេ របៀបវារៈ ខ្ញុំមិនដែលឃើញថាប្រជុំនេះអ៊ីចឹង របៀបវារៈគឺមិនដែលមានរបៀបវារៈ ដូចថាយើងធ្លាប់ធ្វើសព្វថ្ងៃហ្នឹងមានវារៈអ៊ីចេះៗ គឺថាគ្មានទេបាទ គ្មានទេ។

[១៤:២០:២៤]

**ស៖** ចាស សូមអរគុណ។ តាមលោកដែលលោកជាអ្នកបកប្រែ ខ្ញុំចង់ជម្រាបសួរលោកថា ការប្រជុំញឹកញាប់ជាងគេក្នុងអំឡុងឆ្នាំណាដែរ?

**ឆ៖** គឺវាងចុង៧៧ ចុង៧៧ ៧៨ហ្នឹង ប៉ុន្តែមិនជាញឹកញាប់អីដល់មមាញឹកណាស់ណាទេ ខ្ញុំមិនចាំថាមានអីច្រើនណាស់ណាទេ។

**ស៖** ចាស សូមអរគុណ។ លោកបាននិយាយថា ក្នុងវារៈប្រជុំហ្នឹងខ្លះលើកពីបញ្ហានាំចូលនេះ បញ្ហានាំចេញនេះ ខ្ញុំចង់ជម្រាបសួរលោកថារាល់ការលើកបញ្ហានាំចូល ឬក៏នាំចេញគេមានកំណត់ទេ? គេមានកំណត់ ឧទាហរណ៍ថាឥឡូវក្នុងឆ្នាំ៧៧ នេះ យើងត្រូវកំណត់ថានាំចូលៗក្រណាត់ប៉ុន្មានតោន ចាស ចូលមកកម្ពុជាហ្នឹង ហើយនាំចេញ គេមានកំណត់ថា តើយើងត្រូវនាំចេញអង្ករប៉ុន្មានតោន ឬក៏សណ្តែកប៉ុន្មានតោនសម្រាប់យកទៅប្រទេសក្រៅហ្នឹង គេមានកំណត់ច្បាស់លាស់ទេចាស?

[១៤:២១:៤០]

**ឆ៖** តាមខ្ញុំចាំដូចជាគ្មានទេបាទ។ មិនដែលគេមិនមាន-- មិនដែលមានផែនការថា មួយឆ្នាំនេះយើងនាំពីប្រទេសខាងនោះប៉ុន្មានមក? គឺថា ខ្ញុំមិនដែលឃើញមានទេបាទ មិនមាន។

**ស៖** ចាស សូមអរគុណ។ ចាស យើងឃើញថានៅក្នុងឋានៈលោក ជាអគ្គនាយករងធនាគារក្រៅប្រទេសហ្នឹង ឥឡូវខ្ញុំចង់ជម្រាបសួរលោកថា តើលោកធ្លាប់ដែលទៅធ្វើ ឬក៏ទៅទស្សនកិច្ចនៅបណ្តាប្រទេសក្រៅផ្សេងៗណាទេចាស?

**ឆ៖** បាទ មិនដែលទេបាទ។

**ស៖** ចាស សូមអរគុណ។ ចាស លោកបានបញ្ជាក់ជាមួយសហព្រះរាជអាជ្ញា កាលពីព្រឹកមិញថាលោក អៀង សារី ធ្លាប់បានចូលប្រជុំ ហើយលោកក៏មានការភ្ញាក់ផ្អើល។ ចាស ប្រជុំនៅគណៈកម្មាធិការពាណិជ្ជកម្មហ្នឹង លោកមានការភ្ញាក់ផ្អើល ហើយនៅកំណត់ហេតុរបស់លោកដែលលោកបានឆ្លើយជាមួយអ្នកស៊ើបអង្កេត ចាស កាលពីថ្ងៃទី១៤ ខែ១២ ឆ្នាំ២០០៩នោះ លោកបានឆ្លើយថា លោក អៀង សារី បានចូលរួមប្រជុំជាមួយចិន ចាស គឺជាកិច្ចប្រជុំមួយដ៏សំខាន់។ ហើយការដែលចូលរួមប្រជុំ

ហ្នឹងមិនមែនថា ប្រជុំម្តងទេ គឺប្រជុំ-- ដូចថាលោកថា មិនមែនប្រជុំម្តង។ អ៊ីចឹងបានន័យថាលោក អៀង សារី ធ្លាប់បានចូលរួមប្រជុំជាមួយគណៈកម្មាធិការពាណិជ្ជកម្មហ្នឹងច្រើនដងហើយ តាមកំណត់ហេតុរបស់លោកចាស។

[១៤:២៣:២៤]

**ឆ៖** ពេលនុ៎ង គឺថាមុនដំបូងខ្ញុំមិនចាំថា បានចូលរួមជាមួយគាត់ទេ។ ប៉ុន្តែដល់ឃើញឯកសារហ្នឹងមក ខ្ញុំនឹកឃើញថាជារូម ហើយខ្ញុំក៏បន្ថែមថា វាអាចមានចូលប្រជុំ ហើយប្រជុំម្តងពីរដងអី ប៉ុន្មានដងអីប៉ុន្មានដងអី គឺថាវាតាមហើយ-- បើកាលណាមានៗពេលខ្លះក៏ប្រជុំធំ ប្រជុំតូចទៅ។ ប្រជុំធំអ៊ីចឹងអ្នកដែលសំខាន់មានអ្នកថ្នាក់ដឹកនាំទៅប្រជុំទៅ បើប្រជុំតូចថ្នាក់បច្ចេកទេសខាងក្រោមអ៊ីចឹងទៅ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងបាទ។ ហើយត្រង់ខ្ញុំថាប្លែកត្រង់ថា ពីមុនប្រជុំពាណិជ្ជកម្មមិនដែលឃើញគាត់ដឹកនាំទេ ហើយដល់ពេលហ្នឹងមានគាត់ជាអ្នកដឹកនាំម្តង។ អ៊ីចឹង ខ្ញុំគិតថាអាហ្នឹងជារឿងសំខាន់ហើយ។ បាទ បានថ្នាក់រដ្ឋមន្ត្រីការ-- ចូលរួមប្រជុំអ៊ីចឹងបាទ។

**ស៖** ចាស សូមអរគុណ។ ក្នុងកំណត់ហេតុដែលលោកបានឆ្លើយ ជាមួយអ្នកស៊ើបអង្កេតកាលពីថ្ងៃទី១៤ ខែ១២ ២០០៩ហ្នឹង លោកបានឆ្លើយនៅក្នុងចម្លើយទី២០ហ្នឹង លោកបានឆ្លើយថា លោក អៀង សារី បានចូលរួមប្រជុំ។ ចាស បានចូលរួមប្រជុំ ហើយការប្រជុំៗជាមួយចិនហ្នឹងមិនមែនមួយដងទេ តើលោកនៅរក្សាចម្លើយរបស់លោក កាលពីថ្ងៃទី១៤ ខែ១២ ២០០៩ហ្នឹងដដែល ឬយ៉ាងណាចាស?

[១៤:២៤:៥០]

**ឆ៖** សូមកែថាវាជាមិនមែនម្តងទេ អាចមានទៀត តែខ្ញុំមិនចាំទេបាទ។ ប៉ុន្តែត្រង់មួយហ្នឹង ដោយសារតែមានឯកសារមកឲ្យខ្ញុំមើលទេ។ ហើយឯទៀតៗ ខ្ញុំមិនចាំទេ បាទ។

**ស៖** ចាស សូមអរគុណ។ ហើយនៅក្នុងកំណត់ហេតុរបស់លោកដដែលហ្នឹង ហើយនៅក្នុងចម្លើយ និងសំណួរទី៣៨ ចាស លោកបានឆ្លើយថា វន វ៉េត ពេលនោះ គឺជាប្រធានគណៈកម្មការសេដ្ឋកិច្ច ហើយក៏មានឋានៈជាឧបនាយករដ្ឋមន្ត្រីផងដែរ ចា៎ះ! ហើយគាត់គ្រប់គ្រងផ្នែកគណៈកម្មការពាណិជ្ជកម្ម និងគណៈកម្មការឧស្សាហកម្ម អាចមានគណៈកម្មការផ្សេងៗទៀត តាមលោកដឹង មែនទេ លោកបានឆ្លើយ អ៊ីចឹងទេចាស?

**ឆ៖** នេះ គឺតាមដែលឯកសារយកបង្ហាញខ្ញុំមកហូរហែមកទេ មិនមែនខ្ញុំដឹងខ្លួនខ្ញុំថា រចនា

សម្ព័ន្ធហ្នឹង វាយ៉ាងម៉េចៗទេ ប៉ុន្តែដោយឯកសារដែលយកមកឱ្យខ្ញុំមើលពេលនុ៎ង ក៏វាអាចទៅជាអ៊ីចឹង។ ប៉ុន្តែដែលពេលមុនហ្នឹង ខ្ញុំមិនបានដឹងថាគាត់គ្រប់គ្រងលើផ្នែកណាផ្សេងទៀតទេ ប៉ុន្តែដូចចំពោះមុខពេលនុ៎ង ឃើញដូចថាគាត់ ដូចជាគាត់គ្រប់គ្រងពាណិជ្ជកម្ម ហើយនិងឧស្សាហកម្មហ្នឹងមែននៅពីលើ។

[១៤:២៦:២៨]

**ស៖** ចាស សូមអរគុណ។ ចាស ហើយខ្ញុំចង់ជម្រាបសួរលោកបន្តទៀត ចាស ពាក់ព័ន្ធនឹងការដក និងការដាក់សាច់ប្រាក់។ ខ្ញុំចង់ជម្រាបសួរលោកថា កាលដែលលោកគ្រប់គ្រងនៅធនាគារក្រៅប្រទេសហ្នឹង រាល់ទំនិញ ដូចថានាំចេញ នាំចូល តើមានការដកសាច់ប្រាក់អីសម្រាប់ទូទាត់ទំនិញទេ?

**ឆ៖** សូមបញ្ជាក់ថា គ្មានទេ ពីព្រោះធនាគារគ្មានហ្នឹងលុយផង។ គ្រាន់តែមានតែក្រដាសអ៊ីចឹងទៅ ហើយត្រង់គេ ខាងផ្នែកពាណិជ្ជកម្ម គេទូទាត់គ្នាយ៉ាងម៉េច គឺថាជារឿងផ្សេងមួយទៀត ព្រោះខាង ដូចខ្ញុំជម្រាបមុននោះ ធនាគារគ្មានគណនេយ្យ គ្មានអី គ្មានអីចុះបញ្ជីអី។ ហើយទៅទូទាត់យ៉ាងម៉េច គឺគ្មានទេបាទ។

**ស៖** ចាស សូមអរគុណ។ ចុះកន្លងមក លោកៗតាមដែលទំនិញនាំចេញ នាំចូល ខ្ញុំចង់ជម្រាបសួរលោកថា តើទូទាត់របៀបរូបិយប័ណ្ណហ្នឹង យើងប្រើតែលុយយ័ន ឬក៏យើងមានប្រើលុយប្រភេទអីផ្សេងៗទៀតដែរលោក?

[១៤:២៨:០៦]

**ឆ៖** គឺថាអាចមានពីព្រោះសម័យហ្នឹង លុយយ័ន មិនទាន់ខ្លាំងដូចឥឡូវទេ។ នែ៎! ព្រោះលុយយ័នអាចប្រើតែជាមួយចិនអ៊ីចឹង តែដល់ប្រទេសផ្សេងៗទៀតត្រូវតែលុយផ្សេង ប្រហែលជាដុល្លារ ប៉ុន្តែខ្ញុំសូមបញ្ជាក់ម្តងទៀតថា គ្មានឯកសារអីនៅនឹងដៃខ្ញុំទេ តែគឺថាតាមហេតុផល បារាំង ថា ឡូស៊ីក ហ្នឹងគេវាត្រូវតែប្រើលុយផ្សេងហើយ។ ហើយខ្ញុំគ្មានដើងលេខអីទេបាទ។ ពីព្រោះមិនអាចយកលុយយ័នទៅប្រើនៅ ឧបមា ម៉ាដាហ្គាស្កា នៅហុងកុងនៅអីណា អត់មានទេបាទ លុយយ័នហ្នឹងបាទ។ តែបញ្ជាក់ថា ខ្ញុំគ្មានឯកសារទេ គ្រាន់តែជាការគិតរបស់ខ្ញុំ លុយយ័នសម្រាប់តែចិនគេឱ្យខ្ចី ឱ្យទៅក្រសួងខ្ចីទូទាត់តែរវាងលុយយ័នហ្នឹងទេបាទ។

[១៤:២៨:៥៤]

**ស៖** ចាស សូមអរគុណ។ ខ្ញុំចង់ជម្រាបសួរលោកបន្តទៀតហើយ ចុះកន្លងមកដែលទូទាត់

ទំនិញ ចាស ជារបស់មានតម្លៃដូចជាមាស ឬក៏ពេជ្រទេ ស្រុកខ្មែរយើងហ្នឹង? ដែលយើង--ប្រទេសយើងអត់មានលុយចាយ ចាស ហើយយើងមានទូទាត់របៀបជាមាស រៀបជាពេជ្រឲ្យទៅ ឲ្យថ្លៃទំនិញហ្នឹង លោក?

**ឆ៖** ខ្ញុំអត់ដឹងទេបាទ ពីព្រោះខ្ញុំមិនដឹងជាមាស ជាពេជ្រហ្នឹង គេទុកនៅឯណាទេបាទ។ អត់ដឹងទេបាទ។

**ស៖** ចាស១ ខ្ញុំចង់ជម្រាបសួរលោកមក-- លោកថា ចុះកន្លងមកទំនិញនាំចេញ ពីស្រុកខ្មែរយើងទៅក្រៅប្រទេស ដែលនាំទំនិញដូចរបស់មានតម្លៃ ដូចជាមាស ហើយនិងពេជ្រនាំចេញទៅចិន ឬក៏ទៅយូហ្គោស្លាវី ឬទៅប្រទេសណាផ្សេងៗ ដែលនាំចេញអាទំនិញហ្នឹងទេចាស?

**ឆ៖** បាទ ខ្ញុំមិនដឹងទេបាទ។

**ស៖** ចាស សូមអរគុណ។ ខ្ញុំចង់ជម្រាបសួរលោកពាក់ព័ន្ធនឹងបញ្ហាការបង្កើតក្រុមហ៊ុន ខ្ញុំចង់ជម្រាបសួរលោកថា ក្រុមហ៊ុនដែលបង្កើតនៅហុងកុងនុ៎ង ជាក្រុមហ៊ុនរបស់កម្ពុជាប្រជាធិបតេយ្យ តើបង្កើតប៉ុន្មានក្រុមហ៊ុនដែរនៅក្នុងហុងកុងហ្នឹង?

**ឆ៖** បង្កើតក្រុមហ៊ុននេះ តាមពិតខ្ញុំវាភ្លេចទៅហើយ ប៉ុន្តែពេលដែលអ្នកស៊ើបអង្កេតទៅយកឯកសារមកឲ្យខ្ញុំមើល ខ្ញុំនឹកឃើញវិញក្រុមហ៊ុនហ្នឹង ពីមុនខ្ញុំភ្លេចហើយ។ ភ្លេចឈ្មោះហើយ តែដល់យកឯកសារមកខ្ញុំនឹកចាំ ចងចាំឡើងវិញថា មានបង្កើតក្រុមហ៊ុនមួយនៅហុងកុង ក្រុមហ៊ុនមួយ។

[១៤:៣០:៥៦]

**ស៖** មានតែមួយទេ ឬក៏យ៉ាងណាលោក?

**ឆ៖** ខ្ញុំដឹងតែមួយហ្នឹង ព្រោះឯកសារឲ្យខ្ញុំមើលឃើញតែមួយហ្នឹង។

**ស៖** អរគុណ។ អ៊ីចឹងក្រុមហ៊ុនមានបង្កើតនៅតែហុងកុង ប្រទេសផ្សេងៗមានបង្កើតទេ តាមលោកដឹង?

**ឆ៖** ខ្ញុំអត់ដឹងទេ បាទ។

**ស៖** សូមអរគុណ។ ចាស ខ្ញុំចង់ជម្រាបសួរលោកពាក់ព័ន្ធនឹងការបាត់ខ្លួននៅក្នុងឯកសារ E--D279/7 ចាស ERN ជាភាសាខ្មែរ គឺ 00418555 ត្រង់សំណួរចម្លើយទី១៣ ទាក់ទងនឹងការចាប់មនុស្ស២២នាក់ នៅក្នុងឆ្នាំ៧៦ ហើយ៧៧, ៧៨, ៧៩ យកទៅ ស-២១ ហ្នឹង។ ខ្ញុំចង់ជម្រាបសួរលោកថា តើលោកមានបានដឹងពីការចាប់មនុស្ស ឬក៏ពីការបាត់ខ្លួនកម្មាភិបាលមួយចំនួនជាបន្តបន្ទាប់លោក

មានបានដឹងខ្លះទេចាស?

[១៤:៣២:១៦]

**ឆ៖** បញ្ហានេះ ដូចជា បានសួរខ្ញុំម្ដងហើយ ប៉ុន្តែខ្ញុំឆ្លើយថា ខ្ញុំអត់បានដឹងទេ ព្រោះអានេះវាជារឿងពាក់ព័ន្ធនឹងផ្នែកពាណិជ្ជកម្ម ហើយមិនដូច ខ្ញុំមិនបានដឹងទេ បាទ។

**សៈ** លោកបានជម្រាបអង្គសវនាការកាលពីព្រឹកមិញថា លោកមានការភ័យខ្លាចៗពីអាបញ្ហាដូចថា បញ្ហាដែលថាការចាប់ខ្លួនខ្លះដែរមែនទេ? ព្រឹកមិញលោកមានបានជម្រាបអង្គសវនាការពីបញ្ហាហ្នឹងទេ?

**ឆ៖** ខ្ញុំបានប្រាប់ ប៉ុន្តែមិនមែនថា រឿងចាប់ខ្លួនអស់ហ្នឹង សួរខ្ញុំអ៊ីចឹង ឮដូចជាខ្ញុំដឹងប៉ុន្មាននាក់ហ្នឹងចាប់ ខ្ញុំមិនដឹងផង ហើយដូចថា មិនដឹងថាមានអ្នកខ្លះ គឺថាមិនឃើញមកធ្វើការក្នុងកន្លែងហ្នឹងក៏មានការបារម្ភអ៊ីចឹង តែក៏មិនបានដឹងថា អ្នកណាគេចាប់ប៉ុន្មាន ២០នាក់ ហ្នឹង គឺថាមិនមែនភ័យដោយសារដឹង ២០ប៉ុន្មាននាក់ហ្នឹងគេចាប់ទេ។ ខ្ញុំមិនបានដឹងទេ គ្រាន់តែបារម្ភក្នុងចិត្តអ៊ីចឹង។ ប៉ុន្តែអត់ដឹងរឿងដូចថា ហ្នឹងគេចាប់២០នាក់ហ្នឹង មិនយកទៅណា? អាហ្នឹងខ្ញុំអត់ដឹងទេ រឿង២០នាក់ប៉ុន្មាននាក់ដែលថា មានបញ្ជូនទៅអីណា ស-២១ គឺដឹងដោយសារឯកសារដែលអ្នកសង្កេតយកមកបង្ហាញទេ។ រឿងហ្នឹង ខ្ញុំអត់បានដឹងទេបាទ។ ហើយដែលភ័យព្រួយហ្នឹងមិនមែនដោយសារដឹងរឿងហ្នឹងទេ។ ភ័យព្រួយ គឺថាបរិយាកាសពេលនុ៎ង គឺថាតែមិនឃើញអ្នកមកអ៊ីចឹងទៅយើងវា ភ័យហើយមិនដឹងទៅណា ទៅណីអ៊ីចឹង។ តែប៉ុណ្ណឹងទេបាទ។

[១៤:៣៣:៥២]

**សៈ** សូមអរគុណ។ ទន្ទឹមនឹងការភ័យខ្លាចរបស់លោក តើលោកមានវិធីអីដើម្បីកាត់បន្ថយការភ័យខ្លាចលោក លោកត្រូវធ្វើតាមការបង្គាប់បញ្ជារបស់អង្គការ លោកត្រូវស្មោះត្រង់ លោកត្រូវអីឬក៏ម៉េចដែរចាស?

**ឆ៖** បាទ ពេលនុ៎ងយើងត្រូវតែស្មោះត្រង់អ៊ីចឹងហើយ ប៉ុន្តែខ្ញុំគិតថា ខ្ញុំជាការងារបច្ចេកទេសតូចមួយ អត់ពាក់ព័ន្ធនឹងនយោបាយថា ចាត់កម្លាំងទៅនេះ ទៅនោះ ហើយខ្ញុំគិតក្នុងចិត្តថា មើលទៅវាមិនដូចមិនអាចមានរឿងអីពាក់ព័ន្ធអីធំដុំទេ ធ្វើតែការងារធនាគារហ្នឹង គេឲ្យធ្វើអីធ្វើទៅហើយការងារហ្នឹងក៏មិនច្រើនអីដែរ ហើយមិនពាក់ព័ន្ធដល់អ្នកដទៃអីណាទៀត។ ខ្ញុំមើលទៅដូចជាមិនឃើញមានពាក់ព័ន្ធដែរ ហើយក៏ព្រួយបារម្ភតែ ព្រួយបារម្ភអ៊ីចឹងទៅរង់ចាំទៅតាមវាសនាអ៊ីចឹងទៅដូចគេ ដូចឯង

អ៊ីចឹងទៅ មិនដឹងជាទៅណាទៅណីដែរ។

**ស៖** សូមអរគុណ។ លោកបានជម្រាបអង្គសវនាការកាលពីព្រឹកមិញថា លោកមិនគិតអីទេ គឺលោកគិតតែសន្តិសុខផ្ទាល់ខ្លួន មិនអ៊ីចឹងលោកណ៎ា! លោកបានជម្រាបទេព្រឹកមិញ?

**ធ៖** ខ្ញុំដូចមិនយល់ថាខ្ញុំនិយាយអ៊ីចឹងដាច់ណាត់អ៊ីចឹងពេកទេ។ និយាយថា អ្នកណាស្អីៗទៅ ឲ្យរួចតែខ្លួនឯង ខ្ញុំដូចជា-- អាហ្នឹងបើខ្ញុំនិយាយច្រឡំក៏សូមបំពេញថា ខ្ញុំមិនគិតថា អ្នកណាម៉េចៗទៅ ឲ្យតែរួចខ្លួនឯងនោះ គិតថា ការងារខ្ញុំវាៗបច្ចេកទេស ហើយការងារតូចមួយ វាពាក់ព័ន្ធអីទៅដល់អ្នកដទៃ។ ប៉ុណ្ណឹងបាទ ខ្ញុំមិនមានគំនិតថា នរណាម៉េចៗទៅ ឲ្យតែរួចខ្លួនឯង ដូចជា-- ឬក៏ខ្ញុំនិយាយភ័ន្តច្រឡំ ឬក៏កត់ច្រឡំអី ខ្ញុំមិនដឹងទេ។ តែខ្ញុំគ្មានគំនិតថា អ្នកណាម៉េចៗទៅ ឲ្យរួចតែខ្លួនឯងបានទៅ ខ្ញុំធ្វើការបច្ចេកទេសប៉ុណ្ណឹង ប្រហែលជាឲ្យខ្ញុំរួចខ្លួនក៏មិនដឹង ឬក៏សុខទៅ ខ្ញុំយល់អ៊ីចឹងបាទ។

[១៤:៣៦:០៨]

**ស៖** ចាស សូមអរគុណ។ បែរមកផ្នែកក្រុមហ៊ុនដដែល ខ្ញុំចង់ជម្រាបសួរលោកថា ធម្មតាការបង្កើតក្រុមហ៊ុនគឺដើម្បីយកផលចំណេញ ខ្ញុំចង់ជម្រាបសួរថា តើតាំងពីបង្កើតក្រុមហ៊ុននៅហុងកុងរហូតដល់ពេលដែលរំលាយទៅវិញ ខ្ញុំចង់ជម្រាបសួរតើកម្ពុជាប្រជាធិបតេយ្យទទួលបានផលចំណេញប៉ុន្មាន? ហើយដូចថា ប្រទេសណាខ្លះដែលជំពាក់ នៅជំពាក់លុយកម្ពុជាប្រជាធិបតេយ្យក្នុងពេលដែលបង្កើតក្រុមហ៊ុនហ្នឹង?

**ធ៖** ខ្ញុំសូមបញ្ជាក់ថា ការបង្កើតក្រុមហ៊ុននេះ ជានាទីរបស់គណៈកម្មាធិការពាណិជ្ជកម្ម។ ហើយខាងខ្ញុំនេះអត់មានទៅលូកលាន់អីទេ គេបង្កើតយ៉ាងម៉េចៗចំណេញខាតយ៉ាងម៉េច ក៏ខ្ញុំអត់ដឹងដែរ អត់មានបញ្ជីម្រេយឲ្យៗខ្ញុំដឹងទេបាទ។ ខាតចំណេញក៏ខ្ញុំមិនដឹង គ្រាន់តែដឹងថា ដោយសារឯកសារហ្នឹងមកបង្ហាញ ខ្ញុំជួយពន្យល់ថាមានៗបង្កើតមែន។ ហើយក៏នឹកឃើញថាមានបង្កើតមែន។ តែបញ្ជីម្រេយអីអត់មានឆ្លងតាមធនាគារទេ គឺក្រុមហ៊ុនហ្នឹងវានៅហុងកុងឯណោះ ហើយធ្វើបញ្ជីអីគេអាចរាយការណ៍ត្រឹមថ្នាក់ពាក់ព័ន្ធរបស់គេទៅ ខ្ញុំមិនដឹងថា ហើយទៅមានសល់លុយសល់កាក់ឯណា ខ្ញុំអត់បានដឹងទេបាទ។

**ស៖** ចាស សូមអរគុណ។ ខ្ញុំសួរសំណួរលោកជាចុងក្រោយ។ ខ្ញុំចង់ជម្រាបសួរលោកថា នៅក្នុងសេចក្ដីសម្រេច ៗខ្ញុំឃើញមានចំណុចមួយក្នុងទំព័រ-- ក្នុង D279/7.1 ទំព័រទី៦ ឃើញមានដាក់ “មានចាត់តាំងគណៈប្រតិភូមួយ សម្រាប់ទទួលនិងចរចា។ មានសមមិត្ត ឌឿន, សមមិត្ត គ្រិន, សមមិត្ត

សាត, សមមិត្ត ឈឿន, សមមិត្ត ហុក ការបរទេសម្នាក់ សមមិត្ត ល្អុត។ ហ្នឹងៗមានន័យម៉េចដែរលោក? លោកធ្លាប់ធ្វើការនៅក្រសួងការបរទេស ឬក៏យ៉ាងណាដែរបានដាក់ថាការបរទេសម្នាក់សមមិត្ត ល្អុត? សូមលោករៀបរាប់បញ្ហាហ្នឹងជម្រាបអង្គសវនាការឲ្យបានជ្រាបផង។

[១៤:៣៨:៤០]

**ឆ៖** បើតាមខ្ញុំចាំ ខ្ញុំមិនច្បាស់ប៉ុន្មានទេ តាំងពីពេល៧៥, ៧៦ ពេលដែលលោក ឌឿន ហ្នឹងគាត់នៅជាប្រធានពាណិជ្ជកម្ម ហើយមានគណៈប្រតិភូនរណាៗខ្ញុំមិនស្គាល់ទេ។ ហើយមានម្នាក់ខាងការបរទេស ហើយដាក់ខ្ញុំ ពេលនោះគឺខ្ញុំទើបនឹងមកហ្នឹង ហើយមកហ្នឹងដើម្បីទៅចូលរួមជួបគេហ្នឹង ដើម្បីខ្ញុំចេះកិច្ចការធនាគារ ប្រតិភូគេចេះធនាគារមក។ រួចខ្ញុំចាំ ពេលនុ៎ងណ៎ា។ សូមទោស គ្រាន់តែចាំពេលនុ៎ង ហើយខ្ញុំមិនមែននៅក្រសួងការបរទេសទេ ហើយខ្ញុំមកពីសហករណ៍មក ដោយសារគេដឹងថាខ្ញុំចេះធនាគារ ហើយខាងភាគីម្ខាងទៀតនោះ ក្នុងប្រតិភូគេមានអ្នកធនាគារមក។ ដូច្នេះគេចង់ថា ៗគេខាងនោះមានធនាគារ យើងក៏មានអ្នកចេះដែរ។ មិនមែនខ្ញុំនៅនឹងក្រសួងការបរទេសទេ។ អាហ្នឹងតាមខ្ញុំចាំអ៊ីចឹងណ៎ា! សូមទោសបាទ។

[១៤:៣៩:៤៨]

**ស៖** សូមអរគុណ។ ចុះតាមដែលលោកចាំ ពីព្រោះក្នុងឯកសារហ្នឹងបានសរសេរថា ក្រសួងការបរទេសម្នាក់ គឺសមមិត្ត ល្អុត។ ខ្ញុំចង់ជម្រាបសួរថា ក្នុងអំឡុងដែលលោករៀបរាប់អំមិញក្នុងឆ្នាំណាដែរ ដែលលោកថាលោកមកធ្វើការនៅហ្នឹងដំបូង?

**ប្រធានអង្គជំនុំ៖**

ទំនងមេធាវីថែមពាក្យដឹង? ដូចអត់មានពាក្យគឺទេ។ មើលអក្សរស្រួលបួលមើល៍! ដូចអត់មានពាក្យគឺទេ។ ក្រសួងការបរទេសម្នាក់ ដកឃ្លា សមមិត្ត ល្អុត។ អ៊ីចឹងមិនមែនការបរទេសម្នាក់ គឺសមមិត្ត ល្អុត ទេ។ អ៊ីចឹងឃ្លានេះអាចៗបន្ថែមពាក្យ។ កាលណាបន្ថែមពាក្យនាំឲ្យការសួរខ្លឹមសារវាអត់អាចស្តាប់យល់ទេ។

**លោកស្រី ស៊ីន សុវ៉ន៖**

សូមអរគុណលោកប្រធាន គឺអ៊ីចេះ។ គឺខ្ញុំបានបន្ថែម ក្រសួងការបរទេសម្នាក់ សមមិត្ត ល្អុត។

**លោក សតីម ល្អុត៖**

អំមិញខ្ញុំឆ្លើយអំមិញគឺថា ដូចខ្ញុំជម្រាបអំមិញអ៊ីចឹង គឺប្រហែលជាពេលដែលយកខ្ញុំពី

សហករណ៍មក ទៅប្រជុំហ្នឹងមានគណៈប្រតិភូ កាលនុំងដូចខ្ញុំចាំ ដូចជាចិន។ កាលនោះគេមានធនាគារ ហើយខាងខ្មែរហ្នឹង មានដូចរៀបរាប់ឈ្មោះអំមិញអ៊ីចឹង។ ហើយមានឈ្មោះ ខ្ញុំនៅហ្នឹង ប៉ុន្តែក្នុងឋានៈជាអ្នកដូចថាយល់ដឹងអំពីធនាគារ មិនមែនក្នុងឋានៈជាខ្ញុំហ្នឹងបុគ្គលិកក្រសួងការបរទេសទេ។ ខ្ញុំមិនដែល-- អត់ឲ្យសោះ មិនដែលមានការងារអីទេ។ មិនដែលមានអីជាមួយក្រសួងការបរទេស។ ខ្ញុំមកពីសហករណ៍មក មកនៅជិត ផ្ទះជិតក្រសួងឧស្សាហកម្មរបស់លោក អន នេះ ហើយដល់ក្រោយមកបានមានគណៈប្រតិភូមកអ៊ីចឹងទៅ។

[១៤:៤១:៤៣]

ហើយខ្ញុំចាំថារឿងប្រជុំប្រហែលជាដើម៧៦ ឬកណ្ដាល៧៦ហ្នឹង។ ព្រោះថា ក្រោយដែលខ្ញុំធ្វើស្រែមួយវស្សា មួយចម្រូតហើយ ច្រូតចប់រៀបចំបើងអីបានយកខ្ញុំមក។ ហើយក៏មានៗអ៊ីចឹង។ ហើយសូមបំភ្លឺប៉ុណ្ណឹងបាទ។

**ស៖** ចាស។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្ដល់កន្លែងសម្រាកនៅបន្ទប់សម្រាប់រង់ចាំរបស់សាក្សី ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ លោកមេធាវី តើលោកមានបំណងចង់និយាយអំពីបញ្ហាអីទៅ? លោកឲ្យនូវប្រធានបទ ដែលលោកមានបំណងនិយាយជាមុន ពីព្រោះយើងបានប្រាប់ហើយ យើងមិនបណ្តែតបណ្តោយឲ្យភាគីណាមួយប្រើប្រាស់ពេលវេលាដែលយើងកំណត់ឲ្យការពិភាក្សាដេញដោលនៅទីនេះ ភាគីផ្អៀតប្រើប្រាស់នូវពេលវេលានេះ ដើម្បីធ្វើសេចក្តីថ្លែងការណ៍អ្វីផ្សេងៗរំខាន ឬក៏ធ្វើឲ្យអូសបន្លាយពេលវេលារបស់អង្គជំនុំជម្រះក្នុងការគ្រប់គ្រងកិច្ចដំណើរការសវនាការនោះទៀតឡើយ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន ខ្ញុំនិយាយដោយសង្ខេបទេ ខ្ញុំមិនយកពេលពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទេ ប៉ុន្តែខ្ញុំចង់ចង្អុលបង្ហាញថា មេធាវីការពារ គឺសូមពិភាក្សាអំពីលំដាប់លំដោយនៃសំណួរនៅសប្តាហ៍នេះ ហើយមេធាវី ខៀវ សំផន គាត់ចាប់ផ្តើមមុន ហើយមេធាវីលោក អៀង សារី ក៏មិនជំទាស់ដែរ យើងមិនជំទាស់ទេ យើងយល់ស្របទៅតាមអ្វីដែលអង្គជំនុំជម្រះសម្រេច ដែលថាឲ្យមេធាវីលោក ខៀវ សំផន គាត់ចាប់ផ្តើមមុនបាទ។

[១៥:០៤:៥១]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីទទួលសិទ្ធិពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។ ចាស ខ្ញុំអស់ដូចជាអស់សំណួរសួរទៅលោកសាក្សីហើយ។ ចាស ខ្ញុំសូមបង្វែរសំណួរនោះទៅឲ្យសហភាតាខ្ញុំដែលជាមេធាវីអន្តរជាតិសួរបន្ត។ ជានេះសូមអរគុណលោកសាក្សី ចាស។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១៥:០៥:៣៦]

**លោក បាណាបេ ណោគ្វី៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរសហភាតា

ទាំងអស់ និងសាធារណជន។

**លោក បាណាបេ ណេគ្វី៖**

ជម្រាបសួរលោកសាក្សី។ លោកសាក្សី លោកស្តាប់ខ្ញុំឮទេ?

**លោក សគឹម ល្មុត៖**

ឮបាទ។

**សួរដោយលោក បាណាបេ ណេគ្វី៖**

**ស៖** បាទសូមអរគុណលោកសាក្សី។ ជាបឋម ខ្ញុំសូមជម្រាបថា ខ្ញុំមានសេចក្តីរីករាយណាស់ ដែលបានសួរសំណួរទៅកាន់លោក ដែលជាអ្នកចេះនិយាយភាសាបារាំងនោះ គឺថាអាចឲ្យយើងផ្លាស់ប្តូរយោបល់គ្នាបានងាយស្រួល ព្រោះលោកចេះភាសាបារាំងផងដែរ។ សំណួរទីមួយរបស់ខ្ញុំ គឺព្យាយាមស្វែងយល់ឲ្យបានច្បាស់អំពីខ្លឹមសារនៃ-- អំពីសកម្មភាពគោលរបស់លោកនៅធនាគារនៅចន្លោះឆ្នាំ៧៦ ដល់ឆ្នាំ៧៩។ តើយើងអាចយល់ទេថា សកម្មភាពរបស់លោកនោះគឺថាមានកម្រិតត្រឹមតែការបង្កើតបញ្ជីនាំចេញនាំចូល?

[១៥:០៧:០៦]

**លោក សគឹម ល្មុត៖**

**ឆ៖** បាទ អ៊ីចឹងមែន តែបញ្ជីហ្នឹងក៏វាមិនពេញលេញដែរ វាមិនទៅតាមលក្ខណៈ ដូចថាការនាំចេញនាំចូលលើឆាកអន្តរជាតិហ្នឹង គេធ្វើទៅតាមច្បាប់អន្តរជាតិ វាៗមិនពេញលេញទៅតាមនុ៎ងទេ។ មិនពេញលេញអ៊ីចឹងទេ។ សូមជម្រាបប៉ុណ្ណឹង អត់ពេញលេញទៅតាមដែលថាទម្លាប់អន្តរជាតិដែលគេពេលគេនាំចេញត្រូវធ្វើអី នាំចូលត្រូវធ្វើអី វាមានឈ្មោះធនាគារអ៊ីចឹង ប៉ុន្តែអ្វីៗវាមិនចូលតាមធនាគារទាំងអស់ទេ ហើយបើចូលហ្នឹងក៏វាដាច់ដោច វាមិនស្អីជាស្អីដែរ ខ្ញុំ-- អ៊ីចឹងដូចខ្ញុំជម្រាបកន្លងមក វាគ្មានបញ្ជីអីកត់ត្រាទុកដាក់ គ្មាននរណាជួយកត់ជួយអី វាម្នាក់ខ្ញុំ វា-- ហើយដល់៣០ឆ្នាំមកហើយ វាអត់បញ្ជីមើល ហើយវាស្មារតីវាភ្លេចទៅទៀត។ តែគ្រាន់តែចាំថាវាគ្មានឯកសារអីជាសំខាន់ គឺថាអាចយកមកពណ៌នានៅនេះឲ្យច្បាស់លាស់ គឺថាខ្ញុំមិនមានទេបាទ។ ជាទ្រឹស្តីវាអ៊ីចឹងហើយ វាត្រូវកត់ចូលកត់អី ប៉ុន្តែជាក់ស្តែងវាៗមិនមានអ៊ីចឹងទេបាទ។

**ស៖** សូមអរគុណលោកសាក្សីចំពោះការពន្យល់ដ៏ពេញលេញនេះ។ ហើយខ្ញុំយល់ច្បាស់ហើយឥឡូវនេះ ក៏ប៉ុន្តែខ្ញុំចង់សួរសំណួរលោកមួយចំនួនពាក់ព័ន្ធទៅនឹងការនាំចេញស្រូវ ហើយនិងអង្ករ។

តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេ ថាស្រូវ និងអង្ករនេះលោកបានធ្វើបញ្ជីត្រឹមតែទើបតែនៅខែធ្នូ ៧៨-៧៩ មែនទេ នៅក្នុងក្របខ័ណ្ឌនៃភារកិច្ចរបស់លោកនេះ?

[១៥:០៩:០៦]

**ផ៖** បាទបញ្ជីនាំចេញអង្ករហ្នឹងគឺថាខ្ញុំទើបបានឃើញ លោកព្រះរាជអាជ្ញាបង្ហាញខ្ញុំពីព្រឹកមិញទេ បញ្ជីតារាងអីផ្សេងៗនេះ។ មុនហ្នឹងមិនដែលបានឃើញដែរ ហើយពេលនោះក៏គេមិនដែលឲ្យបញ្ជីនោះមកខ្ញុំកត់ត្រាអីនៅធនាគារដែរ។ ខ្ញុំបញ្ជាក់ឡើងវិញ គឺថាបញ្ជីហ្នឹង ខ្ញុំទើបនឹងឃើញពីថ្ងៃហ្នឹង គេធ្វើរបៀបម៉េច ខាងគណៈកម្មាធិការពាណិជ្ជកម្ម គេអ្នកធ្វើ គេធ្វើរាយការណ៍ទៅត្រង់ណា ខ្ញុំមិនដឹងទេ ប៉ុន្តែអត់មានយកមកចុះបញ្ជីអីកន្លែងខ្ញុំឲ្យខ្ញុំចាំ គឺថាខ្ញុំមិនមានទេបាទ។ ហើយដូច្នេះមិនដឹងថាអង្ករស្រូវនាំទៅឯណាប៉ុន្មានៗ ក៏ខ្ញុំមិនអាចចាំបាន ព្រោះមិនដែលឃើញបញ្ជីទម្រង់ហ្នឹង ខ្ញុំមិនដែលឃើញផង។ ទើបនឹងឃើញថ្ងៃនេះ។

**ស៖** សូមអរគុណលោកសាក្សី។ យើងក៏បានកត់សម្គាល់ឃើញនៅក្នុងចម្លើយរបស់លោកផងដែរ ថាលោកមានឱកាសបាននាំគណៈប្រតិភូបរទេសទៅកាន់ខេត្តសៀមរាប ហើយនិងខេត្តកំពង់សោម តើអ៊ីចឹងមែនទេលោកសាក្សី?

[១៥:១០:៣០]

**ផ៖** បាទ ទៅមែន ប៉ុន្តែមិនមែនជាក្នុងឋានៈជាអ្នកដឹកនាំទៅទេ គ្រាន់ជាអ្នក ច្រើនតែទៅបកប្រែទេបាទ។ មិនមែនជាខ្ញុំជាអ្នកនាំគេទៅទេ គឺគេឲ្យខ្ញុំទៅ ដើម្បីឲ្យជួយបកប្រែជាភាសាបារាំង។

**ស៖** យើងខ្ញុំយល់ហើយលោកសាក្សី។ គឺខ្ញុំមិននិយាយដល់ថា លោកជាប្រធានទេ ខ្ញុំគ្រាន់តែចង់ដឹងថា តើនៅក្នុងឱកាសដែលលោកនាំទៅនោះ តើគណៈប្រតិភូនោះ គាត់មានស្នើសុំទៅទស្សនកិច្ចនៅតាមសហករណ៍អីដែរទេ?

**ផ៖** ខ្ញុំមិនដឹងថា គេស្នើ មិនស្នើទេ ប៉ុន្តែក្នុងពេលនោះ ខ្ញុំមិនចាំបានថា ក្រៅពីទៅមើល ដូចថាកំពង់សោម ឬសៀមរាប អ៊ីចឹងណ៎ា គេនាំទៅមើលសហករណ៍ទៀតអ៊ីចេះ គឺថាមិនឃើញទៅទេ ខ្ញុំអត់- - មិនឃើញទៅទេ បាទ។ ទៅហើយមកវិញ អត់មានចូលសហករណ៍នេះ សហករណ៍នេះក៏ដឹងដែរបាទ ឬក៏នៅពេលណាផ្សេង ដែលគ្មានខ្ញុំ ក៏ខ្ញុំមិនដឹងដែរ តែពេលហ្នឹង អត់មានទេបាទ។

[១៥:១២:០៥]

**ស៖** នៅតាមផ្លូវពីភ្នំពេញ ទៅកាន់កន្លែងផ្សេងៗ ដូចជានៅតាមទីក្រុងពីរនេះ គឺសៀមរាប និង

កំពង់សោមនោះ។ បើតាមការចងចាំរបស់លោក តើមានបញ្ហាពាក់ព័ន្ធទៅនឹងខាងស្បៀងអាហារនៅក្នុងតំបន់ទាំងនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេ ពីព្រោះថាពេលយើងចេញភ្នំពេញ ឧបមាថាទៅកំពង់សោម យើងបើកឡានរហូតដល់កំពង់សោមតែម្តង។ ហើយបើថាចង់មានឈប់សម្រាកភេសជ្ជៈអីតិចតួច គេមានកន្លែងគេឈប់ត្រង់ហ្នឹង មន្ទីរគេមួយកណ្តាលផ្លូវអ៊ីចឹងទៅ ហៅថា សភាពការណ៍តាមសហករណ៍ តាមជនបទ ដូចមិនសង្កេតឃើញអ្វីទេបាទ។ ទៅត្រង់ ទៅមកតែម្តង អត់មានចូលមើលឯណាទៀតទេបាទ។

[១៥:១៣:១៨]

**ស៖** បើតាមលោកចាំនៅពេលនោះ តើលោកមានស្គាល់អ្នកណាដែលគាត់បានរៀបរាប់លោកនិយាយប្រាប់លោក ដូចថាមានបញ្ហាខាងផ្នែកហូបចុក មានការខ្វះខាតអីដែរឬទេ បើតាមការចង់ចាំរបស់លោកនោះ?

**ឆ៖** គ្មានទេបាទ ពីព្រោះពេលគណៈប្រតិភូអ៊ីចឹង គ្មានអ្នកណាមកជិត មកបៀតអី មកនិយាយលេងមកអី បាទអត់មានទេ គឺថាមានតែក្នុងគណៈប្រតិភូហ្នឹង គ្មានអ្នកណាមកនិយាយអីឲ្យយើងដឹងរឿងអី ផ្សេងៗទេ ព្រោះសហករណ៍អីណា គេមិនដឹងនៅឯណាផង យើងតាមផ្លូវមិនឃើញផង។ ហើយគ្មានអ្នកណាមកនិយាយរឿងរ៉ាវអីប្រាប់ទេបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ពាក់ព័ន្ធទៅនឹងសហករណ៍ដែលគ្រួសាររបស់លោករស់នៅហើយនិងខ្លួនលោកផ្ទាល់ ក៏បានលោកទៅញឹកញាប់ដែរ។ តើលោកមានឃើញការធ្លាក់ចុះនៃស្ថានភាពហូបចុកនៅក្នុងសហករណ៍ដែលលោកទៅហ្នឹងទេ?

[១៥:១៤:៥០]

**ឆ៖** សហករណ៍ហ្នឹង មិនមានសង្កេតឃើញការធ្លាក់ចុះអីទេ ព្រោះថាវាមានលក្ខណៈពិសេសអ៊ីចេះសហករណ៍ហ្នឹង។ នៅៗត្រង់នោះ វាមានបឹង យើងរកត្រី គេមានកម្លាំងរកត្រី ហើយក្នុងសហករណ៍ហ្នឹង មានចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ ចិញ្ចឹមទា មានស្រូវខ្លួនឯង។ ដូច្នេះ ឃើញដូចជាកាលហ្នឹងមិនមានការខ្វះខាតរឿងហូបចុកអីទេ នៅហ្នឹងរហូតដល់ខ្ញុំចេញមកនៅភ្នំពេញហើយ ទៅម្តងម្កាលក៏ឃើញដូចជាមានជីវភាពធម្មតា គេហូបត្បិតត្បៀតមែន តែថាវាមិនខ្វះទេនៅនោះ ព្រោះបន្លែដាំខ្លួនឯង ត្រីជិតបឹងហ្នឹងរកខ្លួនឯង ហើយមានគោមានជ្រូកមានអីគេកាប់ហូបអីអ៊ីចឹងទៅ។ ដោយឡែកសហករណ៍ខ្ញុំនិយាយចំពោះតែសហករណ៍មួយហ្នឹងទេ កន្លែងដទៃទៀត ខ្ញុំមិនបានដឹងទេបាទ ព្រោះមិន

ដែលទៅផង។

[១៥:១៦:០៥]

**ស៖** សូមអរគុណលោកសាក្សី។ បើតាមចម្លើយរបស់លោក គឺថា បើតាមការកត់សម្គាល់របស់លោកនៅសម័យនោះ គឺថាមានស្រូវអង្ករដែលបាននាំចេញ គឺមានន័យថា គឺជាចំនួនលើសមែនទេ តើវាជាសំណល់ពីសហករណ៍ផ្សេងៗមែនទេ? បានន័យថា ជា*អតិរិក* មកពីសហករណ៍ផ្សេងៗ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំមិនអាចថាបានទេ ពីព្រោះខ្ញុំមិនដឹងថា នៅតាមកសិករផ្សេងៗហ្នឹង គឺផលិតស្រូវអង្ករបានប៉ុន្មាន ហើយមានជើងលេខឯណាអីណា ខ្ញុំមិនអាចជម្រាបបានទេ ព្រោះគ្មានស្អី យកមកៗថាជម្រាប ហើយចេញហ្នឹង គឺថាឯកសារដែលខ្ញុំឃើញពីព្រឹកមិញហ្នឹង ហើយត្រង់គេទូទាំងប្រទេសហ្នឹង ធ្វើស្រូវបានអីប៉ុន្មានគឺថា ខ្ញុំគ្មានស្ថិតិ គ្មានស្អីដឹងទេបាទ។

[១៥:១៧:២២]

**ស៖** សូមអរគុណចំពោះចម្លើយដ៏ស្មោះត្រង់នេះលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមចូលទៅដល់ឯកសារដែលខាងសហព្រះរាជអាជ្ញា បង្ហាញជូនលោកកាលពីព្រឹកមិញនេះ។ ខ្ញុំមិនចង់បង្ហាញឯកសារនេះឡើងវិញទេ ខ្ញុំគ្រាន់តែចង់ផ្ដល់លេខ ERN ឯកសារនេះ គឺជាកំណត់ហេតុនៃកិច្ចប្រជុំដែលលោកបានចូលរួម នៅខែធ្នូ គឺសូមទោស គឺនៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៨ ជាមួយនឹងគណៈប្រតិភូកូរ៉េ ដែលមានលេខ ERN ជាភាសាបារាំង 00753603, ERN ជាភាសាអង់គ្លេស 00711446, ERN ជាភាសាខ្មែរ 00188530។ នេះជាកិច្ចប្រជុំដែលលោកបានចូលរួមជំនួសឲ្យលោក វិទ្ធ តើលោកចាំទេ ថាពេលនោះលោកមានគ្នាបីនាក់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនោះ? ឥឡូវនេះ ខ្ញុំចង់សួរសំណួរលោក ពាក់ព័ន្ធនឹងបុគ្គលដែលបានចូលរួមនៅក្នុងគណៈប្រតិភូកម្ពុជាជាមួយលោក គឺមាន សួន ហើយនិងមានម្នាក់ទៀតឈ្មោះដូចជា ប៉ង តើលោកមានចាំទេ ថាលោកបានពិភាក្សាពីចំណុចនេះជាមួយសហព្រះរាជអាជ្ញា? គឺឈ្មោះ ផន សូមទោស។

[១៥:១៩:១៨]

**ឆ៖** បាទ ឯកសារនេះ ខ្ញុំបានជជែកពីព្រឹកមិញហើយ ហើយក៏បានពន្យល់ម្ដងហើយ ហើយខ្ញុំគ្រាន់តែចង់និយាយឡើងវិញអ៊ីចេះ គឺថាខ្ញុំបញ្ជាក់ថា កាលណាប្រជុំជាមួយគណៈប្រតិភូកូរ៉េ ខាងខ្មែរយើងត្រូវមានអ្នកណាម្នាក់ចេះបារាំង ដើម្បីបកប្រែ ឲ្យខ្ញុំទៅប្រជុំហ្នឹងអ្ហែ មិនដឹងខ្ញុំគ្រាន់តែជាអ្នកជួយ

បកប្រែក៏មិនដឹង ហើយអ្នកដែលឈ្មោះ ផន និងឈ្មោះ សួន នេះ ខ្ញុំមិនច្បាស់ទេ ប្រហែលជាកម្មា-ភិបាលថ្នាក់មធ្យម ថ្នាក់អីដែលនៅក្នុងក្រសួងពាណិជ្ជកម្ម ដែលគេដឹងរឿងរ៉ាវខ្លះៗ ព្រោះនៅនេះនិយាយពីរឿងកូរ៉េ គេថាចង់បានស្អី ហើយយើងនេះ-- តែប៉ុណ្ណឹង។ ហើយក៏មិនមាននិយាយច្បាស់ថា ខ្ញុំជាហ្នឹងជាប្រធាន ហើយបើតាមទម្លាប់គឺថា អាចខ្ញុំទៅហ្នឹងជាៗអ្នកបកប្រែទេក៏មិនដឹង។ ពីព្រោះខ្ញុំមិនអាចយករឿងពាណិជ្ជកម្មទៅនិយាយបាន ព្រោះខ្ញុំមិនដឹងរឿងអីផង។ នេះអាចទៅគ្រាន់តែជាអ្នកបកប្រែឲ្យអ្នកពីរនាក់នេះក៏មិនដឹង។ ព្រោះការងាររាក់ជ្រៅរបស់ពាណិជ្ជកម្ម ខ្ញុំមិនដឹងទេត្រង់ថានិយាយជាមួយប្រតិភូនោះទិញអីលក់អី អាហ្នឹងសង្ស័យថាខ្ញុំទៅហ្នឹងជាបកប្រែ ហើយបើជាមួយកូរ៉េច្រើនតែមានខ្ញុំជាអ្នកបកប្រែបាទ។ ប៉ុន្តែមិនដែលទៅហើយជាប្រធានគណៈប្រតិភូអីទេបាទ។ អានេះសូមបញ្ជាក់ប៉ុណ្ណឹងបាទ។

[១៥:២១:០៨]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមិនចង់ដឹងថាលោកជាប្រធានគណៈប្រតិភូ ឬក៏មិនប្រធានអីទេ នៅក្នុងកិច្ចប្រជុំនោះ គឺខ្ញុំគ្រាន់តែចង់ឲ្យលោកពន្យល់ឲ្យបានច្បាស់ថា តើលោកដឹងថា ផន ហើយ និង សួន នោះគឺជាគណៈកម្មាភិបាលរបស់ក្រសួងពាណិជ្ជកម្មនោះដោយរបៀបណា? តើលោកដឹងព័ត៌មានមកពីណាដែរថា គាត់ជាកម្មាភិបាលថ្នាក់កណ្តាលមកពីក្រសួងពាណិជ្ជកម្មនុ៎ង?

**ផ៖** ពីព្រោះៗថា អ្នកទាំងអស់ហ្នឹងដូចជាធ្វើការនៅក្នុងក្រសួងពាណិជ្ជកម្មក្រៅប្រទេសហ្នឹង។ មិនដឹងជាកម្មាភិបាលកម្រិតណាទេ ប៉ុន្តែក៏មិនមែនសមាជិកគណៈកម្មាធិការក្រសួងទាំងមូលដែរ។ តែជាអ្នកដូចថាយើងថ្នាក់ខាងក្រោមហ្នឹងចេះបច្ចេកទេស ដឹងរឿងរ៉ាវទៅ ហើយខ្ញុំក៏ភ្លេចមុខភ្លេចគាត់អីហើយ ភ្លេចឈ្មោះហើយ។ ផន, សួន ហ្នឹង។ តែគាត់មិនមែនជាសមាជិកគណៈកម្មាធិការពាណិជ្ជកម្មទេអាច-- ខ្ញុំស្មានទៅអាចជាអ្នកកម្មាភិបាលថ្នាក់កណ្តាល ដូចយើងឥឡូវនេះជាអ្នកថ្នាក់ការិយាល័យថ្នាក់អីចឹង តែការងារបច្ចេកទេសអីដឹងដែរ។ ហើយត្រង់ឥឡូវគាត់ទៅណាមកណា គាត់នៅរស់ ឬក៏អីខ្ញុំក៏មិនបានដឹងទេបាទ។

[១៥:២២:៥១]

**ស៖** ចំពោះព័ត៌មាននោះ តើជាព័ត៌មានកើតចេញមកពីការកត់សម្គាល់របស់លោកផ្ទាល់ ឬក៏មានអ្នកណាមួយផ្ញើជូនឲ្យលោក ឬក៏មានអ្នកណាផ្តល់ព័ត៌មានជូនលោកអំពីភារកិច្ចរបស់អ្នកបច្ចេកទេសនេះ នៅសម័យនោះ?

**ឆ៖** បាទគ្មាននរណាប្រាប់ខ្ញុំទេ ប៉ុន្តែដល់ទៅប្រជុំហ្នឹង កាលដល់និយាយទៅ យើងដឹងថាអ្នកហ្នឹងវាៗ គេនៅខាងផ្នែកហ្នឹង យើងៗគេនៅខាងផ្នែកពាណិជ្ជកម្មហ្នឹងហើយ ប៉ុន្តែអត់មាននរណាថាប្រកាសគាត់ថាថ្នាក់ប៉ុន្មានៗ ក៏មិនមានទេបាទ។ តែដល់ទៅធ្វើការទៅឃើញថា គាត់ហ្នឹងវាៗនៅក្នុងៗក្រសួងពាណិជ្ជកម្មហ្នឹងហើយ ពីរនាក់នុ៎ង។

[១៥:២៤:០៤]

**ស៖** នៅពេល-- ក្នុងសក្ខីកម្មរបស់លោកនោះលោកបានលើកឡើងនូវឈ្មោះពីរជាញឹកញាប់ គឺឈ្មោះ អន ហើយនិង--

**អ្នកបកប្រែ៖**

លោកប្រធាន អ្នកបកប្រែស្ដាប់ឈ្មោះមួយទៀតអត់បាន សូមឲ្យគាត់ជួយ-- សហការីជាខ្មែរគាត់ជួយ។

**លោក បាណាបេ ណេគ្វី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមមេធាវីសួរសំណួរចុងក្រោយអំមិញសាជាថ្មី ហើយសួរឲ្យបានយឺត ហើយនិងអាននូវឈ្មោះមនុស្សដែលមានការពាក់ព័ន្ធនឹងសំណួរនេះឲ្យបានច្បាស់។ ហើយក្នុងករណីមិនច្បាស់អាចសហការីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអាចនិយាយឲ្យចំនូវឈ្មោះមនុស្សដែលពាក់ព័ន្ធនឹងការតាំងសំណួរនេះ។ សូមអញ្ជើញ!

[១៥:២៥:១៥]

**លោក បាណាបេ ណេគ្វី៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងអនុវត្តតាម។

**សួរដោយលោក បាណាបេ ណេគ្វី៖**

**ស៖** ខ្ញុំនិយាយអំពីឈ្មោះ អន គឺថាមាននៅក្នុងកំណត់ហេតុនេះ គឺសរសេរ AN ប៉ុន្តែខ្ញុំមិនដឹងអានជាខ្មែរម៉េចទេ? ខ្ញុំសូមអានថា ឈ្មោះ អន។ ហើយមួយទៀត គឺឈ្មោះ ប្រាង គឺ ម៉ី ប្រាង គឺ “M-E-Y, P-R-A-N-G” ម៉ី ប្រាង។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកចាំទេ នៅពេលលោកផ្ដល់សក្ខីកម្មនៅទីនោះ លោកបានលើកឈ្មោះពីរនាក់នេះឡើង គឺឈ្មោះ អន និងឈ្មោះ ម៉ី ប្រាង?

**លោក សគីម ល្មុត៖**

**ឆ៖** បាទ ចំពោះ អន ហ្នឹង គឺដូចខ្ញុំបានជម្រាបរួចមកហើយ នៅពេលដែលខ្ញុំ គេយកខ្ញុំមកពីសហករណ៍ មកៗភ្នំពេញហ្នឹងគឺថា នៅស្នាក់នៅកន្លែងក្បែរ-- យើងថា ឥឡូវក្រសួងឧស្សាហកម្មចុះ ឲ្យស្រួលនិយាយ គឺថាមានលោក អន ហ្នឹងជាប្រធាននៅហ្នឹង។ ហើយហ្នឹង អន ហ្នឹង។ ហើយដល់ក្រោយមក ពេលដែលខ្ញុំមកធ្វើការ-- រើកន្លែងមកនៅត្រង់កន្លែងក្រសួងការពារជាតិរាល់ថ្ងៃនេះ ទល់មុខហ្នឹងមានកន្លែងរទេះភ្លើង។ រទេះភ្លើងឮគេថា នៅហ្នឹងមានមិត្ត ប្រាង ធ្វើប្រធាននៅហ្នឹង តែខ្ញុំមិនដែលបានជួបគាត់ទេ។ ដូចខ្ញុំបានជម្រាបន៉ែ អ្នកស៊ើបអង្កេតពេលនោះ ថាខ្ញុំឮឈ្មោះអ៊ីចឹង។ ឈ្មោះ ប្រាង នេះជាប្រធានរទេះភ្លើង តែខ្ញុំមិនមាន-- មិនដែលបានជួបគាត់ទេ មិនដែលបានប្រជុំអីជួយគាត់ ព្រោះគ្មានការងារអីត្រូវៗពាក់ព័ន្ធជាមួយគាត់ទេ ប៉ុន្តែគ្រាន់ថាកន្លែងវានៅទល់មុខគ្នាម្ខាងម្នាក់អ៊ីចឹង។ គេនៅខាងរទេះភ្លើង ខ្ញុំនៅខាងនេះ ឈ្មោះ ប្រាង ហ្នឹងបាទ។

[១៥:២៧:៣០]

**ស៖** សូមអរគុណចំពោះការពន្យល់បំភ្លឺនេះ។ លោកសាក្សីតើលោកអាចដឹងទេថា មុនពេលលោកចេញដំណើរពីភ្នំពេញនៅខែមករា ឆ្នាំ៧៩ នោះ សូម-- គឺ អាន ក៏នៅជាមួយលោកដែរតើមែនទេ?

**ឆ៖** អត់ទេ មិនដែលនៅជាមួយខ្ញុំទេបាទ។ នៅពេលខ្ញុំមកពីសហករណ៍ នៅជាមួយគាត់មួយភ្លែតទៅ តែដល់បែកគ្នាទៅគាត់ ខ្ញុំៗអត់ដែលនៅជាមួយគាត់ មិនមែនធ្វើការនៅក្រោមគាត់ ឬអែបជាមួយគាត់ទេ ខ្ញុំសហការតែជាមួយខាងពាណិជ្ជកម្មទេ ខាងគាត់នៅឧស្សាហកម្មនោះ វាសនាគាត់យ៉ាងម៉េចៗ ខ្ញុំមិនបានដឹងទេ បាទ។ ហើយពេលដែលចេញពីភ្នំពេញនោះ រឹតតែលែងដឹងទៀត។ អត់គាត់មានគាត់នៅជិតខ្ញុំផង អត់មានទេបាទ អន ហ្នឹងបាទ។

[១៥:២៨:៤៦]

**ស៖** លោកសាក្សីលោកបានឆ្លើយទៅនឹងសហព្រះរាជអាជ្ញា ក៏ដូចជាខាងដើមបណ្តឹងរដ្ឋប្បវេណីថា នៅពេលដែលលោកកត់សម្គាល់ឃើញថាមានការបាត់ខ្លួននៅក្នុងផ្នែករបស់លោកនោះ ធ្វើឲ្យលោកមានការភ័យខ្លាច គឺមានន័យថា នៅក្នុងផ្នែកពាណិជ្ជកម្មរបស់លោកនោះ។ សំណួររបស់ខ្ញុំគឺចង់ដឹងថា នៅពេលដែលលោកបានឃើញអ្នកទាំងអស់នោះ តើហេតុអ្វីបានជាលោកខ្លាចថា លោកគិតថាមានរឿងអីកើតឡើងទេ?

**ឆ៖** លោកប្រធានខ្ញុំសូមបញ្ជាក់ឡើងវិញថា ខ្ញុំមិនមែននៅក្នុងក្រសួងពាណិជ្ជកម្មទេ នៅគណៈកម្មាធិការពាណិជ្ជកម្មទេ។ ហើយត្រង់ថា បាត់ខ្លួនប៉ុន្មាននាក់ ២០, ៣០នាក់ នុំងគឺថា ខ្ញុំមិនដែលបានដឹងមុនទេ។ ទើបមកដឹង អឺ! ពេលសវនាការនេះទេ ដែលយកឯកសារមកឲ្យខ្ញុំមើល ពីមុនខ្ញុំអត់ដឹងទេ។ ហើយដែលថា ខ្ញុំខ្លាច បារម្ភនោះ គឺថាៗនៅក្នុងក្រសួងហ្នឹងមានឃើញដូចថា គេម្នាក់មិនៗ-- ឈប់ធ្វើការអីចឹងទៅ បារម្ភទៅតាមបរិយាកាសហ្នឹង ហើយថាឲ្យខ្ញុំភ័យខ្លាចដោយសារប៉ុន្មាន២០នាក់ហ្នឹងៗខ្ញុំអត់ដឹងទេ រឿងពេលនោះខ្ញុំអត់ដឹងទេ។ ហើយអ្នកប៉ុន្មាននាក់នោះ ទើបមកឃើញឯកសារថ្មីៗនេះទេណា។ ដូច្នេះ មិនៗសំអាងការព្រួយបារម្ភខ្ញុំទៅលើប៉ុន្មាននាក់នោះទេ ខ្ញុំអត់ៗបានដឹងទេ អត់បានដឹងច្បាស់ទេ។ អានេះខ្ញុំសូមបញ្ជាក់ៗហើយម្តងទៀត ឯកសារដែលផ្ញើទៅស-២១ សអី គឺថា ខ្ញុំមិនបានដឹងសោះ ទើបមកឃើញពេលសវនាការនេះ។

[១៥:៣០:៥២]

**ស៖** បាទសូមអរគុណ។ បាទ អ្វីដែលលោកនិយាយនេះ គឺថាយើងទទួលបានហើយ ក៏ប៉ុន្តែទន្ទឹមនឹងហ្នឹង ខ្ញុំចង់ៗសួរលោកថា តើនៅពេលដែលលោកដើរហើរដោយជិះកង់នៅទីក្រុងភ្នំពេញនោះ តើលោកធ្លាប់ទៅឃ្លាំងរដ្ឋនៅគីឡូម៉ែត្រ៦ ក្នុង-- ដូចដែលលោកបាននិយាយជាមួយសហព្រះរាជអាជ្ញាដែររទេ? តើលោកធ្លាប់បានទៅទីនោះដែរឬទេ?

**ឆ៖** អារឿងហ្នឹងសូមញែកជាពីរចុះ គឺថាចំពោះឃ្លាំងៗគីឡូលេខ៦ វាឈ្មោះវាតាំងពីដើមមកនៅម៉ុំរ៉ាវទេះភ្លើងនោះ។ ហើយខ្ញុំមិនបានទៅទេឃ្លាំងហ្នឹង គ្រាន់តែស្គាល់ឈ្មោះ ប៉ុន្តែកាលសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គេយកដាក់ឈ្មោះដដែលហ្នឹង ឃ្លាំងហ្នឹង ព្រោះអាហ្នឹងវាមានឃ្លាំងអង្ករ ឃ្លាំងអីមានស្រាប់ ហើយតែរឿងដើរហើរហ្នឹងមិនមានបានន័យថា ខ្ញុំដើរហើរស្រេចតែចិត្តទេ គឺថាខ្ញុំទៅសហករណ៍ទៅតាមផ្លូវណា គេឲ្យកង់មួយខ្ញុំជិះ ខ្ញុំជិះពីភ្នំពេញតាមផ្លូវមុនីវ៉េតហ្នឹង ទៅឆ្លងស្ពានទៅស្ទឹងមានជ័យ ទៅសហករណ៍ទៅ។ អត់ៗបានវៀចបែរ បែរឆ្វេងបែរស្តាំ ងាកនេះនោះទេ។ គឺថាទៅព្រឹកឡើងទៅដល់ថ្ងៃល្ងាចអីចឹងទៅ តាមតែផ្លូវហ្នឹង មកវិញមកតាមផ្លូវហ្នឹង។ ព្រោះថាវៀចវេរមានគេសួរកន្លែងយើង សួរថាអាំឯង ពួងឯមកហ្នឹងមានការអី? ដូច្នេះខ្ញុំមិនអាចថាសេរីហើយ ថាឲ្យសេរីដើរទៅសហករណ៍ ខ្ញុំផ្លៀតទៅរកនេះរកនោះ សួរអ្នកនេះស្អីហ្នឹងអត់បានទេបាទ។ ហ្នឹងគឺជម្រាបថា ទៅសហករណ៍ៗ មកវិញៗ មិនមែនដើរហើរហ្នឹងថា មានសិទ្ធិដើរហើរស្រេចតែចិត្តទេ។ ហើយឃ្លាំងហ្នឹងឮតែឈ្មោះឃ្លាំងគីឡូលេខ៦ វាមានឈ្មោះហ្នឹងតាំងពីដើមមក ហើយជាឃ្លាំងៗគេដាក់ស្រូវ គេដាក់

អង្គរតាំងពីដើមមក។ ត្រង់ថាខ្ញុំមិនដែលទៅបានទៅចូលមើលពេលសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គេដាក់អីៗខ្ញុំមិនដែលបានទៅទេ។ អាហ្នឹងវាជាការងាររបស់ពាណិជ្ជកម្ម។

[១៥:៣៣:២៣]

**ស៖** បាទ សូមអរគុណពីការពន្យល់ទាំងអស់នេះ។ លោកសាក្សីតើលោកអាចនិយាយបានទេថាលោកទៅកំពង់សោមនោះ ញឹកញាប់ប៉ុនណាដែរ ដើម្បីផ្ទៀងផ្ទាត់នូវការដាក់បន្ទុក ស្រូវដែលត្រូវនាំចេញទៅក្រៅនោះ?

**ឆ៖** អាហ្នឹងគឺខ្ញុំសូមវែកញែកដែរ ព្រោះរឿងនាំចេញស្រូវទៅពេលណាៗ ខ្ញុំអត់បានទៅជាមួយទេ អត់ដឹងនាំថ្ងៃណា ខែណា ហើយបញ្ជីហ្នឹងក៏ទើបនឹងឃើញពេលសវនាការហ្នឹងដែរ។ ហើយថាទៅញឹកញាប់ពេលណានោះ គឺថាជួនកាលមានគណៈប្រតិភូ ដូចថាប្រទេសយូហ្គោស្លាវី ប្រទេស រ៉ូម៉ានីមក គេត្រូវការទៅមានការអីទៅនុ៎ង ក៏ទៅជាអ្នកបកប្រែ មិនមែនទៅត្រួតបញ្ជី ត្រួតអីទេ អត់មានទេបាទ។ ហើយក៏មិនជាញឹកញាប់អីទេ យូរៗមានម្តងម្កាលអីអ៊ីចឹង។ មិនមែនដូចយើងឥឡូវ គណៈប្រតិភូស្រុកយើងសកម្មភាពទៅ វានេះនោះ គឺវាមានគណៈប្រតិភូច្រើនទេ។ មានប្រទេសពីរបីហ្នឹង។

[១៥:៣៤:៥៤]

**ស៖** ប្រហែលជាខ្ញុំយល់សំណួររបស់លោកមិនច្បាស់លាស់ សហការីរបស់ខ្ញុំអម្បាញ់មិញនេះនៅពេលដែលលោកនិយាយថា លោកក៏ទៅកំពង់សោមជាញឹកញាប់ដែរ ដើម្បីចូលរួមនៅក្នុងការដាក់ៗទំនិញចូលក្នុងកប៉ាល់។ តើលោកបានឆ្លើយអ៊ីចឹងដែរឬទេ អម្បាញ់មិញនេះ? ឬក៏ខ្ញុំស្តាប់ច្រឡំទេ?

**ឆ៖** ខ្ញុំធ្លាប់បានឆ្លើយអ៊ីចេះពីថ្ងៃមុន គឺថាខ្ញុំនៅពាណិជ្ជកម្មនេះ-- អ៎! នៅជិតក្រសួងពាណិជ្ជ ជួនកាលជួយអ្នកដែលធ្វើការពាណិជ្ជកម្ម ធ្វើបែបបទយ៉ាងណាៗ ដើម្បីដាក់ទំនិញក្នុងកប៉ាល់ ក្នុងអីមានជាជួយជាៗ បង្ហាញពីបែបបទធ្វើ ប៉ុន្តែត្រង់ថា ដល់ពេលគេយកទំនិញទៅ គឺខ្ញុំមិនដែលទៅៗទេ។ ហើយដែលថាជាមួយគណៈប្រតិភូ ខ្ញុំថា ញឹកញាប់ប្រហែលវាខុសហើយ ព្រោះថាគណៈប្រតិភូមិនច្រើនប៉ុន្មាន ពេលណាមានត្រូវការបកប្រែ អានេះបានខ្ញុំទៅ។ ហើយដូចថា យូហ្គោ មកអ៊ីចឹង វាមិនមែនមួយឆ្នាំមកបួនប្រាំដងឯណា។ មកដងពីរដង អ៊ីចឹងទៅ។ អឺ! រ៉ូម៉ានី អីមកដងអ៊ីចឹង។ ដូច្នេះ ដូចខ្ញុំថា ញឹកញាប់ហ្នឹង មិនមានបានន័យថា ច្រើនហួសហេតុនោះទេបាទ។

ហើយបញ្ជាក់ម្តងទៀត គឺថាពេលចុះទំនិញ ខ្ញុំមិនដែលទៅទេ។ អាហ្នឹង គឺខាងភ្នាក់ងារខាងគេផ្នែកពាណិជ្ជកម្មក្រៅប្រទេសមិនដឹង ក្នុងប្រទេសមិនដឹងទេ គេទៅកំពង់ផែហ្នឹង។ ហើយខ្ញុំគ្រាន់តែ

ជួយប្រាប់គេហ្នឹង ថាត្រូវធ្វើឯកសារយ៉ាងណាៗ គេធ្វើទៅ។ ត្រង់ថា ខ្ញុំទៅកត់ត្រាមើលទំនិញ ចូលប៉ុន្មាន? ចេញប៉ុន្មាន? ខ្ញុំមិនបានទៅមើលទេបាទ។

[១៥:៣៧:០២]

**ស៖** បាទ សូមអរគុណលោកសាក្សី។ បើតាមលោកចាំ លោកសាក្សី ដោយហេតុថានៅសម័យថានោះ លោកមានលទ្ធភាពក្នុងផ្លាស់ទីនៅក្នុងទីក្រុងភ្នំពេញ តើលោកបានសង្កេតថា គ្រួសារមួយចំនួនអាចមកទីក្រុងភ្នំពេញ ហើយអាចមកតាំងស្នាក់នៅទីក្រុងភ្នំពេញបានវិញដែរឬទេ នៅចន្លោះឆ្នាំ៧៥ នោះ ដល់៧៩?

**ឆ៖** បាទ ខ្ញុំមិនអាចឆ្លើយបានទេបាទ ពីព្រោះនៅភ្នំពេញមែន ប៉ុន្តែមិនមែនដើរហើរទៅកន្លែងនេះកន្លែងនោះបានទេ។ ដឹងថាពីកន្លែងដែលយើងនៅ ហើយទៅលេងគ្រួសារម្តងម្កាល ត្រង់ថាគ្មានអ្នកណាមានសិទ្ធិមកនៅកន្លែងណាៗ ខ្ញុំមិនអាចបញ្ជាក់ជូនបានទេ។

**ស៖** បាទសូមអរគុណ។ លោកបានប្រាប់អម្បាញ់មិញថា លោកមានទំនាក់ទំនងជាយូរមកហើយជាមួយលោក អៀង សារី ហើយនិងបុគ្គលផ្សេងទៀត ដែលលោកបាននិយាយអម្បាញ់មិញនេះ។ សំណួរខ្ញុំដូចតទៅនេះ បើតាមលោកចាំ តើលោកធ្លាប់បានចូលរួមក្នុងពិធីការរវាងលោក អៀង សារី ហើយនិងអ្នកស្រី អៀង ធីរិទ្ធ នៅសម័យនោះដែរឬទេ នៅពេលដែលលោកនៅវ័យក្មេងនោះ?

[១៥:៣៨:៥៨]

**ឆ៖** ខ្ញុំមិនចាំថា បាន ឬមិនបានទេ។ ខ្ញុំមិនចាំទេបាទ ហើយតាមខ្ញុំមើលទៅ គាត់ដូចជាការគ្នានៅស្រុកបារាំងណោះ។ ខ្ញុំនៅស្រុកខ្មែរ ខ្ញុំមិនរួមទេ គាត់-- ខ្ញុំមិនបានរួមទេ បាទ។

**ស៖** បាទ ជាការពិតណាស់ គឺថារយៈពេលកន្លងទៅច្រើនហើយ តើលោកគិតថា លោកត្រូវ-- បើសិនជាលោកបានចូលរួចក្នុងពិធីការរបស់ពួកគាត់នោះ តើលោក-- ព្រោះអំមិញនេះ លោកនិយាយថា លោកមិនប្រាកដថាខ្លួនហ្នឹងបានចូលរួមក្នុងពិធីរៀបការរបស់គាត់ទាំងពីរនាក់នោះទេ។ តើប្រសិនជាលោកបានចូលរួមនោះ តើលោកគិតថា លោកអាចចាំទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរទេ! សំណួរបែបឧបមាណវិធី អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសាក្សីឆ្លើយតបទេ ពីព្រោះវាមិនអាចនាំឲ្យស្វែងរកការពិតបានឡើយ។

**លោក បាណាបេ ណេគ្វី៖**

លោកប្រធាន មិនបញ្ហាអ្វីទេ ខ្ញុំចោទសំណួរផ្សេងទៀត។

**សួរដោយលោក បាណាបេ ណេគ្វី៖**

**ស៖** លោកសាក្សី លោកបានលើក-- និយាយអំពីលោកឈ្មោះ គ្រិន ដែលទទួលបន្ទុកកំពង់ផែកំពង់សោម។ ហើយលោកក៏បានលើកឡើងផងដែរថា លោកបានជួបគាត់នៅសម័យនោះ នៅពេលដែលគាត់គ្រប់គ្រងនៅកំពង់ផែកំពង់សោម តើលោកអាចបញ្ជាក់បានទេថា តើលោកមានឱកាសជួប ឬក៏អមដំណើរដោយលោក គ្រិន នោះប៉ុន្មានដងដែរនៅសម័យនោះ?

**លោក សគីម ល្មុត៖**

**ឆ៖** ខ្ញុំសូមៗបញ្ជាក់ថា ខ្ញុំទៅស្គាល់គាត់នៅកន្លែងនោះ ដោយសារទៅជាមួយគណៈប្រតិភូសេដ្ឋកិច្ច ពាណិជ្ជកម្ម ហើយបរទេសហ្នឹង ហើយក៏មានឱកាសជួបគាត់ទៅ ហើយបានដឹងថាគាត់ហ្នឹងជាប្រធានកំពង់ផែ។ ហើយត្រង់ថាប៉ុន្មានដងៗ ខ្ញុំមិនចាំទេ។ បាទ គ្រាន់ថា បានជួប ហើយក៏ដឹងថាគាត់ទេ ជាប្រធានផែឈ្មោះ គ្រិន ហើយពីមុនមក ក៏មិនដែលស្គាល់គ្នាដែរទេ។

**ស៖** តើលោកអាចដឹងដែរឬទេ លោកសាក្សីថា នៅពេលណាដែលគាត់ត្រូវបានបញ្ជូនទៅទីក្រុងហុងកុង ដើម្បីឲ្យទៅគ្រប់គ្រង--

**អ្នកបកប្រែ៖**

លោកប្រធានខ្ញុំស្តាប់ឈ្មោះអម្បាញ់មិញ អត់បានទេលោកប្រធាន។ មិនដឹងគាត់និយាយឈ្មោះអីសូមឲ្យគាត់អានឈ្មោះម្តងទៀត។

[១៥:៤២:២៩]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរចុងក្រោយអម្បាញ់មិញនេះសាជាថ្មីម្តងទៀត ដោយសូមលោកប្រកបនូវឈ្មោះដែលលោកនិយាយទៅដល់នៅក្នុងសំណួរនេះឲ្យបានច្បាស់លាស់ បើអាចធ្វើបានគឺប្រកបដូចដែលបានធ្វើអម្បាញ់មិញនេះ ជាភាសាបារាំង ដើម្បីអាចរួមចំណែកក្នុងការជួយឲ្យ ទាំងអ្នកបកប្រែទាំងសាក្សី អាចស្តាប់យកអំពីឈ្មោះដែលលោកមានបំណងសួរ ចង្អុលទៅចំបុគ្គលនៅក្នុងការតាំងសំណួររបស់លោក។

**លោក បាណាបេ ណេគ្វី៖**

បាទលោកប្រធាន ខ្ញុំត្រូវធ្វើយ៉ាងដូច្នេះហើយ។ ខ្ញុំសួរអំមិញនេះ ខ្ញុំសួរថា តើគាត់បានដឹងថា នៅពេលណាដោយពិតប្រាកដនោះដែលលោក គ្រិន ត្រូវបានបញ្ជូនទៅហុងកុង ដើម្បីជំនួស សុខ "S-O-K" សរសេរជាភាសាបារាំង នេះជាឈ្មោះដែលខ្ញុំចង់សួរគាត់អម្បាញ់មិញលោកប្រធាន។

**លោក សតឹម ល្អុត៖**

**ឆ៖** ខ្ញុំមិនចាំថា គេបញ្ជូនលោក គ្រិន ហ៊្នឹងទៅហុងកុង ពីខែណាឆ្នាំណាច្បាស់ទេ ព្រោះបញ្ជូនអ៊ីចឹងៗជាកិច្ចការរបស់គណៈកម្មការពាណិជ្ជកម្ម មិនពាក់ព័ន្ធនឹងការងារខ្ញុំទេបាទ ឈ្មោះ គ្រិន ហ៊្នឹង។ ហើយឈ្មោះ គ្រិន ហ៊្នឹង *អង់ឡាប៉ែល* គ្រិន "K-R-I-N" គ្រិន, ឈ្មោះ គ្រិន អ៊ីចឹងបាទ។

**ស៖** បាទ អរគុណលោកសាក្សី។ បាទ នៅទីបញ្ចប់ខ្ញុំចង់និយាយដោយខ្លី អំពីទំនាក់ទំនងរបស់លោក ជាមួយលោក វ៉ាន់ រិទ្ធ។ រសៀលនេះលោកបានបំភ្លឺបន្តិចបន្តួចដែរ ដោយជម្រាបថា គាត់ជាអតីតកូនសិស្សរបស់លោកនៅវិទ្យាល័យស៊ីសុវត្ថិ អ៊ឺ-- គឺថាវាបន្ថែមលើការដែលលោកបានធ្វើការជាមួយគ្នានៅធនាគាររដ្ឋ មុននឹងពេលដែលលោកបានជួបគ្នាជាថ្មី នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ បាទសំណួរខ្ញុំដូចតទៅនេះ តើយើងត្រូវយល់ថា កម្រិតនៃវប្បធម៌របស់លោក ឬក៏ការស្គាល់គ្នារបស់លោក រវាងលោក វ៉ាន់ រិទ្ធ ហើយនិងលោកនោះ តើយោងលើលក្ខខណ្ឌនេះ នៅពេលដែលលោកដើរជាមួយគ្នានោះ? តើពេលដែលលោកជួបគ្នានោះ តើលោកអត់មាននិយាយផ្លោះប្តូរអីគ្នាទេទាក់ទងទៅនឹងគណៈកម្មាធិការពាណិជ្ជកម្មនោះ?

[១៥:៤៥:៣២]

**ឆ៖** បាទ អត់មានទេ រឿងអ៊ីចឹងៗខ្ញុំត្រូវតែបិទមាត់ជិតមិនត្រូវទៅបង្ហើបសួរអីទេ ឬក៏-- ខ្ញុំដឹងទៅក៏អត់មានប្រយោជន៍ដល់ខ្ញុំ ការងារមិនដឹងល្អជាង។ ខ្ញុំមិនបាន-- ពិតមែនថាធ្លាប់ស្គាល់គ្នាពីៗមុនសម័យមុន ពីព្រៃអ៊ីចឹងបាទ ដល់ជួបគ្នាស្ងាត់ម៉េច ក៏ខ្ញុំមិនប៉ានសួរដែរ អត់មានអីទេបាទ។

**ស៖** បាទសូមអរគុណលោកសាក្សី។ បាទ ខ្ញុំសុំបញ្ចប់ការចោទសំណួរទៅលោកនៅរសៀលហើយខ្ញុំសូមអរគុណដែលបានឆ្លើយមកសំណួររបស់ខ្ញុំទាំងអស់។

**លោក បាណាបេ ណេគ្វី៖**

លោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំគិតថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ចប់ការចោទសំណួរត្រឹមណេះហើយ។ ហើយសូមអរគុណលោកប្រធាន ហើយសូមអរគុណ

ដែលយកចិត្តទុកដាក់ក្នុងការស្តាប់ការចោទសំណួររបស់យើងខ្ញុំ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៧:៣៨]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកលោកសាក្សី ហើយកិច្ចដំណើរការស្តាប់សក្ខីកម្មរបស់សាក្សីមិនទាន់ចប់ទេ។ ដូច្នេះអង្គជំនុំជម្រះ សូមអញ្ជើញសាក្សីមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ ហើយសូមអញ្ជើញមកដល់កន្លែងផ្តល់សក្ខីកម្មនេះនៅវេលាម៉ោងប្រាំបួនព្រឹកថ្ងៃស្អែក។ ហើយដូចគ្នា អង្គជំនុំជម្រះអញ្ជើញលោកមេធាវី ដែលជាទីប្រឹក្សាសាក្សី សូមមកចូលរួមប្រឹក្សាសាក្សីបន្តនៅថ្ងៃស្អែកទៀត ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ។ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ គឺថ្ងៃស្អែក ទី២៥-- ទី៥ខែមិថុនា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសូមជម្រាបផងដែរថា សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី សតឹម ល្មុត ដែលតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តី ដែលនឹងចាប់ផ្តើមពីក្រុមមេធាវីការពារក្តីឲ្យលោក ខៀវ សំផន មុន មេធាវីពីរក្រុមទៀត។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងជំនាញ ក្នុងការបញ្ជូនសាក្សី សតឹម ល្មុត វិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ និងឲ្យនាំគាត់ឲ្យមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួនព្រឹក។

[១៥:៤៩:១៩]

ទន្ទឹមនឹងនេះដែរ អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនបានជ្រាបថា ប្រសិនបើកិច្ចដំណើរការថ្ងៃស្អែក ចំពោះសាក្សី សតឹម ល្មុត ធ្វើទៅចប់ ហើយនៅមានសល់ពេលវេលាសមស្រប អង្គជំនុំជម្រះនឹងបន្តការស្តាប់សក្ខីកម្មសាក្សី TCW-604 ដែលនឹងតាំងសំណួរដេញដោលដោយចាប់ផ្តើមដោយក្រុមសហព្រះរាជអាជ្ញា។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំពួកគាត់ទាំងបីនាក់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោង

ប្រាំបួន។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥០ នាទី)*